01386912

E1/485.1

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:០១នាទី**

**សវនាការលើកទី៤៦៦**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 03-Feb-2017, 14:41
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ហាសាន អាធុរេលិយ៉ា
*( Harshan ATHURELIYA)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក ចូសេហ្វ អេនឌ្រូ ប៊យលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡេប៉ា ជុនធី

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វួ សុទ្ធារី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ឡេា ជុនធី | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| សាក្សី 2-TCW-1037 | ខ្មែរ |
| លោក ស្ទីហ្វិន ម័ររីស (2-TCE-98) | អង់គ្លេស |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី៖** 2-TCW-1037

សួរបន្តដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្ដើមពី........................................................ ទំព័រ ២
សួរដោយលោក ឡោ ជុនធី ផ្ដើមពី........................................................ ទំព័រ ២៧
សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្ដើមពី........................................................ ទំព័រ ៣១

**ការសួរសំណួរទៅអ្នកជំនាញ៖ លោក ស្ទីហ្វិន ម័ររីស** (2-TCE-98)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................................ ទំព័រ ៣៩
សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី........................................................ ទំព័រ ៤៨

# កិច្ចដំណើរការនីតិវិធី

[០៩:០១:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះបន្តធ្វើសវនាការស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម2-TCW-1037 ហើយនិងផ្តើមស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-98។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ មានរហស្សនាម 2-TCW-1037។ លោក និងមេធាវីប្រឹក្សា លោក មឿន សុវណ្ណ មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ អ្នកជំនាញដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ទៀត មានរហស្សនាម 2-TCE-98។ អ្នកជំនាញបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា ឬលោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ អ្នកជំនាញនឹងធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

[០៩:០៣:០៥]

**ប្រធានអង្គជំនុំ៖**

អរគុណកញ្ញា ជា ស៊ីវហ៊ង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់

ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ដោយបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បាន យូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឱ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទ នៅ អ.វ.ត.ក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈវិលមុខ ឈឺចង្កេះពេលងើបឈរ ឬអង្គុយ និងផ្តល់អនុសាសន៍ថា សូមឱ្យអង្គជំនុំជម្រះអនុញ្ញាតឱ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការ ពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

[០៩:០៥:០៧]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឱ្យជនជាប់ចោទ នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឱ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលសវនាការថ្ងៃនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម និងមេធាវីភាគីទាំងអស់ ហើយសូមជម្រាបសួរសាក្សី សម្រាប់ថ្ងៃនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

**ស៖** នៅពេលដែលយើងបានសម្រាកកាលពីម្សិលមិញនោះ យើងបាននិយាយអំពីការងារនៅក្នុងក្រុមកងនេសាទដែលផ្គត់ផ្គង់ត្រីដល់កងយោធា។ សូមលោកប្រាប់តុលាការ ពីពេលណាដែលលោក

ឈប់ធ្វើការនៅក្នុងកងនេសាទ?

**2-TCW-1037៖**

**ឆ៖** បាទ ខ្ញុំឈប់ធ្វើការងារនៅកងនេសាទនេះគឺ ខ្ញុំឈប់ឆ្នាំ១៩៧៨។

[០៩:០៥:៣៧]

**ស៖** ហេតុអ្វីបានជាលោកឈប់ធ្វើការនៅក្នុងកងនេសាទនៅពេលនោះ?

**ឆ៖** ខ្ញុំឈប់ធ្វើការងារក្នុងកងនេសាទហ្នឹង គឺដោយសារកម្លាំងទ័ពរបស់ថ្នាក់លើហ្នឹង គឺបានរំលាយអង្គភាព និងមន្ទីររបស់ខ្ញុំខាងនេសាទ ខាងសេដ្ឋកិច្ចហ្នឹងគឺចោល ដកហូត បំបែកកម្លាំងយកទៅដាក់តាមសហករណ៍ផ្សេងៗជាច្រើនកន្លែង ដូចជានៅសហករណ៍សាលាតាអន បញ្ជូនទៅភ្នំធិបតី ហើយនិងបញ្ជូនទៅកន្លែងផ្សេងៗមួយចំនួនទៀត។

**ស៖** នៅពេលដែលលោកនិយាយថា យោធាមកពីថ្នាក់លើ តើលោកសំដៅទៅកងយោធាខាងនិរតីដែរឬទេ?

**ឆ៖** បាទ កាលនុ៎ងខ្ញុំឃើញកម្លាំងទ័ពនិរតីចុះមកច្រើន មានកាណូតបួនប្រាំកាណូតបើកចុះទៅដល់តំបន់បាក់ព្រា ទន្លេសាបហ្នឹងទៅកៀរយកប្រជាពលរដ្ឋរាប់រយគ្រួសារហ្នឹង បញ្ជូនឡើងទៅតំបន់ផ្សេងៗ ដូចជាតំបន់៤ ហើយនិងតំបន់៧ខាងៗអីខាងស្រុកគាស់ក្រឡអីផង ទៅខាងភ្នំធិបតីហ្នឹងផង គឺបញ្ជូនទៅដាក់តាមសហករណ៍ផ្សេងៗ។

**ស៖** តើខ្លួនលោកផ្ទាល់ លោកទៅកន្លែងណាដែរនៅពេលនោះ?

**ឆ៖** បាទ នៅពេលនុ៎ងខ្ញុំមានប្រហែលជាប្រាំពីរ ប្រាំបីគ្រួសារទេ ដែលគេឲ្យខ្ញុំហ្នឹងរស់នៅនឹងសហករណ៍សាលាតាអន។ នៅភូមិគេហៅភូមិតាដក់ អ៎! អន្លង់តាដក់ បាទ នៅភូមិអន្លង់តាដក់ស្ថិតនៅក្នុងសហករណ៍សាលាតាអន តំបន់៤ហ្នឹងតែម្តង។

[០៩:០៨:១៥]

**ស៖** នៅពេលដែលលោកទៅរស់នៅក្នុងសហករណ៍នេះ តើលោកបានកត់សម្គាល់ឃើញថាមានជីវភាពរស់នៅហ្នឹងមានការ<ខុសប្លែកគ្នា>ដូចម្តេចដែរ <បើធៀបនឹង>ពេលដែលលោកទៅនៅក្នុង<>កងយោធា<>នោះ?

**ឆ៖** បាទ កាលនុ៎ងគឺខ្ញុំ ខ្លួនខ្ញុំផ្ទាល់ខ្ញុំឃើញថា ការរស់នៅក្នុងសហករណ៍ហ្នឹងគឺមានជីវភាពកាន់តែលំបាកច្រើនជាងដែលខ្ញុំរស់នៅក្នុងជួរអង្គភាពទ័ពទៀត ព្រោះអង្គភាពទ័ពមានការខ្វះខាត មាន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បបរមានបាយខ្លះ មានពេលខ្លះមានបបររឹង ពេលខ្លះមានបាយ។ ដល់ពេលៗទៅសហករណ៍គឺបបរព្រឹក បបរល្ងាច។ និយាយរួមទៅក្នុង១០នាក់ គេឲ្យហូបតែពីរកំប៉ុងទៅបីកំប៉ុងទេ ក្នុងមួយខ្ទះហ្នឹងបបរក្នុងមួយខ្ទះហ្នឹងដាក់បានតែប៉ុណ្ណឹង។

**ស៖** លោកបាននិយាយអំពីទីកន្លែងមួយចំនួនដែលថាកងនេសាទបានទៅ ថាតើ<មាននរណាខ្លះបាន>ទៅដាក់<កន្លែងមួយហៅថា>គុកកកោះដែរឬទេ?

**ឆ៖** កន្លែងគុកកកោះហ្នឹង គឺពួកខ្ញុំមិនបានទៅទេ។ តែខាងយោធា បាទយោធាភាគហ្នឹងមួយចំនួនហ្នឹងគឺគេបានយកទៅលត់ដំនៅកន្លែងគុកកកោះហ្នឹងច្រើនគ្នាដែរ។ តែខ្ញុំអត់ស្គាល់ពិតប្រាកដថាឈ្មោះណាមួយទេ គ្រាន់តែដឹងថាខាងទ័ពរបស់ភាគហ្នឹង គឺមួយចំនួនហ្នឹង គេបានយកទៅដាក់នៅកន្លែងលត់ដំ កន្លែងកកោះហ្នឹងច្រើនគ្នា។

**ស៖** តើលោកអាចជម្រាបតុលាការបន្ថែមផ្សេងទៀតទេ <>អំពីគុកនៅកកោះនោះ <ក្រៅពីការប្រើប្រាស់ទីនោះជាកន្លែងសម្រាប់ដាក់អ្នកទោសយោធា> ភូមិភាគ<ក្នុងទ្រង់ទ្រាយធំ>?

តើលោកបានស្ដាប់ឮសំណួរខ្ញុំទេ? បាទ ខ្ញុំនឹងសួរឡើងវិញ ខ្ញុំចង់ឲ្យលោកជម្រាបតុលាការ ថាតើលោកដឹងពីអ្វីទៀតទេ <បន្ថែម>ពី<លើការពិតដែលថា គុកកកោះត្រូវប្រើជាកន្លែង>ឃុំឃាំង<អ្នកទោសយោធាភូមិភាគពាយ័ព្យ។> តើលោកបានដឹងអ្វីថែមទៀតដែរឬទេ?

[០៩:១១:២៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកស្រីមេធាវី អង់តា ហ្គីសសេ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអន្តរាគមន៍នៅក្នុងពេលនេះ ព្រោះខ្ញុំមិនដឹងថាតើសហព្រះរាជអាជ្ញាចង់បានអីទេ នៅពេលដែលគាត់សួរសំណួរទាំងអស់ហ្នឹង។ ខ្ញុំចង់ដឹងថាតើគាត់សួរហ្នឹង ពាក់ព័ន្ធនឹងផ្នែកណានៃដីកាសម្រេចបំបែកនីតិវិធីនោះ?<ហើយបើវាជា>មន្ទីរសន្តិសុខ<ឬជាគុកដែលជាផ្នែក>នៃដីកាបំបែកនីតិវិធី <មានន័យថា>វា<ស្ថិត>នៅ<ក្នុង>វិសាលភាពនៃសំណុំរឿង០០២/០២ ហើយលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

ដើម្បីឆ្លើយតបហ្នឹង គឺថាសំណួររបស់ខ្ញុំពាក់ព័ន្ធទៅនឹងការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យ ហើយចង់ដឹងថាតើគេបញ្ជូនទៅទីណា ហើយគេធ្វើប្រព្រឹត្តទៅលើអ្នកទាំងអស់នោះដូចម្ដេច។ ហើយខ្ញុំក៏មិនសួរពីលក្ខណៈពិសេសនៅមន្ទីរសន្តិសុខនោះទេ គឺខ្ញុំគ្រាន់តែចង់ដឹងពីគោលនយោបាយពាក់ព័ន្ធទៅនឹងការបោសសម្អាតកម្មាភិបាលតែប៉ុណ្ណោះ។

[០៩:១២:៥០]

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ឆ៖** លោកសាក្សី--

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់នេះ ហើយសំណួរនេះអាចសួរបាន ប៉ុន្តែវាពាក់ព័ន្ធនឹងគោលនយោបាយ។ សាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ បើសិនបើលោកចាំនូវសំណួរ។

**2-TCW-1037៖**

**ឆ៖** បាទ ក្នុងចំណុចហ្នឹង រឿងកន្លែងកកោះហ្នឹង មិនមែនជាកន្លែងគុកដាក់អីទេ កន្លែងហ្នឹងគឺតាមខ្ញុំដឹងគឺកន្លែងលត់ដំ កន្លែងកែប្រែ។ អ្នកទោសល្មមៗគេយកទៅលត់ដំកែប្រែកន្លែងហ្នឹង ហើយមានការ អាណាវាងប្រព្រឹត្តធ្ងន់ធ្ងរអីបន្តិចបន្តួចហ្នឹង គឺយប់ឡើង គេមានកន្លែងគេឲ្យនៅកន្លែងផ្សេងអីចឹង តាមខ្ញុំដឹងមួយចំនួន តែខ្ញុំអត់ដែលបានទៅនៅកន្លែងហ្នឹងទេ។ នេះតាមព័ត៌មានបងប្អូនខាងយោធាហ្នឹងគេប្រាប់ខ្ញុំអីចឹង។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** លោកទើបតែបាននិយាយអំពីភាពខុសគ្នានៃការប្រព្រឹត្តទៅលើអ្នកទោស ដែលគេថាអ្នកទោសធ្ងន់ អ្នកទោសស្រាល។ តើលោកដឹងដែរឬទេ ថាតើគេបញ្ជូនថ្នាក់ដឹកនាំ ឬកម្មាភិបាលដឹកនាំខ្ពស់ៗមួយចំនួន<នៅភូមិភាគពាយ័ព្យនោះ> គេចាប់ ហើយគេបញ្ជូនយកទៅណាដែរ តាមដែលលោកដឹងនោះ?

[០៩:១៤:៣៥]

**ឆ៖** ចំណុចហ្នឹង ខ្ញុំមិនដឹងច្បាស់ថាយកទៅណាទេ ក៏ប៉ុន្តែបើកម្មាភិបាលធំៗ ថ្នាក់ភូមិភាគ

ថ្នាក់វរសេនាធំអីអស់ហ្នឹង ថ្នាក់តំបន់អីហ្នឹង គឺគេមិនដែលឲ្យដឹងថាគេទុកនៅនឹងខេត្តហ្នឹងនៅកន្លែងណាផង តែភាគច្រើនគេថាអ្នកធំ គេបញ្ជូនមកភ្នំពេញ នេះតាមដែលខ្ញុំឮខាងទ័ពគេអ្នកនិយាយប្រាប់អីចឹង។

**ស៖** នៅពេលលោកនិយាយថា លោកដឹងពីទ័ព<ភូមិភាគ>ថា តើលោកបានឮពីកងទ័ព<ភូមិភាគ>ហ្នឹង ភូមិភាគពាយ័ព្យ ឬក៏ពីទ័ពខាងភូមិភាគនិរតី?

**ផ៖** ពីទ័ពភូមិភាគពាយ័ព្យ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំនឹងសួរសំណួរលោកអំពីប្រធានបទមួយចំនួនដែលលោកបានឆ្លើយនឹងសំណួរមួយចំនួនកាលពីម្សិលមិញ ហើយខ្ញុំចង់ចាប់ផ្ដើមសួរលោកអំពីបុគ្គលម្នាក់ដែលលោកនិយាយនៅក្នុងបទសម្ភាសន៍របស់លោកគឺឈ្មោះ តាហំ។ សូមលោកជម្រាបតុលាការម្ដងទៀតថាតើ តាហំ នេះគាត់មានតំណែងអ្វីដែរនៅភូមិភាគពាយ័ព្យកាលនោះ?

**ផ៖** បាទ តាហំ ហ្នឹងគាត់មានមុខតំណែងក្នុងអង្គភាពសេនាធិការរបស់ភូមិភាគ។

**ស៖** លោកបាននិយាយថានៅក្នុងចម្លើយទៅ<ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា គឺឯកសារ> E3/10666, អង់គ្លេស 01330540, ខ្មែរ 01326329។ "សំណួរ៖ តើប្រធានមន្ទីរសេដ្ឋកិច្ចភូមិភាគឈ្មោះអ្វី? គាត់ឈ្មោះ តាហំ។ តើ<សេដ្ឋកិច្ច និង>ភស្តុភារដូចគ្នាទេ? <បាទ គឺដូចគ្នា> ប៉ុន្តែពួកគាត់ស្ថិតនៅក្នុងយោធា។ ភូមិភាគ<ខុសគ្នា>។" តើ តាហំ ហ្នឹងគាត់ជាប្រធានមន្ទីរសេដ្ឋកិច្ចផង ខាងភស្តុភារផង អីចឹងត្រឹមត្រូវដែរទេ គឺភស្តុភារខាងយោធាភូមិភាគ?

[០៩:១៧:៣៥]

**ផ៖** បាទ ចំណុចនេះ ខ្ញុំជម្រាបថា តាហំ ហ្នឹងគាត់មិនមែនប្រធានសេដ្ឋកិច្ចយោធាភាគទេ គាត់នៅខាងផ្នែកសេនាធិការកាន់ខាងភស្តុភារ។ បាទ ហើយប្រធានសេដ្ឋកិច្ចរបស់យោធាភាគ គឺឈ្មោះ តាស៊ុម។ សេដ្ឋកិច្ច ប្រធានយោធាភាគហ្នឹងគឺឈ្មោះ តាស៊ុម នៅខាងផ្នែកនេសាទ។

**ស៖** តាហំ ដែលលោកបញ្ជាក់នៅក្នុងចម្លើយរបស់លោកហ្នឹង តើលោកដឹងឈ្មោះនាមត្រកូលនាម និងនាមត្រកូលរបស់គាត់ទេ? <ខ្ញុំដឹងថា> តាហំ ហ្នឹងជាឈ្មោះហៅក្រៅរបស់គាត់ <ប៉ុន្តែតើលោកស្គាល់ឈ្មោះពិតគាត់>ទេ?

**ផ៖** ខ្ញុំអត់ស្គាល់ ខ្ញុំអត់ស្គាល់ត្រកូលគាត់ផង ស្គាល់តែនាមរបស់គាត់ ផន់គាត់។ គេហៅ តាហំៗ ហ្នឹងគឺធ្លាប់ឮអីចឹងមក ហៅ តាហំៗ អីចឹងទៅ ប៉ុន្តែនាមៗត្រកូលគាត់មិនដឹងនាមអី អត់ដឹងឈ្មោះ។

**ស៖** តើក្រោយមក តាហំ ហ្នឹងគាត់មានរឿងអ្វី ឬជួបបញ្ហាអ្វីដែរឬទេ?

**ឆ៖** បើក្នុងបញ្ហាហ្នឹង រឿងនេះ វាដូចខ្ញុំបានជម្រាបខាងដើមថា វាជាប់ពាក់ព័ន្ធនឹងកម្មាភិបាលរបស់ភូមិភាគហ្នឹង គេថាជាខ្មែរយៈក្បត់ ជាសេ.អ៊ី.អា ជាដឺ.បេ អីអ៊ីចឹង ការបង្កប់ផ្ទៃក្នុង ព្រោះអង្គការថ្នាក់ដឹកនាំខាងលើគេចោទអ៊ីចឹង គេថាខ្មែរយៈក្បត់ តាំងពីថ្នាក់លើរហូតដល់ថ្នាក់ក្រោមអ៊ីចឹង។ អ៊ីចឹងបញ្ហាមានតែពាក់ព័ន្ធមានតែប៉ុណ្ណឹងឯង បានគេចាប់ខ្លួនកាលហ្នឹង។

**ស៖** តើគេចាប់ខ្លួនគាត់ដែរឬទេ?

[០៩:១៩:៥៤]

**ឆ៖** កាលហ្នឹងខ្ញុំអត់បាន – បាទ កាលហ្នឹងខ្ញុំអត់បានឃើញគេចាប់ទេ តែអ្នកដែលរស់នៅនៅក្នុងកន្លែងគាត់ហ្នឹង ជាយោធារស់នៅធ្វើការងារនៅក្នុងមន្ទីរហ្នឹង គេប្រាប់ខ្ញុំថា គេហៅគាត់ទៅរៀនសូត្រ ក៏ទៅបាត់បណ្ដោយ។ យកទៅបាត់បណ្ដោយទៅ អត់ដឹងថា គេហៅទៅ គេសម្លាប់ ឬក៏គេចាប់នៅកន្លែងណាគឺអត់ដឹង បាត់ខ្លួនតាំងពីថ្ងៃហ្នឹងមក គឺបាត់រហូត។

**ស៖** តើលោកដឹងដែរឬទេ ពេលដែលគេហៅគាត់ទៅរៀនសូត្រហ្នឹងគឺក្នុងអំឡុងខែឆ្នាំណាដែរ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ តែកាលនោះ ខ្ញុំចាំបានប្រហាក់ប្រហែលឆ្នាំ១៩៧៧ ឬក៏ពាក់កណ្ដាលឆ្នាំ៧៧ ហ្នឹង។

**ស៖** សូមអរគុណ។ លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមរំឭកទៅភាគី ជាពិសេសសហព្រះរាជអាជ្ញា សូមឱ្យលោកទុកគម្លាតបន្តិចមុនពេលលោកសួរសំណួរហ្នឹង ដើម្បីឱ្យអ្នកបកប្រែគាត់អាចបកប្រែទាន់។ អម្បាញ់មិញហ្នឹង សំណួរចុងក្រោយរបស់លោកអម្បាញ់មិញហ្នឹង គឺអ្នកបកប្រែ គាត់បកមិនទាន់ទេ ដោយសារតែអ្នកឆ្លើយចប់ភ្លាម លោកសួរភ្លាម អ៊ីចឹងអ្នកបកប្រែអត់មានពេល។

[០៩:២១:៤២]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

បាទ ខ្ញុំគោរពតាមនេះ ហើយសូមអភ័យទោសអ្នកបកប្រែ។ លោកប្រធាន សុំការអនុញ្ញាត

បង្ហាញទៅសាក្សីនូវឯកសារមួយចំនួន ហើយនិងបង្ហាញនៅលើអេក្រង់ផងដែរ ដើម្បីរំឭកការចងចាំរបស់គាត់។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី ខ្ញុំនឹងបង្ហាញជូនលោកនូវឯកសារប្រាំ ជាពិសេសនៅលើអេក្រង់ទូរទស្សន៍ ជាឯកសារនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយខ្ញុំនឹងពិនិត្យមើលឯកសារនេះ ហើយនិងប្រាប់លោកឱ្យពិនិត្យមើលតាមដែលខ្ញុំណែនាំនៅពេលនោះ ហើយនិងសួរលោកបន្តពីនោះ។ លោកសាក្សី នេះជាឯកសារ <E3/8707.7> គឺថាឯកសារ 00143315 ហើយនៅក្នុងឯកសារ <E3/8707> ខ្មែរ <00052760> គឺជាឯកសារពី ចាន់ <នៅមន្ទីរ ស-២១> គោរពជូនទៅ ឌុច គឺ<ថ្ងៃ១៥ ខែកញ្ញា>នៅក្នុងឆ្នាំ១៩៧៧ <រាយការណ៍អំពីអ្នកទោសដែលបានយកចេញទៅ>គឺនៅ<ថ្ងៃទី១៣> ខែ<កញ្ញា> ១៩៧៧ <មានការលើកឡើងតែមួយទេសម្រាប់ថ្ងៃនោះ សូមដកស្រង់> "ឈ្មោះថា ភី ហ៊ីង ហៅ ហំ ប្រធានសេដ្ឋកិច្ចឃោធាភូមិភាគ<ពាយ័ព្យ>។" ហើយទៅឯកសារមួយទៀតគឺ E3/10275 គឺមានតែជាភាសាខ្មែរទេ ជាបញ្ជីអ្នកទោស ស-២១ គឺខ្មែរ 01017124។ យើងសូមបង្ហាញឯកសារនៅលើអេក្រង់ គឺឈ្មោះ ភី ហ៊ីង ហៅ ហំ គឺចូលមកដល់ ស-២១ ថ្ងៃទី១៣ ខែ៩ ឆ្នាំ៧៧ <អាយុ៣៦ឆ្នាំ> ដែលបញ្ជាក់ថាគាត់ជាប្រធានខាងសេដ្ឋកិច្ច<ឃោធាភូមិភាគពាយ័ព្យ>។ គឺថាឯកសារមួយទៀត E3/3182, ខ្មែរ 00088690, អង់គ្លេស <00784613><គឺជាបញ្ជីអ្នកទោស ស-២១> នៅក្នុងនេះគឺដាក់ឈ្មោះថា <ហ៊ី> ហ៊ីង ហៅ ហំ <ភេទប្រុស អាយុ៣៥ឆ្នាំ មកពីភូមិភាគពាយ័ព្យ ត្រូវបានគេរៀបរាប់ថា>គឺជាប្រធាន<កសិដ្ឋាន បានចូលនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៧៧ ហើយស្លាប់ដោយសារជំងឺនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៧>។

[០៩:២៤:៥៨]

ឯកសារមួយទៀត <>គឺឯកសារ E3/10003 គឺមានតែមួយទំព័រទេ ខ្មែរគឺ 01012327 គឺថាមានតែភាសាខ្មែរទេ។ គឺបញ្ជីប្រចាំថ្ងៃរបស់អ្នកទោស ដែលចុះថ្ងៃទី០៧, ០៨ ខែតុលា ឆ្នាំ១៩៧៧ ដែលនៅខាងក្រោមនោះ ហ៊ី បញ្ជាក់ថា "មនុស្សបីនាក់ស្លាប់" គឺថាមួយ នៅក្នុងនោះគឺ <ហ៊ី> ហ៊ីង ហៅ ហំ <ដែលជាប្រធានការដ្ឋានឃោធាភូមិភាគពាយ័ព្យ។> ហើយនិងសូមបង្ហាញឯកសារនេះ នៅលើ

អេក្រង់ផងដែរ។

សូមអនុញ្ញាតឲ្យខាងប្រព័ន្ធសោតទស្សន៍បង្ហាញឯកសារនេះនៅលើអេក្រង់<>។ សូមអរគុណ គឺឯកសារចុងក្រោយនោះ គឺឯកសារ E3/1208 គឺជាសារទូរលេខដែលបញ្ជូនដោយ រស់ ញឹម គឺជាលេខាភូមិភាគពាយ័ព្យ គឺជូនទៅអង្គការ៨៧០ គឺដែលចុះថ្ងៃទី២១ ខែ<ធ្នូ> ឆ្នាំ១៩៧៧។ <រស់ ញឹម មិនដឹងថា> ហំ <បានស្លាប់ទៅហើយនោះទេ> គឺគាត់សុំ<ព័ត៌មានដែលទទួលបានពី ហំ ដើម្បីឲ្យគាត់អាចចាប់ខ្លួនជំនួសឲ្យអង្គការ។ សូមដកស្រង់> “ខ្ញុំ<សង្ឃឹមថា>សន្តិសុខ<សួរ ហំ ដែល>ជាអ្នកទទួលបន្ទុកខាងភស្តុភារយោធាភូមិភាគ<ឲ្យបានឆាប់ ដូច្នេះអ្នកដែលជាប់ទាក់ទងជាមួយវា គឺត្រូវបាន>កំណត់ឈ្មោះ <និង>ត្រូវចាប់ខ្លួនជាបន្ត។” ហើយអ៊ីចឹងជូនព័ត៌មានដល់អង្គជំនុំជម្រះ និងភាគី គឺថានៅក្នុងបញ្ជី អូ.ស៊ី.អាយ.ជេ គឺ<E3/10604> គឺនៅត្រង់លេខរៀង១៧៩១ <គឺបុរសអាយុ៣៦ឆ្នាំម្នាក់> ដែលដាក់ឈ្មោះថា ភី <ឬ ហ៊ី> ហ៊ីង ហៅ ហំ <ប្រធានសេដ្ឋកិច្ចយោធាភូមិភាគពាយ័ព្យ> ដែលថាចូលមកដល់ស-២១ នៅថ្ងៃទី១៣ <ឬ> ១៤ ខែ៩ ឆ្នាំ១៩៧៧។ ហើយគាត់បានស្លាប់នៅថ្ងៃទី០៧ ឬថ្ងៃទី<០៨ ខែតុលា> ១៩៧៧។

អ៊ីចឹងគឺថា ដោយបានឃើញព័ត៌មានបែបនេះ ថាតើ<វាធ្វើឲ្យលោកនឹកឃើញឡើងវិញទេ>ថា <តា> ហំ <ដែលលោកស្គាល់ថាជាអ្នកធ្វើការខាងសេដ្ឋកិច្ចយោធាភូមិភាគ ហើយ>ត្រូវបានគេចាប់ខ្លួននៅ<ពេលណាមួយ>ក្នុង<ពាក់កណ្តាល>ឆ្នាំ១៩៧៧ គឺ ហំ ហ្នឹងគឺជាបុគ្គលដែលឈ្មោះថា ហ៊ី ហ៊ីង ឬ ភី ហ៊ីង <ហើយគាត់ត្រូវបានគេបញ្ជូនមកស-២១នៅភ្នំពេញ>ហ្នឹងដែរឬយ៉ាងដូចម្តេច?

[០៩:២៨:១៨]

**2-TCW-1037៖**

**ឆ៖** បាទ កន្លែងហ្នឹងខ្ញុំ ឈ្មោះ ភី ហ៊ីង ខ្ញុំមិនដែលឮទេ ខ្ញុំឮតែឈ្មោះ ហំៗ តាំងពីខ្ញុំស្គាល់មក តាំងពីនៅធ្វើសង្គ្រាមមិនទាន់បានរំដោះថ្ងៃ អ៊ំ! ឆ្នាំ១៩៧៥ហ្នឹង ក៏ហៅតែគាត់ឈ្មោះ ហំ ឈ្មោះ ហំ ហ្នឹងរហូត។ អត់ដែលស្គាល់ឈ្មោះក្រៅពី ហំ ហ្នឹងទេ។

**ស៖** សូមអរគុណ។ លោក លោកស្រីចៅក្រម ពីព្រោះម្សិលមិញហ្នឹង គឺមានការប្រកាសដោយមេធាវី<ការពារក្តីលោកនួន ជា> បញ្ជាក់នៅក្នុងតុលាការអំពីសច្ចភាព<នៃសាក្សីម្នាក់ដែលបានបង្ហាញខ្លួន និងការ>កំណត់អត្តសញ្ញាណ<របស់គាត់។> ខ្ញុំសូមបញ្ជាក់ថា គឺថាយ៉ាងហោចណាស់ គឺមាន<> តាហំ ហ្នឹងច្រើនជាងមួយនៅក្នុងភូមិភាគពាយ័ព្យ ហើយតាមពិត គឺកំណត់ហេតុគឺថា <2-

TCW-1036> គឺឯកសារ E3/9581 គឺត្រង់សំណួរចម្លើយ៦៧ហ្នឹង គាត់បញ្ជាក់ថា យ៉ាងហោចណាស់ គឺមានមនុស្សបីនាក់ឈ្មោះ ហំ នៅក្នុងភូមិភាគពាយ័ព្យ។ គឺចម្លើយរបស់សាក្សី 2-TCW-1036។

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹងគឺថាសូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ខ្ញុំយល់អំពីអ្វីដែលសហព្រះរាជអាជ្ញាបញ្ជាក់ ប៉ុន្តែដើម្បីឲ្យពេញលេញនៅក្នុងព័ត៌មាន ដើម្បីជាអត្ថប្រយោជន៍របស់អង្គជំនុំជម្រះតុលាការកំពូលនោះ <ទាត់> គឺអ្នកដែលផ្ដល់បទសម្ភាសន៍ទៅអ្នកស៊ើបអង្កេតនោះនិយាយនៅក្នុងឯកសារ <E3/9610>ហ្នឹង នៅក្នុងចម្លើយ៣១ ដូចខាងក្រោមនេះ៖ “ខ្ញុំប្រើឈ្មោះហៅក្រៅ ហំ ហើយ គឺបងធម៌ខ្ញុំ គឺថា បានឃើញឈ្មោះខ្ញុំត្រូវគេសម្លាប់នៅស-២១ ប៉ុន្តែក្រោយមក គាត់បានដឹងថា ខ្ញុំរស់នៅ គាត់ក៏បាន<ឲ្យខ្ញុំ>ពិនិត្យមើល<បញ្ជី>ឈ្មោះខ្ញុំនៅស-២១” <ដូច្នេះ>ចម្ងល់<នេះនៅ>មិនត្រូវបានដោះស្រាយ<នៅឡើយ>ទេ។

[០៩:៣០:៥១]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

យើងមិនទាន់ចូលទៅដល់ការពិភាក្សាដេញដោលទេ។ <ខ្ញុំរីករាយនឹងធ្វើសារណាលើបញ្ហានេះ។ ខ្ញុំមានទំនុកចិត្តខ្លាំងណាស់នៅក្នុងតួនាទីរបស់យើង។> ប៉ុន្តែ<ព័ត៌មាន>ដែលមេធាវីបញ្ជាក់ឡើងឥឡូវហ្នឹង ដើម្បីគាំទ្រទស្សនៈរបស់ខ្ញុំតែប៉ុណ្ណោះ គឺថាអាចនឹងមានឈ្មោះ ហំ ច្រើននាក់នៅក្នុងភូមិភាគពាយ័ព្យ <ដូចដែលមាននៅក្នុងភស្តុតាងដែលយើងទទួលបាន>។ ហើយយើងនឹងនិយាយពីការពិភាក្សាដេញដោលនេះ នៅក្នុងសេចក្ដីសន្និដ្ឋានបញ្ចប់ការដេញដោល។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** ប៉ុន្តែលោកសាក្សី ខ្ញុំនឹងបន្តដោយសួរសំណួរមួយចំនួនទៅលោក គឺទាក់ទងទៅនឹង តាខ្លែង ដែលលោកបានឆ្លើយនឹងសំណួរមួយចំនួនពីម្សិលមិញផងដែរ។ លោកឆ្លើយនៅក្នុងសក្ខីកម្ម នៅក្នុងចម្លើយរបស់លោកថា តាខ្លែង ជាប្រធាននៃសេនាធិការយោធានៅក្នុងភូមិភាគពាយ័ព្យ។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

**2-TCW-1037៖**

**ឆ៖** បាទ ចំណុចហ្នឹងគឺត្រឹមត្រូវ មិនត្រឹមត្រូវ ខ្ញុំមិនប្រាកដដែរ ក៏ប៉ុន្តែខ្ញុំដឹងថា គាត់នៅក្នុងអង្គ

ភាពសេនាធិការ នៅក្នុងជួរសេនាធិការកងពលលេខ១ លេខ២ហ្នឹង។

**ស៖** សូមអរគុណ។ ហើយលោកក៏បាននិយាយដែរថា គេបានចាប់ខ្លួនគាត់។ តើលោកដឹងទេ ក្រោយពីគេចាប់ខ្លួនគាត់ទៅ គាត់ជួបនឹងបញ្ហា ឬក៏រឿងអ្វីដែរ?

[០៩:៣២:២៧]

**ឆ៖** តាមខ្ញុំដឹង គឺរឿងដូចខ្ញុំបានជម្រាបខាងដើមថា វាជាខ្សែរយៈ ខ្សែចង្វាក់អ្នកធ្វើការងារនៅក្នុងជួររបស់កម្មាភិបាលយោធាភាគ ភូមិភាគហ្នឹង គឺសុទ្ធតែពាក់ព័ន្ធទៅជាខ្សែចង្វាក់រួម ឃុបឃិតគ្នាចោទថា ការក្បត់ ការអីអឺចឹងទាំងអស់ គឺរឿងតែមួយហ្នឹងតែម្តង។

**ស៖** នេះជាអ្វីដែលលោកឆ្លើយនៅក្នុងបទសម្ភាសន៍ គឺ E3/9580។ "សំណួរលេខ៥៖ ក្រៅពីតាស៊ុម ដែលជាប្រធានខាងនេសាទ តើមានអ្នកណាផ្សេងទៀតទេ? ឆ្លើយថា៖ នៅពេលនោះគឺមាន តាឆាំ, តាខ្លែង និង តាហំ ហើយអ្នកដែលគេចាប់ខ្លួនក្រោយគេគឺ តាញឹម។ តាមខ្ញុំដឹង តាខ្លែង ដែលជាសេនាធិការយោធាភូមិភាគ ប្រហែលជាគេយកទៅដាក់នៅស-២១។ មុនដំបូងបង្អស់ គេចាប់ប្រធានកងពលលេខ១ និងលេខ២ រួចទើបគេបន្តចាប់វរសេនាធំ និងមេវរសេនាតូច និងកងកាំភ្លើងធំ។" <នៅក្នុងចម្លើយនេះ លោកថា "ប្រហែលជាគេបញ្ជូនទៅ ស-២១" តើលោកអាចជម្រាបជូនតុលាការបានទេ ថាតើលោកបានដឹងអ្វីខ្លះ បានជាលោកនិយាយថា ប្រហែលជាគេ>បញ្ជូន<គាត់>ទៅស-២១<នោះ>?

**ឆ៖** បាទ ខ្ញុំក្រៅពី តាហំ និង តាខ្លែង ហ្នឹងខ្ញុំអត់ដឹងថា គេបញ្ជូនទៅណាទេ តែខ្ញុំដឹងថា តាខ្លែង និង តាហំ ហ្នឹងគេបញ្ជូនមកភ្នំពេញ។ តែផុតពីហ្នឹង អត់ដឹងថា គេយកទៅណាខ្លះ គឺខ្ញុំអត់ដឹងដែរ ព្រោះពេលចាប់ហ្នឹង អត់មានពេលចាប់ថ្ងៃដំណាលតែមួយ ថ្ងៃតែមួយទេ គឺថ្ងៃខុសគ្នា ហើយខែខុសគ្នា។

[០៩:៣៤:៤០]

**ស៖** ខ្ញុំនឹងសួរសំណួរដដែល ទាក់ទងទៅនឹង តាខ្លែង តើឈ្មោះពិតប្រាកដរបស់ តាខ្លែង ហ្នឹង លោកស្គាល់ទេ គាត់មាននាមត្រកូល នាមខ្លួនអ្វី?

**ឆ៖** ខ្ញុំអត់ស្គាល់ដែរ ព្រោះគាត់រស់នៅភូមិខុសគ្នាឆ្ងាយណាស់ ពិតមែនពីដើមមក គឺឃុំកំពង់គល់ដូចគ្នាមែន ក្នុងឃុំហ្នឹងមែន ប៉ុន្តែគាត់ភូមិគាត់ខុសគ្នា ព្រោះគាត់នៅទៅប៉ែកខាងលើនោះ គេហៅភូមិសង្កែវារនោះ គឺខ្ញុំអត់ដឹងឈ្មោះអីក្រៅពី តាខ្លែង ហ្នឹងទេ គេហៅ តាខ្លែងៗ ទៅ។

**ស៖** នៅក្នុងសំណុំរឿងនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត<ដែលជាបញ្ជី ស-២១> គឺ E3/10604 គឺត្រង់លេខ<៧២២៣> ឈ្មោះ លឹម <ឈួម> ហៅ ខ្លែង គឺអាយុនៅពេលនោះ៤២

ជាអនុ<លេខា> កងពលលេខ២ <ភូមិភាគពាយ័ព្យ> ដែលទៅដល់ស-២១ នៅថ្ងៃទី<១៨> ខែធ្នូ ឆ្នាំ ១៩៧៧។ តើរំឭកដល់ការចងចាំរបស់លោកទេ តាខ្លែង ហ្នឹងគឺមានឈ្មោះពេញគឺ លឹម ឈួម? តើលោកធ្លាប់ដឹង ឬក៏ឮបែបនេះទេ?

**ឆ៖** បាទ អត់ដែលឮផង។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំបន្តទៅសួរសំណួរមួយចំនួនទៀតទាក់ទងទៅនឹង តាវ៉ាញ ដែលលោកបានឆ្លើយពីម្សិលមិញផងដែរ។ លោកបាននិយាយពីម្សិលមិញថា តាវ៉ាញ គឺថិតនៅក្នុងគណៈនៃគណៈកម្មការនៅក្នុងតំបន់២។ តើលោកស្គាល់ឈ្មោះជានាមខ្លួន នាមត្រកូលរបស់ តាវ៉ាញ ទេ ក្រៅពី តាវ៉ាញ នេះ?

[០៩:៣៦:៥៨]

**ឆ៖** ខ្ញុំមិនដឹងថាឈ្មោះមុនមកឈ្មោះអី គេហៅថា តាវ៉ាញៗ ព្រោះគាត់ហ្នឹងគាត់អ្នកតស៊ូអតីតជំនាន់មុន មុនឆ្នាំ១៩៧០ទៀត ព្រោះ តាវ៉ាញ ហ្នឹងគាត់កាលនៅសង្គ្រាមគាត់ជាគណៈតំបន់២ ហើយខ្ញុំឧស្សាហ៍ចេញចូល បានជាស្គាល់គាត់ ដោយសារកាលនុ៎ងខ្ញុំទាក់ទងរឿងស្បៀងរឿងអីហ្នឹង ដើម្បីដោះស្រាយបញ្ជូនទៅឲ្យយកទុកដាក់ ដើម្បីផ្គត់ផ្គង់ទ័ពកាលៗពីសម័យនុ៎ង។ ខ្ញុំស្គាល់តែឈ្មោះ តាវ៉ាញៗ ហ្នឹង តែក្រៅពី តាវ៉ាញ ហ្នឹងអត់ៗស្គាល់ថា មិនដឹងថាឈ្មោះអីទៀតទេ។ បាទ សូម បានដឹងប៉ុណ្ណឹង។

**ស៖** តើលោកនៅចាំដែរឬទេ ថាតើ តាវ៉ាញ ហ្នឹង<ត្រូវបាន>គេចាប់ខ្លួនគាត់នៅពេលណា?

**ឆ៖** ខ្ញុំអត់ចាំដែរ ព្រោះកាលនៅពីសង្គ្រាមគាត់មិនដឹងថា មុខតួនាទីគាត់បានគ្រប់គ្រងតំបន់២ ហ្នឹងពីឆ្នាំណាមក ក៏អត់ដឹងដែរ ព្រោះតាំងពីសម័យ៧៣មក ៧៣, ៧៤មក ខ្ញុំឃើញគាត់ឡើងជាគណៈតំបន់រួចអស់ហើយ។ ដល់ក្រោយមកឆ្នាំ ក្រោយឆ្នាំ១៩៧៥ មិនដឹងថាគាត់មានតួនាទីអ្វីទេ តែគេឲ្យគាត់មកមើលការខុសត្រូវគ្រប់គ្រងនៅ គេហៅទំនប់កង្ហូត ដំបូងឡើយបាទ មុនគេបង្អស់។

**ស៖** ខ្ញុំក្រែងលោតែលោកស្ដាប់<សំណួរ>ខ្ញុំ<មិន>ច្បាស់ ឬក៏មានការបកប្រែភ័ន្ត។ ខ្ញុំចង់ដឹងថាតើគេចាប់ខ្លួនគាត់នៅពេលណា?

**ឆ៖** ខ្ញុំមិនចាំទេ។

**ស៖** អ៊ីចឹងខ្ញុំសូមរំឭកការចងចាំគឺ ឯកសារ E3/10604 គឺនៅក្នុងបញ្ជី<ស-២១>របស់ការិយាល័យសហាថៅក្រមស៊ើបអង្កេត <លេខរៀង៩១៣ អាយុ៣៦ឆ្នាំ>គឺឈ្មោះ ជា <ហួន> ហៅ វ៉ាញ <លេខាតំបន់១ ភូមិភាគពាយ័ព្យ> គឺចូលដល់ស-២១ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ នៅត្រង់លេខ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

រឿង៩១៣។ ថាតើគេអាចចាប់ខ្លួនគាត់នៅពាក់កណ្ដាលឆ្នាំ១៩៧៧ គឺនៅក្នុងខែមិថុនា តើអាចធ្វើឲ្យលោកចងចាំពីអ្វីដែលកើតឡើងដែរឬទេ?

[០៩:៤០:១០]

**ឆ៖** មិនចាំទេ ព្រោះកាលនុ៎ង ខ្ញុំ៧៦, ៧៧ ហ្នឹងខ្ញុំទៅនៅតំបន់ទន្លេសាបបាត់ហើយ ព្រោះក្នុងជួនកាល១ឆ្នាំអី ខ្ញុំមកបីដងអី ឡើងមក មានការងារនៅក្រុងបាត់ដំបងនេះ អត់ដែលបានដើរទៅណាផងនៅតែទន្លេហ្នឹងរហូត។

**ស៖** នៅក្នុងសក្ខីកម្មម្សិលមិញ លោកឆ្លើយថាតើ ស៊ុម ប្រាប់លោកថា តាវ៉ាញ គាត់បានប្រមូលកងទ័ពដោយខុសច្បាប់ ប៉ុន្តែលោកមិនដឹងថា តាស៊ុម ហ្នឹងបានព័ត៌មានពីណា ហើយមិនដឹងពីរឿងលម្អិតនោះទេ។ អ៊ីចឹងតើលោកដឹងដែរឬទេថា តាវ៉ាញ គាត់ពិតជាបានធ្វើ<>ដូចដែលគេចោទប្រកាន់គាត់ដែរឬទេ?

**ឆ៖** ខ្ញុំបានឮដែលគេចោទប្រកាន់គាត់ គេនិយាយអ៊ីចឹង គេនិយាយថា តាវ៉ាញ ហ្នឹងគឺមានការលាក់អាវុធ ទុកបំពាក់ឲ្យកងចល័ត។ អ៊ីចឹងវាជារឿងខុសច្បាប់ បានជាគេចាប់។ នេះតាមខ្ញុំដឹង ពួកគេនិយាយអ៊ីចឹង តែក្រៅពីហ្នឹងទៀត ខ្ញុំមិនដឹងដែរ។

**ស៖** នៅក្នុងចម្លើយ ឌី.ស៊ី.ខេម គឺឯកសារ E3/10666 គឺ<អង់គ្លេស ERN 01330557> ខ្មែរ ERN 01326340 បាននិយាយពីព័ត៌មានដែលលោកបានឮអំពី តាវ៉ាញ ហើយគេសួរលោកថា៖ "តាមអ្វីដែលលោកចងចាំ តើរឿងរ៉ាវនេះពិតដែរឬទេ រឿងរ៉ាវដែលថាគេ គាត់រៀបចំទ័ពដើម្បីវាយបកមកវិញនោះ? លោកឆ្លើយថា៖ ខ្ញុំមិនដឹងថា អ្វីដែលគេចោទគាត់ហ្នឹងពិត ឬមិនពិតទេ ខ្ញុំមិនដឹងថារឿងហ្នឹងពិត ឬមិនពិតទេ។ <គាត់ត្រូវបានចាប់ខ្លួន។>" អ៊ីចឹងអ្វីដែលលោកឆ្លើយហ្នឹង គឺជាចម្លើយលោកត្រឹមត្រូវអ៊ីចឹង ឬដូចម្ដេច?

**ឆ៖** បាទ ចម្លើយហ្នឹងគឺខ្ញុំនិយាយត្រឹមត្រូវ ព្រោះឮៗតពីគេមក គេបាននិយាយអ៊ីចឹង តែរឿងពិត មិនពិត គឺខ្ញុំមិនដឹង តែក្រោយមកគឺ តាវ៉ាញ ហ្នឹងបានបាត់ខ្លួនមែន បាត់ខ្លួនមួយពេល ៗហ្នឹងមែន។

[០៩:៤៣:០៦]

**ស៖** តើលោកធ្លាប់ឮរឿងរ៉ាវ ដែល<គេនិយាយអំពី> ជា ហ៊ន ហៅ វ៉ាញ <>ដែរទេ នៅពេលដែលគេចាប់ខ្លួនគាត់?

**ឆ៖** បាទ សុំសួរម្ដងទៀត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទមិនថ្វីទេ ខ្ញុំសួរទៅលោកថាតើលោកធ្លាប់ដែលឮគេនិយាយថា ជា ហ៊ាន ហៅ វ៉ាញ នេះនិយាយថាម៉េចដែរទេ នៅពេលដែលគេចាប់ខ្លួនគាត់?

**ឆ៖** បាទ ខ្ញុំអត់ដែលឮ ជា ហ៊ាន ហៅ វ៉ាញ នេះនិយាយយ៉ាងម៉េចទេ ឮតែពីឈ្មោះ តាស៊ុម ហ្នឹងដែលគាត់ប្រាប់ខ្ញុំ ខ្ញុំដឹងតាមគេដែរ។ ផ្ទាល់មាត់ជាមួយគាត់ ខ្ញុំអត់ដែលបានជួបគាត់ទេ តាំងពីរំដោះឆ្នាំ១៩៧៥មក គឺខ្ញុំអត់ដែលបានទៅជួប ឬក៏ទៅប្រាស្រ័យទាក់ទងជាមួយគាត់ អត់ទេ ព្រោះខ្ញុំការងារដោយឡែកផ្សេង។

**ស៖** ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្តាប់ នេះឯកសារ E3/413 ជាកំណត់ហេតុស្តាប់ចម្លើយរបស់ សាឡុត បាន ERN អង់គ្លេស 00361014, ខ្មែរ 00357531, បារាំង 00405456។ គាត់និយាយថា គេបានចាប់មនុស្សយកមកភ្នំពេញ។ សូមដកស្រង់៖ "ប៉ង់ បានប្រាប់គាត់ថាពួកគេនេះគឺយកឲ្យទៅរៀនសូត្រតែប៉ុណ្ណោះ ប៉ុន្តែខ្ញុំ<ឮ>ថាអ្នកដែលគេចាប់ខ្លួនហ្នឹងបានស្រែកថា ជយោ! បក្សកុម្មុយនីស្តកម្ពុជា! ជយោ ប៉ុល ពត! អ្នកដែលស្រែកទាំងនោះ រួមមាន <ហ៊ូ នឹម>, វន វ៉េត, កែ គឹមហួត រួមទាំងគ្រូរបស់ខ្ញុំឈ្មោះ ជា ហ៊ាន នេះផងដែរ។" សូមបញ្ចប់ការដកស្រង់។ តើសម្រង់នេះជួយនឹកដល់ការចងចាំរបស់លោកថា ជា ហ៊ាន ហៅ វ៉ាញ នេះក៏មានស្រែកជយឃោស លើកសរសេរ លើកតម្កើងថា ជយោ! បក្សកុម្មុយនីស្តកម្ពុជាផងដែរ នៅពេលដែលគេចាប់ខ្លួនគាត់?

[០៩:៤៥:៥៥]

**ឆ៖** បាទ ចំណុចហ្នឹងខ្ញុំអត់ដែលបានឮទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំសួរសំណួរពីរបី ខ្លីៗទេ អំពី រស់ ញឹម។ ដំបូង តើលោកអាចជម្រាបជូនតុលាការបានទេ តើអ្នកណាមកជំនួសតំណែង រស់ ញឹម នេះ ក្រោយពេលគេចាប់ខ្លួន រស់ ញឹម ទៅ?

**ឆ៖** កាលហ្នឹងខ្ញុំមិនទាន់ដឹងរចនាសម្ព័ន្ធខាងលើហ្នឹង ចាត់តាំងជំនួសមុខឲ្យ តារស់ ញឹម ហ្នឹង ម៉េចទេ ប៉ុន្តែខ្ញុំឃើញ តាម៉ុក ហើយនិង តាទិត្យ ហ្នឹងទៅនៅខេត្តបាត់ដំបង។ ទៅនៅកន្លែងមន្ទីរសេនាធិការ ទៅនៅកន្លែងដើរទៅតាមតំបន់ តាមអីហ្នឹង តំបន់១, តំបន់២ អីហ្នឹង។

**ស៖** នៅពេលលោកឆ្លើយអំពី រស់ ញឹម ម្សិលមិញ លោកថាលោកបានជួប រស់ ញឹម ផ្ទាល់តែម្តង ពីរបីដង នៅពេលដែលលោកបានចូលរួមវគ្គរៀនសូត្រនយោបាយនៅសាលានយោបាយ។ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ត្រង់ហ្នឹងគឺត្រឹមត្រូវ ព្រោះកាលនុ៎ងគេហៅកម្មាភិបាលក្រសួងមន្ទីរអី ថ្នាក់ក្រោមៗហ្នឹងទៅ ៗរៀនសូត្រនៅសាលានយោបាយ គឺខ្ញុំស្គាល់គាត់។ និយាយរួមទៅ ខ្ញុំធ្លាប់ស្គាល់គាត់តាំងពីដែលមិនទាន់បានរំដោះមុនឆ្នាំ១៩៧៥ តាំងពីនៅក្នុងព្រៃឡើយ។

**ស៖** តើវគ្គរៀនសូត្រនេះ គឺថាគេបើកនៅពេលណាដែរ?

[០៩:៤៨:១៤]

**ឆ៖** កាលនុ៎ងខ្ញុំមិនចាំដែរ ព្រោះរៀនវាច្រើនដងដែរ រៀនម្តងរយៈពេលពីរថ្ងៃ ទៅបីថ្ងៃអី ហ្នឹងបានចប់វគ្គ។

**ស៖** ហើយតើវគ្គរៀនសូត្រនេះ វាកើតឡើងនៅមុនថ្ងៃ១៧ មេសា ៧៥ ឬក៏ក្រោយ១៧ មេសា ៧៥ ឬក៏វគ្គរៀនសូត្រហ្នឹង បើកទាំងមុន ទាំងក្រោយ ១៧ មេសា ៧៥?

**ឆ៖** រៀនហ្នឹងរៀនក្រោយ១៧ មេសា ៧៥ ឆ្នាំៗ ចុងឆ្នាំ៧៥ហ្នឹងបើកវគ្គម្តង ដល់ពាក់កណ្តាលឆ្នាំ៧៦ហ្នឹង ដើមឆ្នាំ៧៦ហ្នឹង ប្រហែលខែ តាមខ្ញុំៗចាំបានខ្លះ ប្រហែលជាខែ២ទៅខែ៣ហ្នឹង គឺបានចូលរៀនម្តងទៀត។

**ស៖** ហើយតើអ្នកណាជាអ្នកឡើងឧទ្ទេសនាមនៅក្នុងវគ្គរៀនសូត្រនេះ?

**ឆ៖** អ្នកដែលឡើងឧទ្ទេសនាមក្នុងការរៀនសូត្រនេះ គឺមានគណៈយោធាភាគហ្នឹងមាន តាខ្លែង, មាន តាកឹ, មាន តាសាន ផង។ ជាពិសេស តាសាន គឺគាត់អ្នកបកស្រាយ អ្នកធ្វើអត្ថាធិប្បាយនៅបញ្ហារៀនសូត្រហ្នឹង។

**ស៖** តើគេបង្រៀនលោកអំពីអ្វីនៅក្នុងវគ្គរៀនសូត្រហ្នឹង? តើគេយកប្រធានបទអ្វីមកបង្រៀនលោក?

[០៩:៥០:២២]

**ឆ៖** កាលនុ៎ង បើតាមខ្ញុំចាំបានខ្លះៗ កាលនោះគេរៀនពង្រឹងពីជំហរនយោបាយ ការធ្វើបដិវត្តន៍សង្គមនិយម។ បាទ គេបង្រៀនអំពីពង្រឹងស្មារតី ប្រឆាំង និងតស៊ូ បំបាត់របបសក្តិភូមិ នាយទុនឲ្យអស់ពី ហើយកសាង កែ ៗខ្លួនឲ្យទៅជាអ្នកធ្វើបដិវត្តន៍ អ្នកដឹកនាំក្នុងជួរបដិវត្តន៍ ក្នុងជួរកងទ័ព។ តាមដែលខ្ញុំក្តាប់បានគឺមានតែប៉ុណ្ណឹង អត់មានអីច្រើន។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលបន្តសួរលោកអំពីសំណួរមួយចំនួន អំពីព័ត៌មានដែលលោកបានជម្រាបជូនតុលាការដែលលោកបានឮពាក់ព័ន្ធទៅនឹងផែនការបះបោរ។ ហើយលោកក៏និយាយម្តង

ទៀតនៅថ្ងៃនេះ ថាលោកឮពីប្រជាជននិយាយ មិនដឹងថាវាពិត ឬមិនពិតនោះទេ។ ម្សិលមិញលោកក៏បានពន្យល់ថា ព័ត៌មានដែលលោកបានដឹង និងអំពីការចោទប្រកាន់ ថាមានផែនការបះបោរនេះ គឺចេញមកពីកម្មាភិបាលភូមិភាគនិរតីក្រោយពីការចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យ។ ខ្ញុំសូមចាប់ផ្ដើមសួរលោក សំណួរខ្លីៗអំពីអង្គភាពនេសាទ កងនេសាទរបស់លោកនេះ ដែលមានការចាប់ខ្លួន មានការបំបែកចេញពីគ្នាផងដែរ។ តើកម្មាភិបាលភូមិភាគនិរតីធ្លាប់ដែលបានចោទប្រកាន់លោក ឬក៏អ្នកណានៅក្នុងកងនេសាទនោះ ពីអ្វីមួយដែរទេ នៅពេលដែលគេចាប់ខ្លួនលោកហ្នឹង ឬក៏នៅពេលដែលគេបំបែកកម្លាំងរបស់លោកនោះ?

[០៩:៥២:៤៧]

**ឆ៖** បាទ ចំណុចនេះ មុនពេលដែលគេចាប់ប្រធានខ្ញុំឈ្មោះ តាស៊ុម ហ្នឹង មុនហ្នឹងគេមាននិរតីគេចូលទៅគ្រប់គ្រង ទៅធ្វើការងារនៅក្នុងអង្គភាពដូចខ្ញុំអ៊ីចឹងដែរ។ គេចោទ គេរាយការណ៍មកភាគនេះ ថាពួកខ្ញុំហ្នឹង យកម៉ាស៊ូត យកត្រីអីទៅចាក់ចោលនៅកណ្ដាលទន្លេ នៅលើទឹក។ វាទៅជាថា ពួកខ្ញុំហ្នឹងមានការបំផ្លិចបំផ្លាញ យករបស់អង្គការថ្នាក់លើហ្នឹងទៅបំផ្លាញចោល មិនគិតពីការអត់ឃ្លានរបស់ទ័ពអី។ អាហ្នឹងគេចោទមួយសា។ ហើយក្រោយមក បានគេចាប់ខ្លួន តាស៊ុម ហ្នឹង។ ក្រោយមកគេចាប់ខ្លួន តាស៊ុម ហ្នឹងហើយចាប់ខ្លួន តាស៊ុម បានហើយហ្នឹង ក៏គេចុះទៅរំលាយ ទៅយកកម្លាំងអ្នកនេសាទ ទាំងអ្នកដឹកនាំ ទាំងក្រុម ទាំងកងអីហ្នឹង ទាំងកម្លាំងនេសាទទាំងអស់ហ្នឹង យកទៅបញ្ជូនទៅដាក់តាមសហ-ករណ៍ហ្នឹង។ ហ្នឹងតាមខ្ញុំដឹងគឺ ឯការបះបោរហ្នឹង វាអត់មានអីបះបោរទេ ហើយការបះបោរហ្នឹងគ្រាន់តែតាមសហករណ៍ខ្លះ វាបះបោរ ដោយសាររត់ចូលព្រៃអី ធ្វើសកម្មភាពបង្កើតខ្មែរស ខ្មែរអីតែប៉ុណ្ណឹងទេ។

**សៈ** បញ្ហាដែលកម្មាភិបាលនិរតីចោទប្រកាន់លោក និងសមាជិកនៃកងនេសាទរបស់លោកនោះ <ថាចាក់ប្រេងទៅក្នុងទឹក> តើលោកពិតជាបានធ្វើនូវអ្វីដូចដែលគេបានចោទប្រកាន់ហ្នឹងមែនឬទេ?

[០៩:៥៤:៥៨]

**ឆ៖** បាទ កាលហ្នឹង អត់ផង។ ជាពិសេសគឺអត់មានទេ មានប្រជាពលរដ្ឋរស់នៅក្នុងហ្នឹង គឺគេដឹងឮ។ ចុះការងារអីធ្វើ ដឹកម៉ាស៊ូត ដឹកប្រហុក ត្រីសាច់អីទៅ មិនដែលមានត្រីសាច់ឯណាទៅចាក់ចោល រកតែប្រេងចាក់ទូកម៉ាស៊ីនបើកបរអូសត្រី អូសអួនក្នុងទន្លេហ្នឹង សឹងតែខ្វះខាតផង ហើយមានម៉ាស៊ូតឯណាទៅចាក់ចោល។ អ៊ីចឹងគេស៊ើបសួរតាមរយៈប្រជាពលរដ្ឋនៅក្នុងអង្គភាព ក្នុងជួរសេដ្ឋកិច្ច

ហ្នឹង ក៏គេសួរដែរ ប៉ុន្តែដល់នេះទៅគេ ក្រោយមកក៏គេមិនជឿទេ ប្រហែលជាគេមិនជឿទេ បានគេទៅចាប់ តាស៊ុម។ កាលនុ៎ង ហៅ តាហ៊ុម មកផ្សារលើហ្នឹង ក៏ចាប់នឹងផ្សារលើតែម្តងទៅ។ ហើយបន្ទាប់មក គេយកពួកខ្ញុំហ្នឹង បំបែកពួកខ្ញុំហ្នឹងដាក់តាមសហករណ៍អស់ អត់មាននៅកន្លែងដដែលហ្នឹងទៀតទេ។ ទូកកាណូតអី យកផែ ធ្វើផែធ្វើអីនៅតាមហ្នឹង គឺទុកចោលទៅ ទាំងរបស់របរអី យកមិនទាន់អីទុកចោលនៅកន្លែងហ្នឹងទាំងអស់ ទាំងគ្រឿងម៉ាស៊ីន គ្រឿងអីហ្នឹង។ ខ្ញុំយកតែម៉ាស៊ីនកាណូតធំៗហ្នឹងដាក់អូសប្រជាពលរដ្ឋឡើងមក ពីរបីខ្សែតាមដងស្ទឹង មកដល់បាត់ដំបងហ្នឹង បានបែកជួរគ្នា។ ខ្លះដាក់នៅនឹង គេហៅសាលាតាអនហ្នឹង ខ្លះក៏អូសឡើងមកដល់បាត់ដំបងណោះ។

**ស៖** តើលោកដឹងទេ ហេតុអ្វីបានជាកម្មាភិបាលភូមិភាគនិរតីចោទប្រកាន់លោកធ្វើអ្វីមួយ ដែលតាមពិតទៅ លោកមិនបានធ្វើសោះ តែគេចោទប្រកាន់?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ នេះគឺថាការសួរឲ្យសាក្សីឆ្លើយដោយស្មានៗហើយ។ គាត់មិនដឹងទេ ថាក្នុងចំណោមកម្មាភិបាលភូមិភាគនិរតីហ្នឹង អ្នកណានិយាយច្បាស់លាស់ផង។ <មិនដឹងថា តើការពិតនោះគេបានរកឃើញប្រេង ឬក៏អត់ទេ។ ដូច្នេះ សំណួរនេះជាការសួរឲ្យសាក្សីឆ្លើយដោយស្មានៗ។>

[០៩:៥៧:០៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សួរ គ្រាន់តែសួរ ថាលោកដឹង ឬក៏អត់នោះទេ។ បើសាក្សីដឹង ឆ្លើយថាដឹង មិនដឹង ក៏ឆ្លើយមិនដឹងទៅ ឬក៏លោកសហព្រះរាជអាជ្ញារងរៀបសំណួរឡើងវិញ។

**សួរដោយលោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

**ស៖** លោកសាក្សី ខ្ញុំរៀបសំណួរខ្ញុំឡើងវិញ។ តើលោកដឹងទេ ថាហេតុអ្វីបានជាកម្មាភិបាលភូមិភាគនិរតីចោទប្រកាន់លោក និងសមាជិកនៅក្នុងកងនេសាទរបស់លោក នូវអ្វីដែលក្រុមរបស់លោកមិនបានធ្វើ?

**2-TCW-1037៖**

**ឆ៖** បាទ កាលហ្នឹងខ្ញុំថា មានអ្នកធ្វើការមកពីខាងនិរតីហ្នឹង គេចុះធ្វើការនៅក្នុងអង្គភាពខ្ញុំដែរ។ អីចឹងប្រហែលជាគេរាយការណ៍មកថ្នាក់លើ មិនដឹងដែរទេ បានជាគេចោទពីបញ្ហាហ្នឹង។ គឺចោទនេះ គឺចោទសម្លាប់ទេ។ អត់មានហេតុផលជាក់ស្តែង អ្នកណាដែលហ៊ានទៅធ្វើអីចឹង។

**ស៖** តើមានកម្មាភិបាលភូមិភាគនិរតីណាម្នាក់ប្រាប់លោកថា អ្នកណាដែលបង្គាប់ឲ្យគាត់ទៅភូមិភាគពាយ័ព្យ? ហើយហេតុអីបានជាពួកកម្មាភិបាលនិរតីទាំងនោះហ្នឹង គាត់មានវត្តមាននៅឯភូមិភាគពាយ័ព្យដែរឬទេ?

**ឆ៖** បាទ ចំណុចហ្នឹង ខ្ញុំមិនដឹងពីទិសដៅខាងលើដែរ ព្រោះឃើញថា គាត់ទៅហ្នឹង គាត់បានទៅសុំរស់នៅជួយធ្វើការងារ នៅហ្នឹង ព្រោះខាងថ្នាក់លើ គេសុំផ្ញើមនុស្សទៅតាមមន្ទីរ តាមអង្គភាពមួយៗហ្នឹង។ សឹងតែគ្រប់កន្លែងអ៊ីចឹង។

[០៩:៥៩:១៨]

**ស៖** ខ្ញុំសូមអានសម្រង់មួយ ពីកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/9580។ ត្រង់ចម្លើយលេខ៣៦៖ "សួរ៖ នៅពេលក្រុមនិរតីទៅដល់ពាយ័ព្យ តើគេដែលប្រកាសនៅក្នុងអង្គប្រជុំថាពួកគេទៅត្រួតត្រាភូមិភាគនោះទាំងមូលតែម្តងឬទេ? ឆ្លើយ៖ នៅក្នុងពេលប្រជុំ ពួកគេមិនដែលនិយាយថា ពួកគេមកពីនិរតីទេ។ គេគ្រាន់តែប្រាប់ថាថ្នាក់លើចាត់តាំងឲ្យពួកគេមកត្រួតត្រានៅភូមិភាគពាយ័ព្យ ប៉ុន្តែយើងដឹងរឿងនេះ យើងដឹងតែតាមរយៈពាក្យចចាមអារាមតែប៉ុណ្ណោះ។" តើលោកមានដែលស្តាប់ឮកម្មាភិបាលភូមិភាគនិរតីឡើងនិយាយក្នុងអង្គប្រជុំថា អង្គការទេ ជាអ្នកឲ្យពួកគាត់ទៅភូមិភាគពាយ័ព្យនោះដែរឬទេ?

**ឆ៖** បាទ ចំណុចហ្នឹងខ្ញុំអត់ដែលឮទេ តែអ្នកដែលទៅៗរស់នៅជាមួយគ្នាហ្នឹង ធ្វើការជាមួយគ្នាហ្នឹង គេបានថា ខ្ញុំមកសុំរស់នៅជាមួយអង្គភាពនេសាទ ជួយៗធ្វើការហ្នឹង ព្រោះអង្គការថ្នាក់លើបានឲ្យខ្ញុំមកជួយដល់អង្គភាពសមមិត្ត។ អ៊ីចឹង! អាហ្នឹងគេសម័យហ្នឹង គេនិយាយអ៊ីចឹង។

**ស៖** តើពិតឬទេ ដែលថាពេលខ្លះនោះលោកបានចូលរួមប្រជុំ នៅពេលដែលកម្មាភិបាលភូមិភាគនិរតី គេឡើងបើកអង្គប្រជុំ ហើយផ្តល់ព័ត៌មានផ្សេងៗ?

**ឆ៖** បាទ ចំណុចហ្នឹង គេមិនដែលកោះហៅប្រជុំទេ។ នេះគេគ្រាន់តែចុះមកហ្នឹង គេបានហៅពីរបីនាក់ អង្គភាពធ្វើការងារហ្នឹង នៅក្នុងអង្គភាពសេដ្ឋកិច្ចហ្នឹង មានពីរនាក់ហ្នឹង គេហៅមក គេធ្វើការពិភាក្សាគ្នាថា គេគ្រាន់តែសុំផ្ញើខ្លួន និងធ្វើការនៅជាមួយនឹង មានការងារអី ខុសត្រូវអី យើងជួយកែលម្អគ្នាទៅវិញទៅមក។ តាមខ្ញុំដឹង គឺមានតែប៉ុណ្ណឹង តែផែនការប្រជុំពីរទិស ពីខាងលើមក គឺខ្ញុំអត់ដែលបានទទួលផែនការហ្នឹងពីខាងលើទេ។

[១០:០១:៥០]

**ស៖** តើនៅពេលដែលលោកនៅកងនេសាទហ្នឹង តើលោកធ្លាប់បានចូលរួមប្រជុំណាមួយដែរឬទេ នៅពេលដែលលោកត្រូវបានគេបញ្ជូនទៅសាលាតាអាន នៅឃុំសាលាតាអាន -- ឃុំសាលាតាអន គឺអង្គប្រជុំដែលបើកឡើងដោយកម្មាភិបាលភូមិភាគនិរតីនោះណា?

**ឆ៖** បាទ កាលហ្នឹងខ្ញុំ គេមិនដែលហៅទៅប្រជុំឯណាទេ បើប្រជុំក្នុងកងតូច មាន។ ប្រជុំពីរឿងការស៊ីចុក ពីរឿងការធ្វើការងារ មែន។ គឺប្រជុំកាលហ្នឹង គឺប្រជុំឲ្យមានស៊ីបបរហ្នឹង ឲ្យពូជួង អាហ្នឹងគេប្រជុំក្នុងកងណា។ ឲ្យពូជួង រហ័សមក ហើយអត់ឲ្យយកបបរលាក់លៀមអីទៅផ្ទះ ទៅកន្លែងស្នាក់នៅហ្នឹងទេ។ ហើយនិងគេប្រជុំឲ្យយើងចេញធ្វើការទាន់ម៉ោង ទាន់ពេលវេលា កុំខ្ជិល កុំច្រអូស កុំពុត កុំទម្រន់អីចឹង។ អានេះជា១គោលការណ៍របស់គេ គឺអីចឹង។

**ស៖** ខ្ញុំសូមអានសម្រង់មួយឲ្យលោកស្ដាប់ គឺសម្រង់ដែលលោកបានឆ្លើយជូនចៅក្រមស៊ើបអង្កេត គឺE3/9580។ នៅត្រង់សំណួរចម្លើយ៣៧ លោកឆ្លើយថា៖ “ក្រោយពីចាប់ក្រុមពាយ័ព្យ តើគេដែលបើកអង្គប្រជុំប្រកាសថា ហេតុអីបានជាគេចាប់ពួកពាយ័ព្យ? ឆ្លើយ៖ ខ្ញុំធ្លាប់បានចូលរួមប្រជុំជាមួយនឹងប្រធានសហករណ៍<សាលាតាអន ឈ្មោះ> តាអ៊ឹម <គាត់មកពីនិរតី>។ តាអ៊ឹម គាត់និយាយថា ពួកក្បាលម៉ាស៊ីនពាយ័ព្យក្បត់អង្គការ និងប្រជាជន។ ដូច្នេះគាត់មកដើម្បីរៀបរួមគ្នា និងអភិវឌ្ឍន៍សហករណ៍ឡើងវិញ។ ពួកមុន គឺពួកក្បត់នឹងអង្គការ ហើយខាងអង្គការធ្វើការបោសសម្អាតពួកនេះរួចហើយ។” បញ្ចប់ការដកស្រង់។ តើចំណុចនេះ ជួយរំឭកដល់ការចងចាំរបស់លោកទេ ថាលោកបានចូលរួមនៅក្នុងអង្គប្រជុំបែបនេះ លោកបានទទួលព័ត៌មានថា ហេតុអ្វីបានជាកម្មាភិបាលភូមិភាគពាយ័ព្យនោះ ត្រូវបានគេបោសសម្អាតនោះ?

[១០:០៤:១៨]

**ឆ៖** បាទកាលនុ៎ងគឺខ្ញុំទៅដល់ដំបូង។ ទៅដល់ដំបូងហ្នឹង គេឲ្យខាងប្រជាជនដែលបានទៅនៅនឹងសហករណ៍សាលាតាអនហ្នឹង មានប៉ុន្មានគ្រួសារហ្នឹង ហើយនិងបូកនឹងជាមួយប្រជាជនសហករណ៍ចាស់ដែលគេនៅពីមុនមកហ្នឹង តាអ៊ឹម គាត់ចុះទៅគ្រប់គ្រងសហករណ៍ហ្នឹង កាលហ្នឹងគឺដំបូង គេបានហៅប្រជាពលរដ្ឋទៅប្រជុំ។ ប្រជាពលរដ្ឋទៅប្រជុំហ្នឹង គេនិយាយអីចឹងមែន។ គេនិយាយថា ហេតុអីបានជាអង្គភាពនេសាទហ្នឹង មករស់នៅកន្លែងនេះ។ គេថា មកពីថ្នាក់ដឹកនាំហ្នឹងក្បត់។ ក្បត់ បានជាខាងលើហ្នឹងគេចាប់។ ឥឡូវហ្នឹងពួកគាត់មកហ្នឹងដើម្បីរៀបចំពង្រឹង ឲ្យបានរឹងមាំឡើងវិញ។ នេះតាមដែលខ្ញុំឮ ខ្ញុំបានទៅចូលរួមប្រជុំដំបូង។ ដល់ក្រោយមកគ្រាន់តែប្រជុំតាមកងតូចនៅក្នុងការដ្ឋាននីមួយៗ

ទេ ប្រជុំពីការងារពលកម្មអីប៉ុណ្ណឹង។

**ស៖** ខ្ញុំសូមអានសម្រង់មួយចំនួនឲ្យលោកស្តាប់ចេញពីចម្លើយដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ ឯកសារទី១គឺ E3/10666 ERN អង់គ្លេស 01330560, ខ្មែរ 01326341។ សូមដកស្រង់៖ "សួរ៖ តើគេប្រកាសអំពីការត្រួតត្រាដោយ តាម៉ុក របៀបម៉េច? គេប្រកាសថា មេភូមិភាគហ្នឹងបានក្បត់អង្គការ គឺមេ<>នេះ<ឬមេនោះ>ក្បត់ អ៊ីចឹងគេចាត់តាំងឲ្យឈ្មោះទាំងអស់ឲ្យគ្រប់គ្រងនៅតាមតំបន់ទាំងអស់ និងស្រុកទាំងអស់។" បញ្ចប់ការដកស្រង់។

សម្រង់បន្ទាប់មកទៀត គឺអង់គ្លេស 01330541, ខ្មែរ 01326330។ សូមដកស្រង់ នេះលោកជាសម្តីរបស់លោក៖ "<ខ្ញុំមិនខ្វះច្រើនទេ។ ការខ្វះខាតបានកើត>ឡើង។ នៅពេលដែលកម្មាភិបាលនិរតីទៅដល់ គេបានរំលាយកងរបស់ខ្ញុំ។ គេនិយាយថា តាញឹម, តាខ្លែង ហើយនិង តារិន ទាំងអស់ហ្នឹងគឺសុទ្ធតែអាពួកក្បត់។" បញ្ចប់ការដកស្រង់។ នៅពេលលោកប្រើពាក្យថា "ពួកគេ" តើ<លោកចង់និយាយពីប្រភេទអង្គប្រជុំដែល>កម្មាភិបាលភូមិភាគនិរតី<>ប្រាប់លោកអំពីមូលហេតុនៃការចាប់ខ្លួនអ្នកទាំងនេះ<ឬ>?

[១០:០៧:៤១]

**ឆ៖** បាទ ចំណុចហ្នឹងគេ មូលហេតុដែលគេចាប់ហ្នឹងគេថាពួកក្បត់ ពួកខ្សែរយៈក្បត់ពី១១ធំមកតូច គឺគេបោសសម្អាតទៅតាមអង្គភាពមួយៗអ៊ីចឹង នេះតាមឮៗនិរតីគេនិយាយអ៊ីចឹង។

**ស៖** តើពួកគេមានបានប្រាប់លោកថា បុគ្គលដែលមកពីភូមិភាគ<និរតី>នេះ គឺថាជាភ្នាក់ងារសេ.អ៊ី.អា ជាតិញ<វៀតណាម>នោះដែរឬទេ?

**ឆ៖** ត្រង់ចំណុចហ្នឹងខ្ញុំធ្លាប់ឮ ខាងនិរតីគេនិយាយ គេថាៗ ភូមិភាគពាយ័ព្យហ្នឹងសុទ្ធតែពួកសេ.អ៊ី.អា ពួកគិញបង្កប់អី ធ្វើការបម្រើសក្តិភូមិអ៊ីចឹង អានេះតាមខ្ញុំឮ ធ្លាប់ឮគេនិយាយអ៊ីចឹងមែន។ ហើយខ្ញុំមិនដែលទៅសាកសួរគេទេ គ្រាន់តែឮៗកត់ទុកក្នុងខួរក្បាលខ្ញុំ ហើយខ្ញុំក៏មិនហ៊ានទៅសាកសួរឬដេញដោលដែរ ព្រោះកាលនុ៎ងគេៗរកដែរ គេរកមុខថា អ្នកណាមួយជាអង្គភាពជាមួយ តាស៊ុម តែសំណាងខ្ញុំដែលៗខ្ញុំធ្វើអំពើល្អ មិនដែលមានសកម្មភាពអីអាក្រក់ទៅលើប្រជាពលរដ្ឋ ទៅលើសមាជិកទាំងអស់ហ្នឹងទេ គឺគេជួយការពារ គេជួយលាក់លៀម ប្រាប់ពួកនិរតីនោះថា អង្គភាព តាស៊ុម ហ្នឹងគេចាប់អស់ហើយ អត់មានសល់ទេ អត់មាននៅកន្លែងហ្នឹងទេ។ ពេលហ្នឹងគឺខ្ញុំនៅតែប្រាំមួយ, ប្រាំពីរ, ប្រាំបីគ្រួសារទេដែលនៅនឹងសាលាតាអនហ្នឹង។ គឺប្រជាពលរដ្ឋដែលរស់នៅជាមួយគ្នា និងប្រជាពលរដ្ឋ

ដែលធ្លាប់ស្គាល់ខ្ញុំឡើងចុះនៅក្នុងសាលាតាអនហ្នឹង ក៏ជាជួយលាក់បាំងដែរ។ កាលហ្នឹងបើគេរកមុខដែរ បើសិនជា គេបង្ហាញថាខ្ញុំហ្នឹងជាអង្គភាព អនុប្រធាន តាស៊ុម អីប្រហែលជាអត់មានមុខមកថ្ងៃនេះដែរហ្នឹង។

**ស៖** មួយសំណួរបន្តទៅទៀត។ <ហេតុអ្វីបានជា>លោក<និយាយ>ថា បើសិនណាជា មានគេប្រាប់ទៅថាលោកហ្នឹងគឺជាអនុ<ប្រធានខាងនេសាទ>ហ្នឹង ប្រហែល<លោក>ជាគ្មានមុខមកនៅចំពោះមុខតុលាការថ្ងៃនេះទេ ហេតុអី?

[១០:១០:៤៥]

**ឆ៖** បាទ ហេតុអី ខ្ញុំជឿជាក់ថា បើដឹងថាគេរកៗមុខអនុប្រធានហ្នឹង ប្រហែលជាៗគេចាប់ខ្ញុំ ឬក៏គេយកទៅលត់ដំ បង្អត់បាយ បង្អត់ទឹកក៏មិនដឹង ធ្វើបាបយ៉ាងម៉េច មើលមិនឃើញដែរ ព្រោះសកម្មភាព គេថាយើងអ្នកក្បត់ទៅហើយ អាហ្នឹងស្រេចនឹងគេទេ គេយកទៅកន្លែងណាវាជារឿងរបស់អង្គការគេហ្នឹង។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលើ៖**

លោកប្រធាន ខ្ញុំត្រូវទៅប្រធានបទមួយផ្សេងទៀត។ តើគួរឈប់សម្រាកសិន ឬយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣១ នាទី)*

[១០:៣១:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយផ្តល់វេទិកាជូនទៅសហព្រះ

រាជអាជ្ញារងអន្តរជាតិដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ ហើយសូមបញ្ជាក់ថាសហព្រះរាជអាជ្ញារង -- សហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេល៤០នាទីទៀតក្នុងការសួរដេញដោលសាក្សីរូបនេះ។

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី ឥឡូវនេះខ្ញុំចង់សួរលោកនូវសំណួរមួយចំនួនអំពីខ្មែរស។ អំពីចលនាខ្មែរស លោកក៏បានបញ្ជាក់ប្រាប់តុលាការម្សិលមិញផងដែរ ហើយថ្ងៃនេះ ក៏លោកបានបញ្ជាក់ ហើយម្សិលមិញ លោកបញ្ជាក់ថាអ្វីដែលលោកយល់នោះ គឺថាកម្មាភិបាលភូមិភាគពាយ័ព្យ ហើយនិងពួក១៧មេសា <ដែល>បានរត់គេចខ្លួន នៅពេលដែលកម្មាភិបាលនិរតីចូលមកដល់ ហើយពួកអ្នកទាំងនោះដែលរត់នោះ ក៏គាត់បានបង្កើតចលនាខ្មែរស។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ តាមដែលខ្ញុំយល់ដឹងពីលោកនោះ?

**2-TCW-1037៖**

**ឆ៖** បាទ រឿងហ្នឹងពិតអ៊ីចឹងមែន។

**ស៖** សូមលោកប្រាប់តុលាការ ថាតើលោកដឹងព័ត៌មាននេះដោយរបៀបណាដែលថាបុគ្គលទាំងនោះដែលរត់ចេញទៅនោះ បង្កើតជាចលនានោះ?

[១០:៣៣:៣៧]

**ឆ៖** បាទ ខ្ញុំដឹងព័ត៌មាននេះ គឺដឹងពីបងប្អូននៅក្នុងភូមិឃុំខ្ញុំហ្នឹង គេថាកាលហ្នឹងអ្នកមួយចំនួនថ្នាក់វរសេនាតូច វរសេនាធំក្នុងសហករណ៍ មិនមែននេះទេ គេបានរត់ចេញទៅបង្កើតចលនាខ្មែរសហ្នឹងមកលួច មកប្លន់យកស្បៀង យកអង្ករហ្នឹងតាមកន្លែងមួយៗហ្នឹង យកទៅទុកដាក់ ហើយនិងជួបបង្កើតកម្លាំងប្រដាប់អាវុធ ប្អូនដប់នាក់អ៊ីចឹងដើរធ្វើសកម្មភាព រកមុខពួកក្រុមនិរតីដែលបានចុះទៅនៅតាមសហករណ៍ហ្នឹង។

**ស៖** ខ្ញុំនឹងអានសម្រង់ចេញពីចម្លើយរបស់លោកក្នុងកំណត់ហេតុគឺឯកសារ E3/9580 គឺសំណួរចម្លើយ១២៖ "ខ្ញុំដឹងថានៅក្នុងពេលដែលមានភាពវឹកវរ គឺកម្មាភិបាលភូមិភាគពាយ័ព្យខ្លះបានរត់ចូលព្រៃ ហើយអ្នកខ្លះត្រូវបានគេចាប់ខ្លួន។" ហើយនៅក្នុងសំណួរចម្លើយ១៣៖ "ហើយអ្នកដែលរត់ចូលក្នុងព្រៃនោះ គឺបានបង្កើតចលនាខ្មែរស។" ចប់សេចក្តីដកស្រង់។ សូមលោកប្រាប់តុលាការថា នៅពេលណាដែលចលនាខ្មែរសនោះបង្កើតនៅក្នុងខែ ឆ្នាំណា? តាមដែលលោកដឹង ឬក៏ចាំ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** តាមខ្ញុំចាំ ឆ្នាំ១៩៧៨។

**ស៖** តើលោកដឹងថាតើមានមនុស្សប៉ុន្មាននាក់ដែលរួមគ្នាបង្កើតចលនាខ្មែរស?

**ឆ៖** តាមខ្ញុំដឹងមានតិចតួចទេ មិនមានច្រើនទេ មានពីរបីនាក់ដឹកនាំកសាងកម្លាំងហ្នឹង តែឥឡូវហ្នឹងអ្នកដែលដឹកនាំហ្នឹង គាត់បានស្លាប់ហើយ។

**ស៖** តើលោកដឹងឬទេថា ពួកគាត់មានអាវុធ មានកាំភ្លើងឬក៏មានឡានធំ ឡានតូចអ្វីដែរឬទេ? ក្នុងករណីដែលពួកគាត់មាននោះ តើគាត់មានអាវុធ ឬក៏យានយន្តប្រភេទអ្វីខ្លះដែរ?

**ឆ៖** គ្មានអីធំដុំទេ គ្មានយានយន្ត គ្មានអាវុធទំនើបអីទេ មានតែកាំភ្លើងអា.កា កាំភ្លើង សេ.កា.សេ និងធម្មតា។

[១០:៣៧:១៥]

**ស៖** តើលោកដឹងដែរឬទេ ថាតើអាកា-៤៧ ឬក៏អាវុធវែង កាំភ្លើងហ្នឹង លោកដឹងថាមានចំនួនប្រហែលប៉ុន្មានទេ ចលនាហ្នឹងគេមានហ្នឹង?

**ឆ៖** ខ្ញុំអត់បានក្តាប់បានដែរ ប៉ុន្តែខ្ញុំដឹងថា មានអាវុធអា.កា និងសេ.កា.សេហ្នឹង មានពីរប្រភេទហ្នឹងដែលខ្ញុំដឹង។

**ស៖** តើលោកដឹងថា មានអាវុធ អា.កា ឬក៏ សេ.កា.សេ ហ្នឹងមានប៉ុន្មានដើមដែរឬទេ?

**ឆ៖** បាទ អត់ដឹងចំនួនទេ អត់ដឹងចំនួនដើមទេ។

**ស៖** តើលោកដឹងទេថា ខ្មែរសហ្នឹងគឺមានអ្នកណាជាប្រធាន ជាមេដឹកនាំរបស់គេ?

**ឆ៖** បាទ ខ្ញុំមិនដឹងប្រធានឈ្មោះណាមួយទេ ដឹកនាំ តែខ្ញុំគ្រាន់តែស្គាល់មនុស្សម្នាក់ តែគាត់បានខូចហើយ។ ក្រោយពេលដែលវៀតណាមចូលទៅដល់បាត់ដំបងហ្នឹង វ៉ៃយករំដោះ យកប្រជាពលរដ្ឋមកចូល មកពីព្រៃពីអីមកហ្នឹង ពួកហ្នឹងក៏បានប្រមូលអាវុធ ទម្លាក់អាវុធហ្នឹងមកចូលរួមជាមួយវៀតណាមហ្នឹងអស់ អត់មាននៅធ្វើការតស៊ូអីតទៀតទេ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ ខ្ញុំចង់សួរលោក ថាតើលោកដឹងអ្នកណាម្នាក់ដែល<>ជាជនជាតិវៀតណាម នៅក្នុងភូមិភាគពាយ័ព្យ<> ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥<ដែរឬទេ>?

[១០:៣៩:៤៥]

**ឆ៖** បាទ ខ្ញុំដឹងកាលនុ៎ង គឺដឹងជនជាតិវៀតណាមដែលធ្លាប់រស់នៅតាំងពីសង្គមចាស់មក ពីមុន

មក គឺរស់នៅកន្លែងខ្ញុំហ្នឹង គឺមានប្រាំ ប្រាំមួយគ្រួសារដែរ ដែលគេអត់បានបញ្ជូន នៅឆ្នាំ១៩៧៥ហ្នឹង គេអត់បានបញ្ជូនទៅទេ ដោយមូលហេតុថាគាត់ ប្រពន្ធជាវៀតណាម ប្ដីជាកម្ពុជា ជាខ្មែរអ៊ីចឹងគឺជាប់ជាប់ខ្មែរផង វៀតណាមផង អត់បានបញ្ជូនទេ។ អ៊ីចឹងគេទុកឲ្យនៅហ្នឹង ក្រៅពីហ្នឹងគេបញ្ជូនដាក់ទូកឡើងទៅវៀតណាមអស់។ បញ្ជូនទៅច្រើន កាលឆ្នាំ១៩៧៥ បញ្ជូនវៀតណាមទៅច្រើនណាស់ តាមទន្លេសាប បញ្ជូនចេញមកភ្នំពេញហ្នឹង។ ដឹកៗទាំងកាណូត ទាំងទូកហ្នឹងមក ហើយនៅសល់ ដូចខ្ញុំថាអ៊ីចឹងសល់តែអ្នកដែលប្ដីវៀតណាម ប្រពន្ធខ្មែរ, ប្ដីខ្មែរ ប្រពន្ធវៀតណាមអ៊ីចឹង អាហ្នឹងគឺអត់យកទៅណាទេ។ ប៉ុន្តែដល់មកក្រោយមក ដែលវឹកវរ បះបោរខ្លាំងហ្នឹង ដែលច្របូកច្របល់ចាប់ពាយ័ព្យ កម្មាភិបាលមួយចំនួនត្រូវគេចាប់ ខ្លះរត់ចូលព្រៃគេចខ្លួនអីតាមសហករណ៍តាមអីហ្នឹង ពេលហ្នឹងគឺនិរតីចុះទៅដល់ គេបោសសម្អាត។ ពួកខ្ញុំដែលនៅតាមទន្លេហ្នឹង គឺមានសាច់ញាតិជាប់វៀតណាម វៀតអី គេយកទៅសម្លាប់ចោល។ អត់មានសល់ទេ។ តាមខ្ញុំដឹង កាលហ្នឹងគឺអ៊ីចឹងមែន។

**ស៖** ចំពោះក្រុមគ្រួសារជនជាតិវៀតណាមដែលគេបញ្ជូនតាមទូក តើលោកដឹងថាគេបញ្ជូនចេញហ្នឹងក្នុងខែ ឆ្នាំណា? បើសិនជាមិនចាំឆ្នាំជាក់លាក់ តើរយៈពេលភ្លាមៗ បន្ទាប់ពីឆ្នាំ១៩៧៥ ខែមេសា ឬក៏យូរបន្ទាប់ពីនោះ?

**ឆ៖** បាទកាលហ្នឹងបន្ទាប់ពីខែមេសាមក តែនៅក្នុងឆ្នាំ១៩៧៥ហ្នឹង តែមិនមែននៅក្នុងខែមេសាហ្នឹងទេ យកៗផុតពីខែមេសា ប្រហែលជាចូលខែ៧ ខែ៨អីហ្នឹង។

[១០:៤២:៣៥]

**ស៖** តើលោកដឹងដែរឬទេ ថាតើគេរៀបចំដូចម្ដេច ដើម្បីរៀបចំជនជាតិវៀតណាមដឹកតាមទូកចេញហ្នឹង? ថាតើគេ<មាន>ប្រកាស<ទេ>? <តើមានអ្នកទៅប្រាប់ពួកគេទេ?> ថាតើគេ<រៀបចំ>ឲ្យជនជាតិវៀតណាមទាំងអស់នោះ ចាកចេញ ហើយធ្វើដំណើរតាមទូក<>មកភ្នំពេញកាលណោះនោះ<ដោយរបៀបណា>?

**ឆ៖** កាលនោះគេចាត់តាំងមនុស្សរបស់គេហ្នឹង ដើម្បីដើរស្រង់ ដើរប្រមូល នៅតាមស្រុកភូមិហ្នឹង ឲ្យបញ្ជូនមកស្រុកវៀតណាមវិញ។

**ស៖** តើលោកដឹងដែរឬទេ ថាតើគេអាចកំណត់អត្តសញ្ញាណថាតើអ្នកទាំងនោះជាជនជាតិវៀតណាមហ្នឹង គេកំណត់អត្តសញ្ញាណផ្អែកលើអ្វីខ្លះដែរ?

**ឆ៖** ខ្ញុំអត់ដឹងថា គេកំណត់យ៉ាងម៉េចដែរ។ គេគ្រាន់តែថា និយាយខ្មែរមិនច្បាស់ ប៉ែឡាំៗហ្នឹង

01386940



គឺគេសម្គាល់ថា ជនជាតិវៀតណាម ព្រោះគេបានសួរ សួរជនជាតិហ្នឹងផ្ទាល់ គេថាគេជាកូនវៀតណាម អីមករស់នៅលើទឹកដីកម្ពុជាហ្នឹង យូរហើយ។ អ្នកខ្លះមកកើតនៅនឹងស្រុកខ្មែរ អ្នកខ្លះកើតពីវៀតណាម មក ក៏មាន។

**ស៖** លោកបានបញ្ជាក់ពីបុគ្គលមួយចំនួនក្នុងកងនេសាទ ថាមានបងប្អូន<ជាជនជាតិ>វៀត-ណាម<ហើយ>ពួកគាត់ត្រូវបានគេយកទៅសម្លាប់។ <ហើយលោកក៏បញ្ជាក់ដែរថា>ពីដំបូងហ្នឹង គឺថាយ៉ាងហោចណាស់ បុគ្គលទាំងនោះដែលមានប្រពន្ធ ឬក៏ប្ដីជាវៀតណាម គេមិនទាន់បានបញ្ជូនទៅវៀតណាមទេ។ អ៊ីចឹងសួរថាតើ<មានអ្វីកើតឡើងចំពោះ>អ្នកដែលមានប្ដី ឬប្រពន្ធជាវៀតណាមដែលនៅស្រុកខ្មែរនៅឡើយហ្នឹង<>?

[១០:៤៥:០៥]

**ឆ៖** ក្រោយមកកាលនុ៎ង គេមិនឲ្យជាប់សញ្ជាតិវៀតណាមអីទេ ទោះបីប្ដីខ្មែរក៏ដោយ ប្រពន្ធខ្មែរក៏ដោយ ពេលហ្នឹងគេត្រូវតែបោសសម្អាត គឺខាងកម្លាំងទ័ពរបស់និរតី គេចុះៗធ្វើអន្តរាគមន៍ គេបោសសម្អាត។ ចាប់ដាក់កាណូត យកទៅសម្លាប់ចោលតាមដងទន្លេសាបហ្នឹងអស់ច្រើនគ្រួសារ។

**ស៖** តើលោកនៅចាំទេ ដោយជាក់លាក់តើហេតុការណ៍ហ្នឹងកើតនៅក្នុងខែឆ្នាំណាដែរ?

**ឆ៖** តាមខ្ញុំក្ដាប់បាន ហេតុការណ៍ហ្នឹងកើតនៅឆ្នាំ១៩៧៨ ចុងក្រោយបង្អស់ហ្នឹងឆ្នាំ១៩៧៨ តែខែ ខ្ញុំអត់ចាំ។ កាលនុ៎ងគឺយើងខែទឹកទន្លេឡើងហើយ ប្រហែលជាខែ៧ ខែ៨ដឹង ខែទឹកជំនន់ទន្លេសាបយើងហ្នឹងឡើងពេញព្រៃអស់ហើយ លិចដី លិចព្រៃអស់ច្រើន។

**ស៖** តើមានអ្នកណាធ្លាប់ប្រាប់លោកដែរឬទេ ពីមូលហេតុថា <>ជនជាតិជាវៀតណាមហ្នឹងត្រូវបានគេបញ្ជូនចេញ ហើយ<ក្រោយមកត្រូវបាន>គេយកទៅសម្លាប់នោះ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញនឹងមុខ។ ខ្ញុំលាក់គាត់មួយ ឡើងមកតាមពួកខ្ញុំហ្នឹង មកដល់យើង គេហៅចំណុចអូរព្រែកក្រូច -- អូរកាច់រទេះ។ មកដល់កន្លែងហ្នឹង ខ្ញុំរស់នៅហ្នឹងបណ្ដោះអាសន្នរយៈពេលបួនប្រាំថ្ងៃ។ គេតាមទៀត ពួកកម្លាំងទ័ពហ្នឹងគេបើ ៗកាណូតទៅហ្នឹង គេចូលទៅដល់កន្លែងហ្នឹង គេស្រាវជ្រាវ គេសួររក។ គេថា បើលាក់វៀតណាម យួននៅហ្នឹងទៀត អត់បានទេ គឺត្រូវតែមានទោស។ អ៊ីចឹងគេស្រាវជ្រាវរកឃើញប្ដីយួន ប្រពន្ធយួនអីក៏ដោយ គឺត្រូវតែទទួលខុសត្រូវខ្លួនឯង។ ដល់អ៊ីចឹងទៅប្រជាពលរដ្ឋនៅក្នុងហ្នឹង អត់ហ៊ានលាក់ទេ។ ម្ល៉ោះហើយ ខ្ញុំសុំ មិនមែនទេ គាត់អត់មែនយួនទេ។ គាត់ប្រពន្ធខ្មែរ តែប្ដីៗយួន។ តែប្ដីនោះមករកស៊ីនៅស្រុកខ្មែរហ្នឹងតាំងពីសង្គមរាស្ត្រនិយមមក។ ដល់អ៊ីចឹង

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ទៅ គាត់មានកូនមានចៅឡើងប្រាំប្រាំមួយនាក់អ៊ីចឹង។ ដល់អ៊ីចឹងទៅ គេថា អ្ហ៊ែ! អត់បានទេ! ឲ្យតែជាប់សាច់យួន គឺអត់បាន។ គេហៅឡើងកាណូតទៅ ចង់ដាក់លើកាណូត បើកមកតាមស្ទឹងបាត់ដំបង មកទន្លេសាបនេះ យកមកបាញ់ចោលក្នុងទឹក ក្នុងព្រៃទាំងអស់។ ហើយផុតពីហ្នឹងមក ខ្លះនៅតាមទូក តាមអីក្រោមៗហ្នឹងគេដើរប្រមូល គេចាប់អត់ឲ្យសល់ទេ។ គេចាប់យកទៅសម្លាប់ទាំងអស់នៅឆ្នាំ១៩៧៨ហ្នឹង។

[១០:៤៨:៥៥]

**ស៖** ខ្ញុំចង់បន្តទៅប្រធានបទចុងក្រោយ ដើម្បីសួរសំណួរលោកមួយចំនួន។ តើលោកដឹងថាមានជនជាតិចាមដែលរស់នៅក្នុងភូមិភាគពាយ័ព្យដែរឬទេ ក្រោយពី<ថ្ងៃ១៧> ខែមេសា ឆ្នាំ១៩៧៥?

**ឆ៖** បាទត្រង់ជនជាតិចាមហ្នឹងគឺខ្ញុំដឹង តែមិនសូវមានសកម្មភាពអីដូចជនជាតិវៀតណាមទេ បើវៀតណាមគឺអត់បានតែម្តង។ បើជនជាតិចាម គេគ្រាន់តែថា ទទួលការគាបសង្កត់ខាងទំនៀមទម្លាប់ ហើយនិងប្រពៃណីខ្លះ។ ដូចថា គេមិនធ្លាប់ហូបសាច់ជ្រូកអ៊ីចឹងទៅ អ៊ីចឹងខាងកុម្មុយនីស្តហ្នឹង គេឲ្យ គេបង្ខំឲ្យជនជាតិហ្នឹងហូបសាច់ជ្រូក សាច់អីទៅ។ អ្នកខ្លះមិនហូប មានការជៀសវាងអ៊ីចឹងទៅ ក៏គេធ្វើបាប ទារុណកម្មអី ធម្មតា អ្នកខ្លះក៏មានការបាត់បង់អាយុជីវិតអីខ្លះដែរ។ ប៉ុន្តែភាគច្រើនគឺច្រើននៅរស់ជនជាតិចាមហ្នឹង គឺភាគច្រើននៅរស់។ តែអ្នកដែលស្លាប់ហ្នឹងគឺស្លាប់ដូចថា ប្រឆាំងនឹងគេ មិនព្រមអនុវត្តតាមគេ អាហ្នឹងគឺមានការបាត់បង់អាយុជីវិតហើយ។ តាមខ្ញុំគឺមានតែប៉ុណ្ណឹង។

**ស៖** តើលោកទទួលបានព័ត៌មានបែបនេះដូចម្តេចដែលនិយាយថា គេបង្ខំជនជាតិចាមឲ្យហូបសាច់ជ្រូក ហើយអ្នកណាដែលប្រឆាំងដែលមិនព្រមហូបគឺគេនឹងសម្លាប់ តើលោកដឹងដោយរបៀបណា?

[១០:៥០:៥៤]

**ឆ៖** ខ្ញុំដឹងតាមរយៈបងប្អូនខ្មែរអ៊ីស្លាមហ្នឹងដែលគាត់ធ្លាប់ទៅរស់នៅ រកត្រីរកនឹងទន្លេហ្នឹងជាមួយខ្ញុំ គាត់បានប្រាប់ខ្ញុំអ៊ីចឹង។ បានខ្ញុំថាមកនៅកន្លែងខ្ញុំអីមិនបាច់ភ័យទេ ទោះបីមិនហូបសាច់ជ្រូកក៏ហូបស្អីក៏បានដែរ តែសំខាន់មិនកុំឲ្យជំទាស់នឹងគេ ទំនាស់នឹងគេអ៊ីចេះចុះអត់បានទេ។ ខ្ញុំគ្រាន់តែប្រាប់គេអ៊ីចឹង។ អ៊ីចឹងកន្លែងខ្លះគេៗប្រកាន់គេអត់ឲ្យនេះទេ ឲ្យធ្វើតាមគេទាំងអស់ គេឲ្យហូបអីគឺឲ្យហូបហ្នឹង ព្រោះកាលហ្នឹងយើងបាយរួម។ ការដ្ឋានមួយៗមានចាប់ពី៧០, ៨០ទៅ១០០នាក់អី មានជាង១០០អីក៏មានដែរ ការដ្ឋានបាយបបរហ្នឹង។ អ៊ីចឹងវាត្រូវការម្ហូបហ្នឹង បើសាច់ជ្រូកៗទាំងអស់គ្នា បើត្រីៗទាំងអស់

គ្នា បើអត់ៗទាំងអស់គ្នាអ៊ីចឹងទៅ។ អ៊ីចឹងគឺអាត្រង់ហ្នឹងហើយដែលវាៗមានបញ្ហាពិបាកបងប្អូនអ៊ីស្លាម ហ្នឹងរស់នៅក្នុងកាលពីសង្គមហ្នឹង។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកច្រើន ដែលលោកបានឆ្លើយនឹងសំណួរខ្ញុំទាំងអស់នេះ។ ហើយសូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរនឹងសួរសាក្សីនេះហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ ផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលសាក្សីរូបនេះ។

[១០:៥២:៣១]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោកលោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតលោកប្រធានផ្តល់ឱកាសឲ្យលោកមេធាវី ឡោ ជុនធី មានសំណួរមួយចំនួនតូច ដើម្បីសួរទៅសាក្សីរូបនេះ។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ហើយសូមគោរពអង្គជំនុំជម្រះទាំងមូល ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំបាទមកពីអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** នៅពេលនេះ សូមជម្រាបសួរលោកពូដែលជាសាក្សី។ ពាក់ព័ន្ធសំណួរមួយចំនួនដែលលោកពូមានបទពិសោធន៍ នៅចំណុចថ្មីមួយដែលខ្ញុំបាទចង់ជម្រាបសួរលោកពូ គឺពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍នៅក្នុងកន្លែងដែលលោកពូបានធ្វើការហ្នឹង តើមានការរៀបអាពាហ៍ពិពាហ៍យ៉ាងណាដែរនៅក្នុងសម័យនោះបាទ?

[១០:៥៣:៥៩]

01386943


2-TCW-1037៖

**ឆ៖** បាទ ក្នុងសម័យនុ៎ង ក្នុងការរៀបចំអាពាហ៍ពិពាហ៍ហ្នឹង វាមិនមែនដូចសព្វថ្ងៃនេះទេ។ កាលនុ៎ងរៀបចំអាពាហ៍ពិពាហ៍ អ្នកខ្លះគឺបានស្រលាញ់គ្នាដោយចិត្តនឹងចិត្ត អ្នកខ្លះមានការចាប់បង្ខំក៏មានដែរ។ អ៊ីចឹងជាក់ស្ដែងដូចជាខ្លួនខ្ញុំផ្ទាល់ ខ្ញុំក៏មានភរិយានៅពីសម័យហ្នឹងដែរ។ ឆ្នាំ១៩៧៥ ខ្ញុំបានរៀបចំអាពាហ៍ពិពាហ៍ជាមួយគ្រួសារខ្ញុំដែលមកជាមួយនេះ គឺនៅថ្ងៃទី៣១ ខែ – ថ្ងៃទី៣១ ខែៗកញ្ញា អ៎! ខែធ្នូ។ អ៊ីចឹងវាជិតដាច់ឆ្នាំ៧៥ហើយ ជិតចូល៧៦ហើយ អ៊ីចឹងកាលនុ៎ងរៀបមានចំនួន៣០គូ។ អ៊ីចឹងអ្នកខ្លះ គ្រាន់តែថា ខ្ញុំចង់បាន ចង់មានគ្រួសារ អ្នកខ្លះមិនទាន់ឃើញមុខគ្រួសារខ្លួនហ្នឹងមុខមាត់ម៉េចផងក៏មានដែរ។ អ៊ីចឹងពេលនុ៎ង គឺខ្ញុំមិននិយាយទៅណាឆ្ងាយទេ និយាយតែអង្គាល់ជំនាន់ខ្ញុំហ្នឹង គឺខ្ញុំធ្លាប់ជួបអ៊ីចឹងមែន ហើយការរៀបចំនេះគឺគ្មានអីទេ គ្រាន់តែចាប់ដៃគ្នាទៅ ឧទ្ទេសនាមទៅ ប្រកាសហេតុផលថាឧទ្ទេសនាមទៅ ហើយកែ ខំធ្វើការងារ និងកសាងខ្លួនទៅតាមការណែនាំមាគ៌ានយោបាយរបស់អង្គការដឹកនាំ តែប៉ុណ្ណឹងចប់ហើយ អត់មានអីច្រើនផង។

**សៈ** តើលោកពូបានដឹងថា ការរៀបចំ ដែលរៀបអាពាហ៍ពិពាហ៍ហ្នឹងឡើងហ្នឹង មានការចាត់តាំង ឬមួយមានការរៀបចំពីគណៈដឹកនាំណាខ្លះ? តើលោកពូអាចជម្រាបបញ្ហានេះបានទេបាទ?

**ឆ៖** បាទកាលនុ៎ង គឺមានការរៀបចំដឹកនាំក្នុងពិធីអាពាហ៍ពិពាហ៍អីហ្នឹង គូស្រករហ្នឹងគឺរៀបចំថ្នាក់របស់ក្រសួងមន្ទីរ របស់ភាគគឺមាន កាលនុ៎ងមានមុខ មានតាខ្លែង, មានតាខ្លែង មានតាហំ មានតាស៊ុម មានអីហ្នឹង គឺចូលរួមក្នុងកម្មវិធីហ្នឹង ទទួលស្គាល់ ដឹងឮរបស់សេនាធិការរបស់យោធាភាគហ្នឹង។

[១០:៥៧:១០]

**សៈ** បាទ អរគុណ។ អម្បាញ់មិញលោកបានលើកឡើងថា អំពីពាក់ព័ន្ធទៅរឿងអ្វីដែលខាងនិរតីបានចូលទៅ ហើយមានរឿងកើតឡើងនៅក្នុងតំបន់របស់លោកពូ ខ្ញុំចង់ជម្រាបសួរ ថាតើអ្វីដែលនិរតីចូលទៅហ្នឹង ពេលដែលគេចូលទៅ គេបង្កើតនូវរចនាសម្ព័ន្ធគ្រប់គ្រងរបស់គេហ្នឹងរបៀបណាដែរ លោកពូអាចដឹងទេ?

**ឆ៖** កាលនោះខ្ញុំដឹងបានខ្លះថា ពេលដែលគេចូលទៅដល់ហ្នឹងគឺ គេបានដកហូតអ្នកដឹកនាំខាងពាយ័ព្យ និយាយរួមទៅក្នុងថ្នាក់សហករណ៍មួយចំនួនក៏អ៊ីចឹងដែរ។ ហើយក្នុងៗជួរអង្គភាពទ័ពក៏ៗមានអ៊ីចឹងដែរ គឺគេបានដកហូតហើយ បានគេទៅតែងតាំងអ្នកដឹកនាំក្បាលម៉ាស៊ីនរបស់គេហ្នឹង តាមក្រោយហ្នឹង តាមឋានៈតូចគិតតាមតូច ធំគិតតាមធំអ៊ីចឹងទៅ។ នេះតាមខ្ញុំដឹង គេៗទៅគេប្រកាសអ៊ីចឹង។ តែ

01386944



ចំពោះអង្គភាពខ្ញុំ គេអត់មានប្រកាសទេ គេចាប់ៗចុងក្រោយគេហ្នឹង ឃើញថាចាប់បានប៉ុន្មានខែហ្នឹង មិនដល់ពេល១ខែផង ក៏គេទៅដកហូត ទៅដេញចេញ ប្រមូលយកមកដាក់តាមសហករណ៍អស់ទៅ ហើយអត់បានបង្កើតអង្គភាពហ្នឹងថាមាននិរតីមកគ្រប់គ្រងធ្វើបន្តទៀត អត់ទេ។ អ៊ីចឹងមួយពេលហ្នឹង គឺគេបំបែកចេញទៅតាមសហករណ៍អស់។

**ស៖** បាទ អរគុណ។ ថាតើនៅពេលដែលគេរៀបចំអ៊ីចឹងហើយ តើក្រុមលោកពូ អង្គភាពលោកពូហ្នឹង មានបាត់ខ្លួនបន្តបន្ទាប់ទៀតដែរអត់ទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

[១០:៥៩:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ មិនមែនជាការជំទាស់ទេ ជាការកត់សម្គាល់។ សំណួរនេះគឺមានភាព<ពាក់ព័ន្ធ។> ប៉ុន្តែខ្ញុំមានការភ្ញាក់ផ្អើលបន្តិច ដែលថាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសួរសំណួរអំពីការបះបោរ ឬក៏ការបោសសម្អាតនៅភូមិភាគពាយ័ព្យនេះ ហើយបើសិនណាជាខ្ញុំយល់ច្រឡំសូមជួយកែតម្រូវខ្ញុំផង។ <តាមដែលខ្ញុំយល់> អ្វីដែលកើតឡើងនៅភូមិភាគពាយ័ព្យហ្នឹង គឺវាស្ថិតនៅក្រៅវិសាលភាពសំណុំរឿង<០០២/០២>នេះហើយ។ <ខ្ញុំគិតថា នោះជាជំហរបន្តទៀត។> ពីព្រោះថានៅពេលដែលខ្ញុំសួរចំណុចនេះ គឺថាមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីតែងតែជំទាស់មកយើងខ្ញុំ។ ឥឡូវនេះសំណួរសួរពាក់ព័ន្ធទៅនឹងភូមិភាគពាយ័ព្យនោះ ក៏វាមិនមានការពាក់ព័ន្ធដូចតែគ្នាទេអ៊ីចឹង។

**លោក ឡោ ជុនធី៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមដកសំណួរនេះចេញវិញ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** ពាក់ព័ន្ធនឹងអ្វីដែលខ្ញុំបានសួរខាងមុខ ខាងដើម គឺបញ្ហាអាពាហ៍ពិពាហ៍លោកពូ ថាតើអ្វីដែលលោកពូបានរៀបការហ្នឹង លោកពូបានស្គាល់គ្នាមុន ឬមួយយ៉ាងម៉េចដែរ?

**2-TCW-1037៖**

**ឆ៖** បាទ ចំពោះខ្ញុំ ខ្លួនខ្ញុំផ្ទាល់ ខ្ញុំបានស្គាល់គ្នាមុន។

[១១:០១:២៥]

**ស៖** ចុះចំពោះគូអ្នកផ្សេងទៀត លោកពូអាចជម្រាបបានទេ?

**ឆ៖** បាទ មានអ្នកផ្សេងទៀត តែវាមានតិចតួចទេ មានប្រហែលជាពីរៗគ្រួសារអីទេ ដែលគេមិនបានស្គាល់គ្នា ឃើញមុខគ្នាច្បាស់ គ្រាន់តែៗថាខ្ញុំចង់បានគ្រួសារអីចឹងទៅ អីចឹងគឺអង្គការគេហ្នឹង គេរៀបចំឱ្យតែម្ដង។

**ស៖** អរគុណលោកពូ។ ថាតើក្នុងចំណោមហ្នឹងមានព្រឹត្តិការណ៍អីកើតឡើងទេ ថាមានការបង្ខំឬមួយឱ្យរួមដំណេក ឬអី? លោកពូមានបានឮពាក្យអស់ហ្នឹងទេ?

**ឆ៖** បាទ ចំណុចហ្នឹង ខ្ញុំឮ។ តែចំពោះគូស្រុករដែលរៀបចំជាមួយខ្ញុំហ្នឹង គឺមិនដែលមានទេ ក៏ប៉ុន្តែឮពីកន្លែងផ្សេង តំបន់ផ្សេង ស្រុកផ្សេងហ្នឹង គឺមាន។ មានខ្លះគឺអង្គការគេចាប់បង្ខំ គេសាមីខ្លួនគេអត់ពេញចិត្ត គេអត់ចង់បាន តែការចាប់បង្ខំ ម្ល៉ោះហើយចេះតែធ្វើគោរពយកតែកិច្ចទៅ ដល់ពេលក្រោយមក គឺគ្រួសារហ្នឹងអត់ត្រូវគ្នា បាក់បែកគ្នា ក៏មានដែរ។ ហើយដល់ពេលបាក់បែកគ្នា អ្នកខ្លះរហូតដល់គេយកទៅសម្លាប់ចោល ថាយើងអត់ដើរតាមមាគ៌ានយោបាយរបស់អង្គការអីចឹង។

**ស៖** បាទ អរគុណ។ ថាតើពេលដែល ក្រោយពីរៀបការហើយហ្នឹង ប្ដីប្រពន្ធហ្នឹងគាត់អាចរួមរស់នៅជាមួយគ្នាបានដែរអត់ទេ?

[១១:០៣:៤៧]

**ឆ៖** និយាយទៅភាគៗច្រើន ដូចមិនសូវបាន ការហើយបានតែរយៈពេលពីរថ្ងៃទៅបីថ្ងៃអីប៉ុណ្ណឹងទេ ផុតពីហ្នឹងទៅ គេបំបែក ប្រពន្ធទៅផ្សេង ប្ដីទៅផ្សេងទៅ។ ហើយបើប្ដីជាទ័ពទៅនៅអង្គភាពទ័ពទៅ ហើយប្រពន្ធនៅកន្លែងការដ្ឋាន គ្រួសារទ័ពអីគេយកទៅដាក់ រៀបចំកន្លែងផ្សេងទៅ ឱ្យធ្វើស្រែធ្វើចម្ការនៅកន្លែងណាមួយផ្សេងអីចឹងទៅ។ ហើយបើយើងចង់ជួបប្ដី ជួបប្រពន្ធ ទាល់តែសុំច្បាប់អនុញ្ញាតមកលេងមួយថ្ងៃអីអីចឹងទៅ ឬក៏ពីរថ្ងៃអីអីចឹងទៅ បើគេអនុញ្ញាតបាន បើគេមិនអនុញ្ញាត អត់បានមកជួបប្រពន្ធដែរ អត់ជួបប្ដីដែរ។ ហើយភាគច្រើន គឺប្រពន្ធអត់ដែលហ៊ានសុំមកលេងប្ដីអីទេ ច្រើនតែប្ដីទេដែលសុំនៅក្នុងអង្គភាពខ្លួនរស់នៅហ្នឹង សុំទៅលេងប្រពន្ធ លេងកូនអីចឹង។

**ស៖** សំណួរខ្ញុំចុងក្រោយគឺសំណួរផ្នែក ថាតើលោកពូមានអារម្មណ៍ភ័យខ្លាចយ៉ាងណា ដែលពាក់ព័ន្ធថា ពេលរៀបការហើយ ប្រសិនមានកូន មានចៅទៅវាលំបាកតទៅទៀត ឬមួយយ៉ាងណា?

**ឆ៖** បាទ គិតទៅចំពោះរឿងនេះ ខ្ញុំមានការភ័យព្រួយបារម្ភដែរ ដល់ពេលអនាគតទៅកូនចៅ

វាអត់ គេហៅថា វាអត់មានអីទេ ក៏ប៉ុន្តែក្នុងរបបហ្នឹង នឹកឃើញថា អ្វីៗទាំងអស់វាជារបស់អង្គការទៅហើយ។ អ៊ីចឹងការរស់នៅ ស៊ីចុក ប្រើប្រាស់សម្ភារៈអី គឺជារបស់សម្ហូភាពទាំងអស់ទៅហើយ។ ដល់អ៊ីចឹងទៅ គេមិនឱ្យយើងហ្នឹងមានកម្មសិទ្ធិថា អូ! នេះជាកូនអញ នេះជាទ្រព្យអញ មានស្អីចែកឱ្យកូនឱ្យចៅអីគឺអត់មាន កាលនោះគេអត់មាននិយាយអ៊ីចឹង។ គេគិតថា អ្វីៗទាំងអស់គឺយើងមានតែខ្លួន យើងមានតែពោះបាយ ពោះទឹក ចាំទទួលតែប៉ុណ្ណឹង។ តែរឿងការចាត់ចែង រឿងសេរីភាព រឿងអីចង់ឱ្យអ្នកណាចេះ អ្នកណាល្ងង់ អ្នកណាម៉េច គឺវានៅលើគោលការណ៍របស់គេហ្នឹង។

**លោក ឡេ្វា ជុនធី៖**

បាទ អរគុណលោកប្រធាន។ ខ្ញុំបាទ អស់សំណួរហើយ។ សូមអរគុណលោកពូ។

[១១:០៦:៥០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយជាបន្តនេះ ផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ខ្ញុំមានសំណួរបន្តិចបន្តួចសួរលោកបន្ថែម ជាពិសេសទាក់ទងទៅនឹងសំណួរបន្ត ពាក់ព័ន្ធនឹងអ្វីដែលលោកបាននិយាយនៅចំពោះមុខតុលាការយើងនេះ។ លោកបាននិយាយពីការងាររបស់លោកនៅក្នុងកងទ័ព ហើយលោកបាននិយាយថា លោកត្រូវបានគេចាត់តាំងឱ្យធ្វើការខាងពាណិជ្ជកម្ម។ អ៊ីចឹងនៅពេលដែលលោកទៅធ្វើការខាងពាណិជ្ជកម្មហ្នឹង តើពេលនោះលោកនៅតែជាយោធាផងដែលទេ ឬក៏យ៉ាងណា?

**2-TCW-1037 ៖**

**ឆ៖** បាទ កាលនោះ ខ្ញុំអត់មាន -- កម្លាំងខ្ញុំអត់មានអាវុធអីដូចដែលខ្ញុំនៅជាយោធាទេ។ មានអាវុធដែរ មានតែបួនប្រាំដើមអីប៉ុណ្ណឹង គឺជាៗកម្លាំងក្រសួងរបស់ មន្ទីររបស់កងទ័ពភាគតែម្តង។

[១១:០៨:១៦]

**ស៖** អ៊ីចឹងលោកនៅក្នុងកងទ័ពភូមិភាគ បើតាមចម្លើយរបស់លោកនោះគឺថា លោកមានកាំភ្លើងបួនប្រាំដើមនៅជាមួយលោក។ អ៊ីចឹងខ្ញុំសួរលោកថា តើលោកទុកកាំភ្លើងហ្នឹងនៅនឹងលោក ឬក៏ពេលណាមួយលោកបានប្រគល់ទៅឱ្យគេវិញ?

**ឆ៖** បាទ កាំភ្លើងហ្នឹង--

**ស៖** ខ្ញុំមានបញ្ហាប្រដាប់ស្ដាប់របស់ខ្ញុំលោកប្រធាន។ ខ្ញុំសូមមុននឹងគាត់ឆ្លើយ ខ្ញុំសុំដូរប្រដាប់ស្ដាប់សិន កាសខ្ញុំសិនលោកប្រធាន។ ខ្ញុំសុំទោស! ឥឡូវលោកសាក្សី លោកអាចឆ្លើយនឹងសំណួរខ្ញុំបានបើសិនចាំ។ អ៊ីចឹងសំណួរខ្ញុំសួរថា តើនៅពេលណាមួយនោះ លោកមានបានប្រគល់អាវុធទាំងអស់នោះទៅគេវិញដែរឬទេ?

**ឆ៖** បាទ អាវុធទាំងអស់ហ្នឹង គឺមិនបានប្រគល់យកទុកដាក់ក្នុងឃ្លាំងអីទេ។ អាវុធហ្នឹងគឺគេប្រគល់ឱ្យយើងកាន់ជា ដូចថាជាកម្មសិទ្ធិផ្ទាល់ខ្លួនតែម្ដង។ គឺចែកគ្នាកាន់ទៅ គ្នាបួនប្រាំប្រាំមួយនាក់ហ្នឹងកាន់ ដូចថាជាកម្លាំងការពារនៅក្នុងមន្ទីរហ្នឹង ក្នុងអង្គភាពហ្នឹង។

**ស៖** សូមអរគុណ។ លោកបាននិយាយថា លោកឮគេចោទប្រកាន់ទៅលើ វ៉ាញ ហើយលោកបានថា <គេចោទ>គាត់<ថា>បាន<លាក់ទុក>អាវុធ យកអាវុធហ្នឹងទៅឱ្យកងចល័ត។ អ៊ីចឹងខ្ញុំសួរលោក ថាតើកងចល័តហ្នឹង អាចមានសិទ្ធិទទួលអាវុធដែរឬទេ?

[១១:១០:២៣]

**ឆ៖** បាទ កាលនុ៎ងគឺកងចល័តហ្នឹង គេហៅថា កងចល័តហ្នឹងគឺជាៗក្រុមយុវជន នៅលើវៗហ្នឹង គេរៀបចំកម្លាំងយុវជនហ្នឹង ដើម្បីឱ្យរែកដីធ្វើទំនប់កង្កួតហ្នឹង។ តែរឿងអាវុធហ្នឹង គឺមិនទាន់បានប្រគល់ទេ គេគ្រាន់តែថា គេអ្នកនិយាយហ្នឹង គេថា តាវ៉ាញ ហ្នឹងគឺត្រៀមអាវុធហ្នឹងបំពាក់ឱ្យកងចល័តដើម្បីធ្វើការវាយបក។ នេះតាមដែលខ្ញុំឮ គេប្រាប់ខ្ញុំតែប៉ុណ្ណឹងទេ។

**ស៖** លោកបានឮ គេនិយាយអំពីការចោទប្រកាន់ទៅលើគាត់ហ្នឹង អ៊ីចឹងសំណួររបស់ខ្ញុំចង់ដឹងថា អ្វីដែល តាស៊ុម បាននិយាយប្រាប់លោកនោះ ថាតើ តាស៊ុម មានប្រាប់លោកថា គេរកឃើញអាវុធហ្នឹងលាក់នៅកន្លែងណាមួយ? តើលោកមានបានទទួលព័ត៌មានបែបហ្នឹងពី តាស៊ុម ទេ?

**ឆ៖** បាទ អត់បានទទួលព័ត៌មានអ៊ីចឹងផង។

**ស៖** ឥឡូវខ្ញុំសូមចូលទៅនិយាយពីចំណុចមួយទៀត ដែលលោកទើបតែនឹងបាននិយាយជាមួយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។ លោកបាននិយាយពីចំណុចហ្នឹងពីមុនមកផងដែរ។ លោកបាននិយាយអំពីការមកដល់នៃកម្មាភិបាលមកពីភូមិភាគនិរតី មកកន្លែងលោក ហើយលោកបាននិយាយថាពួកគាត់បានមកជំនួសកម្មាភិបាលនៃកងមួយចំនួន។ នៅក្នុងចម្លើយរបស់លោកចំពោះមុខសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/9580 លោកបាននិយាយអំពីរយៈពេលមួយដែលកម្មាភិបាលមកពីនិរតីទាំងអស់នោះ បានធ្វើការជាមួយអ្នកពាយ័ព្យ។ ខ្ញុំសូមដកស្រង់ គឺនៅចម្លើយទី៣៦ លោកនិយាយដូចតទៅនេះ៖ "យើងបានដឹងថា ពួកគេមកពីភូមិភាគនិរតី ដោយសារព័ត៌មានសម្ងាត់ដែលយើងបានដឹង ដែលប្រជាជនបានដឹង។ ដំបូងគេធ្វើការជាមួយអ្នកធ្វើការខាងពាយ័ព្យជាមួយគ្នា ដោយមកជួយគ្នា ក៏ប៉ុន្តែតាមពិត គេមកហ្នឹងដើម្បីស៊ើបការណ៍លើពួកពាយ័ព្យទេ។ បីបួនខែក្រោយមក វាចាប់ផ្ដើមរាយការណ៍ពីអ្នកណាដែលធ្វើខុស។ ឧទាហរណ៍<គេបានចោទ>អង្គភាពនេសាទរបស់ខ្ញុំ <ថាចាក់>ម៉ាស៊ូត នៅក្នុងទឹក ហើយលែងត្រីឲ្យរួចវិញ <ប៉ុន្តែយើងមិនបានធ្វើដូច្នោះទេ>។"

សំណួរខ្ញុំសួរថា តើអ្វីដែលលោកបាននិយាយនៅក្នុងចម្លើយរបស់លោកនោះ លោកថា<> អ្នកភូមិភាគនិរតីហ្នឹង គាត់ធ្វើការជាមួយនឹងអ្នកពាយ័ព្យ<បីបួនខែ>។ តាមឃ្លារបស់លោកនេះ ឃើញថាការចាប់ខ្លួននោះ គឺមិនបានធ្វើភ្លាមៗនោះទេ។ តើ<ខ្ញុំយល់ត្រឹមត្រូវទេ ហើយតើ>លោកអាចបញ្ជាក់បានទេ<>?

[១១:១៤:០៨]

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា កាលដែលគេចាប់ផ្ដើមចាប់ខ្លួនពាយ័ព្យហ្នឹង គឺដំបូងមិនមែននិរតីមកចាប់ទេ។ អ៊ីចឹងថ្នាក់ដឹកនាំនៅក្នុងភូមិភាគហ្នឹង ក៏ចាប់អ្នកពាយ័ព្យហ្នឹងដែរ ចាប់មួយចំនួន។ ដល់ក្រោយមកបានឃើញនិរតីហ្នឹង ក៏ចុះមកសៀតស៊កនៅតាមក្រសួងមន្ទីរមួយចំនួនរបស់ភាគហ្នឹង។ ជាក់ស្ដែងដូចនៅកន្លែងខ្ញុំហ្នឹង ខាងកងនេសាទខ្ញុំហ្នឹង មន្ទីរខាងនេសាទខ្ញុំហ្នឹង ក៏គេទៅរស់នៅធ្វើការងារជាមួយខ្ញុំដែរ។ អ៊ីចឹងចាប់ពីពេលហ្នឹងមក ខ្ញុំឃើញថា ផ្នែកដឹកនាំខាងលើហ្នឹង តិចឮថា អ៎! គេចាប់អានេះ តិចថាឮចាប់អានោះ។ អ៊ីចឹងនិរតីកាន់តែចុះមកច្រើន ជាពិសេសចុះមក ចាប់ដែលខ្លាំងជាងគេគឺនៅឆ្នាំ១៩៧៨ហ្នឹងតែម្ដង។ ដើមឆ្នាំ៧៨ និងចុងឆ្នាំ៧៨ហ្នឹង គឺចាប់ច្រើនជាងគេ នេះតាមខ្ញុំដឹង។ បាទ សូមរាយការណ៍ជូនប៉ុណ្ណឹង។

**ស៖** ខ្ញុំពិបាកយល់ចម្លើយរបស់លោក។ បើសិនជាខ្ញុំយល់មិនច្រឡំទេ គឺលោកបាននិយាយអម្បាញ់មិញហ្នឹងថា ការចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យនោះ ពីដំបូងគឺគេចាប់ផ្ដើមចាប់ -- ពីដំបូង

ទីហ្នឹងគឺថា កម្មាភិបាលភូមិភាគពាយ័ព្យហ្នឹងចាប់កម្មាភិបាលភូមិភាគពាយ័ព្យគ្នាឯងទេ។ លោកនិយាយអ៊ីចឹង ឬក៏យ៉ាងម៉េច?

[១១:១៦:០៧]

**ឆ៖** បាទ ខ្ញុំនិយាយអ៊ីចឹងមែន ដំបូងបង្អស់។ ដល់ក្រោយមកបានឃើញនិរតីមកចាប់ភូមិភាគពាយ័ព្យ។

**ស៖** សូមអរគុណ។ ហើយតាមចម្លើយអម្បាញ់មិញហ្នឹង គឺលោកនិយាយថា នៅក្នុងកងនេសាទរបស់លោកនោះ គឺលោកធ្វើការជាមួយអ្នកមកពីភូមិភាគនិរតីដែរ ពីដំបូងទី។ តើខ្ញុំនិយាយអ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រឹមត្រូវ។ ដំបូងគឺគេមកសុំធ្វើការជាមួយខ្ញុំដែរ នៅកិច្ចការងារនេសាទហ្នឹង។

**ស៖** អ៊ីចឹងគឺខ្ញុំសូមឲ្យលោកជួយបំភ្លឺត្រង់ចំណុចមួយ កាលណោះលោកដូចឆ្លើយទៅសហព្រះរាជអាជ្ញា ឬក៏ឆ្លើយទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ តាមខ្ញុំស្តាប់ឮហ្នឹងគឺលោកនិយាយថា លោកបានលាក់ថា លោកមិនជាអនុប្រធានកងនេសាទ ដើម្បីកុំឲ្យគេចាប់លោក។ អ៊ីចឹងខ្ញុំសួរលោកថា លោកលាក់អត្តសញ្ញាណរបស់ខ្លួនឯងម៉េចនឹងបានទៅ បើពួកហ្នឹងគេមក គេមកធ្វើការជាមួយលោកពីដំបូងទីនោះ?

[១១:១៧:៤៣]

**ឆ៖** បាទ កាលហ្នឹងដែលខ្ញុំលាក់បានហ្នឹង កាលដែលគេចាប់ តាស៊ុម ទៅហ្នឹង ខាងនិរតីហ្នឹងក៏គេដកចេញដែរ គេអត់ប៉ាននៅ រស់នៅជាមួយយើងទេ ព្រោះកាលហ្នឹងគ្នាគេមានម្នាក់ពីរនាក់ អ៊ីចឹងខ្លាចលោពួកពាយ័ព្យបះបោរទៅ គេមិនដឹងគេចទៅណា។ អ៊ីចឹងមួយពេលចុងក្រោយហ្នឹង គឺគេគេចខ្លួនបាត់ហើយ។ ដល់តែពេលគេយកពួកខ្ញុំទៅដាក់សហករណ៍ហ្នឹង គេរក គេសួររក ដូចខាងសហករណ៍តាអ៊ឹម ហ្នឹងគេសួររកខាងថា តើមានអ្នកណាមួយដែលជាៗអនុប្រធាន តាស៊ុម? អ៊ីចឹងកម្លាំងពួកខ្ញុំនៅហ្នឹង ប្រជាពលរដ្ឋដែលខ្ញុំរស់នៅជាមួយហ្នឹងគេស្គាល់ខ្ញុំ គេចេះប្រាប់ថា អត់ទេ និរតីគេចាប់យកទៅអស់ហើយ។ ក្រោយពីចាប់ តាស៊ុម ទៅហ្នឹងអត់នៅទេ ព្រោះជាក់ស្តែងកាលនុំងគឺកម្លាំងរាប់រយនាក់ គឺត្រូវបែកបាក់គ្នា ចែកគ្នា អាខ្លះទៅសហករណ៍ ខ្លះទៅខាងកន្លែងលត់ដំកោះអីខ្លះអ៊ីចឹងទៅ។ អ៊ីចឹងគេក្តាប់អត់បានថា ខ្ញុំនៅកន្លែងណា។ បាទ សូមឆ្លើយអ៊ីចឹង។

**ស៖** ខ្ញុំមិនដឹងថាមានបញ្ហាក្នុងការបកប្រែ ឬក៏យ៉ាងណាទេ។ ឥឡូវខ្ញុំឮលោកឆ្លើយថា អ្នកនិរតី

ដែលមកធ្វើការ<បី>បួនខែដំបូងជាមួយនឹងកងនេសាទរបស់លោកហ្នឹង គឺមកធ្វើការហ្នឹងដើម្បីស៊ើបអង្កេតលើពួកពាយ័ព្យ។ ហើយលោកឆ្លើយអំមិញថាយ៉ាងម៉េច ពួកខាងនិរតីហ្នឹងត្រូវបានគេដកចេញ ឬក៏យ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំស្ដាប់មិនសូវបាន?

**ឆ៖** បាទ កាលហ្នឹងគឺ កាលហ្នឹងគេរឹករវរខ្លាំងហើយ គ្រប់ក្រសួងមន្ទីរទាំងអស់របស់ភូមិភាគហ្នឹងច្របូកច្របល់ ត្រូវកិច្ចការងាររចនាសម្ព័ន្ធដឹកនាំហ្នឹង គឺលែងទាក់ទងអ្វីគ្នាបានហើយ។ ដល់អ៊ីចឹងគឺនិរតីដែលៗនៅតាមកន្លែងមួយៗហ្នឹងគេប្រមូលគ្នា ផ្ដុំគ្នាគេហ្នឹង មិនដឹងទៅណាមកណើទេ ព្រោះមួយពេលហ្នឹង ពួកខ្ញុំបានគេយកមកដាក់ទន្លេសាប -- យកមកដាក់សហករណ៍ហ្នឹងប្រមាណប្រាំពីរទៅប្រាំបីគ្រួសារទេ។ ហើយផុតពីហ្នឹងគេបញ្ជូនទៅសហករណ៍ផ្សេងៗ និងកន្លែងកកោះ និងភ្នំធិបតី។ ហ្នឹងខាងនិរតីគេយកមកទីក្រុងបាត់ដំបងហ្នឹង គេបញ្ជូនទៅហ្នឹង ទៅមុនខ្ញុំ។ ខ្ញុំឡើងមកក្រោយគេទេ មកនៅសាលាតាអនហ្នឹងរយៈពេលបួនប្រាំថ្ងៃក្រោយមក បានគេប្រមូលឡើងមកទៀត ព្រោះយកម្ដងវាអត់អស់ទេ ទាល់តែពីរដងបានអស់។

[១១:២១:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសុំអធ្យាស្រ័យដែលកាត់រំខានសហការីខ្ញុំ។ ខ្ញុំសុំនិយាយអំពី<>បញ្ហា<នៃការបកប្រែ>។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីរូបនេះ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីទៅដល់ឯភូមិភាគពាយ័ព្យ គឺជាភាសាអង់គ្លេសមានពាក្យខុសគ្នាគឺ "ការស៊ើបអង្កេត" និង"ការតាមដាន"។ ក៏ប៉ុន្តែខ្ញុំយល់ថា ការបកប្រែជាភាសាបារាំងគឺ *"អេស្គ្វីរ៉ណេ"* នេះគឺមានន័យថាជា "ការស៊ើបការណ៍" ទៅវិញទេ។ អ៊ីចឹងឃើញ យើងឃើញថាការបកប្រែទៅជាភាសាពីរនេះមានភាពខុសគ្នា។ ប៉ុន្តែសម្រាប់យើងខ្ញុំៗសុំឱ្យមានការបញ្ជាក់ឱ្យបានច្បាស់បន្តិចជាភាសាខ្មែរ តើយកពីពាក្យពីបារាំង និងអង់គ្លេសមួយណាយកមកប្រើ?

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ឥឡូវយើងត្រឡប់មកនិយាយពីបញ្ហាហ្នឹងវិញ ឥឡូវពេលដែលលោកនិយាយថា អ្នកនិរតីមកធ្វើការនៅក្នុងកងរបស់លោក ពីបីទៅបួនខែដំបូងនោះ តើលោកមានបានដឹងដែរឬទេ ថាតើពួកគេហ្នឹងមានបានស៊ើបអង្កេត ឬក៏មានដឹងថា ពួកគេហ្នឹងមានបានមើលត្រួតពិនិត្យលើឯកសារនៃកងរបស់លោកហ្នឹង ដើម្បីឱ្យដឹងថាពីរបៀបធ្វើការរបស់លោកនោះ? តើលោកមានដឹងទេ ចំណុចអស់ហ្នឹង?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:២២:៤៩]

**2-TCW-1037៖**

**ឆ៖** បាទ ចំណុចអស់ហ្នឹង គឺគេមកហ្នឹង គេមក គេឃើញយើងធ្វើអី គេទៅជាមួយយើងអ៊ីចឹងទៅ។ គេមិនមែនក្នុងនាមជា គេមកដឹកនាំយើងទេ។ ដូចថា គេមកហ្នឹងមកក្នុងនាមស៊ើបអង្កេត មកតាមដានមើល ក្តាប់សភាពការណ៍មើល តើវាមានអ្វីដែលកើតឡើងអ៊ីចឹង គេនឹងរាយការណ៍ហើយ។ បាទ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** គង់ សំអុន គាត់ឆ្លើយថា នៅក្នុងចម្លើយ៣៦នេះ ចម្លើយរបស់គាត់ហ្នឹង ភាសាខ្មែរហ្នឹងគឺគាត់ប្រើពាក្យ"ស៊ើបអង្កេត"។ អ៊ីចឹងសុំឱ្យលោក គង់ សំអុន គាត់ជួយបញ្ជាក់ពាក្យដែលប្រើហ្នឹង ដើម្បីឱ្យអស់មន្ទិលសង្ស័យ។ អ៊ីចឹងពាក្យថា *"អង្កេត"* ហ្នឹងបកជាភាសាខ្មែរថា "ស៊ើបអង្កេត" ហ្នឹងវាត្រូវហើយនៅក្នុងចម្លើយទី៣៦របស់គាត់ហ្នឹង <ដូច្នេះចំណុចនេះវាឆ្លើយនឹងសំណួររបស់សហការីខ្ញុំ>។ ខ្ញុំនៅសល់ពេលវេលាខ្លីណាស់ មុននឹងបញ្ចប់ការសួរសំណួរនេះ។ អ៊ីចឹងមានសំណួរមួយ លោកបាននិយាយអំពីព្រឹត្តិការណ៍ទាក់ទងទៅនឹងជនជាតិវៀតណាមដែលស្ថិតនៅកម្ពុជាប្រជាធិបតេយ្យ ក្រោយពីពេលវៀតណាមមួយចំនួនត្រូវបានគេបញ្ជូនទៅវៀតណាមវិញអស់ហើយ។ ក្រៅពីមនុស្ស<>ដែលលោកបាន<និយាយថា> លាក់គាត់នៅក្នុងព្រៃនោះ អស់មួយរយៈពេលទៅនោះ តើក្រៅពីគាត់ហ្នឹងលោកមានស្គាល់ជនជាតិវៀតណាមផ្សេងទៀតដែរឬទេ? ឬក៏តើនៅក្នុងកន្លែងដែលលោកធ្វើការហ្នឹងមានជនជាតិវៀតណាមផ្សេងទៀតដែរឬទេ?

[១១:២៤:៤៥]

**ឆ៖** តាមខ្ញុំស្គាល់ ក្រុមគ្រួសារជាប់សាច់ឈាមជាកម្ពុជាហ្នឹង មានប្តីខ្មែរ ប្រពន្ធវៀតណាម ប្រពន្ធខ្មែរ ប្តីវៀតណាមហ្នឹង គឺបួនប្រាំគ្រួសារដែរ។ តែខ្ញុំលាក់បានតែមួយគ្រួសារទេ លាក់បានមួយគ្រួសារហ្នឹង ផុតពីហ្នឹងគេចាប់យកទៅអស់។ មុនៗពេល មុនពេលដែលគេកៀរពួកខ្ញុំឡើងមក មករស់នៅក្នុងសហករណ៍ គឺខ្ញុំលាក់បានតែប៉ុណ្ណឹង ហើយលាក់មិនជិតទេ។ ដល់ពេលមកដល់កន្លែងដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង គេហៅថា ព្រែកកាច់រទេះហ្នឹង អាកន្លែងកាច់រទេះហ្នឹង ក៏គេៗរកមុខ ស្រាវជ្រាវរកឃើញទៀត កាលហ្នឹងគេបើកចំហហើយ គឺកម្លាំងទ័ពចុះមកព្រោងព្រាត ជិះទូកជិះកាណូតមកច្រើនណាស់។ គេដើរធ្វើការគ្រប់កន្លែងទាំងអស់ហ្នឹង គេស្រាវជ្រាវហ្នឹង គេរកឃើញហ្នឹង ក៏គេដឹកទូកដឹកកាណូត យកទៅសម្លាប់ចោលបង្ហើយអស់រលីងទៅ។ គឺដែលខ្ញុំខំលាក់ទុកមួយគ្រួសារហ្នឹង គឺទុកអត់

បាន។ តាមខ្ញុំដឹងមានតែប៉ុណ្ណឹង។

**ស៖** លោកនិយាយថាពួកគេមកជិះសេះ ហើយនិងជិះកាណូត តែអម្បាញ់មិញនេះលោកឆ្លើយទៅនឹងព្រះរាជអាជ្ញាហ្នឹង លោកបាននិយាយពីយោធា តើយោធាណាដែរ? ហើយលោកដឹងទេថាអ្នកណាអ្នកចេញបញ្ជាឲ្យចាប់មនុស្សទាំងអស់ហ្នឹង?

**ឆ៖** បាទខ្ញុំអត់ដឹងដែរ ព្រោះកាលនុ៎ងគឺខ្ញុំអស់សិទ្ធិហើយ ខ្ញុំអត់មានតួនាទីអីទេ ជាប្រជាពលរដ្ឋទេ ព្រោះឡើងមកនៅរត់ចេញពីកន្លែងហ្នឹងមក។ ហើយឃើញថាយោធាគេទៅ ហើយមាននិរតីដឹកនាំកម្លាំងទ័ពហ្នឹង បួនប្រាំដណ្តប់នាក់ ទៅទូកពីរបីអីទៅ ទូកតូចៗ ជិះគ្នាបួនប្រាំនាក់។ គេទៅចុះធ្វើការបោសសម្អាតជនជាតិវៀតណាមនៅតាមស្ទឹង តាមទន្លេហ្នឹង។

[១១:២៧:៣៧]

**ស៖** ត្រង់ចំណុចនេះដដែល លោកនិយាយប្រាប់ថាពួកគេហ្នឹង តើនៅពេលចាប់ខ្លួនគ្រួសារវៀតណាមទាំងអស់ហ្នឹង លោកមានវត្តមាននៅទីហ្នឹងដែរឬទេ? ហើយលោកមានបានឃើញយោធាទាំងអស់ហ្នឹងចាប់ជនជាតិវៀតណាមហ្នឹងដែរឬទេ?

**ឆ៖** បាទ ឃើញ ខ្ញុំនៅហ្នឹងដែរ។ គ្រាន់តែលើក -- ខ្ញុំនៅហ្នឹងគេលើកដៃសំពះឲ្យខ្ញុំជួយផង។ ខ្ញុំថាខ្ញុំមិនហ៊ានជួយទេ ខ្ញុំជួយមិនបានទេ ខ្ញុំនេះអ្នករងគ្រោះដូចតែគ្នា យំសស្រែកសស្រាក់ គេហៅឡើងកាណូតទៅ។ ហើយប្តីនោះគេយកទៅសម្លាប់មុន ដល់ក្រោយមកគេយកប្រពន្ធទៅសម្លាប់តាមក្រោយទៀត មួយកូនមួយចៅអស់ហ្នឹងអស់ នៅសល់តែកូនមួយ រត់គេចខ្លួនរស់បានរហូតដល់ឆ្នាំ១៩៧៩ ខ្ញុំទៅជួបនៅនេះ ជួបនៅបន្ទាយមានជ័យ។

**ស៖** តើលោកស្គាល់យោធាដែលចាប់ជនជាតិវៀតណាមទាំងអស់នុ៎ងដែរឬទេ?

**ឆ៖** មិនស្គាល់ទេ ខ្ញុំអត់ស្គាល់ទេ។ ខ្ញុំស្គាល់តែមេដឹកនាំមួយ ខ្ញុំចំណាំចេញចូលៗមកកន្លែងខ្ញុំ គឺឈ្មោះ មិនស្គាល់ឈ្មោះអីទេ គ្រាន់ចំណាំមុខថាគាត់ហ្នឹងនៅធ្វើការនៅកន្លែងភស្តុភារ ធ្វើការនៅកន្លែងភស្តុភារ។

**ស៖** ហើយ<តាំងពីពេលណាដែរ ដែលប្រធាននេះធ្វើការ>ខាងភស្តុភារហ្នឹង? <ដើម្បីឲ្យកាន់តែច្បាស់ តើ>គាត់ធ្វើការភស្តុភារហ្នឹងតាំងពីពេល<>ដែលលោកធ្វើការនៅខាងពាណិជ្ជកម្មហ្នឹង<> ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំទើបឃើញមុខដែរ អ្នកក្រោយហ្នឹងដែលចុះទៅចាប់វៀតណាមហ្នឹង ទើបឃើញមុខមក

ថ្មីទេ។ គឺនិយាយរួមទៅ អត់មានកម្លាំងពាយ័ព្យទេ សុទ្ធតែកម្លាំងមកពីខាងកើតហ្នឹងទាំងអស់។

[១១:៣០:២០]

**ស៖** លោកអត់បានឆ្លើយនឹងសំណួរខ្ញុំទេ។ <តើគាត់នៅក្នុងកងនេសាទរបស់លោក ឬនៅក្នុងកងភស្តុភាររបស់លោក> ពេលដែលលោកធ្វើការនៅ<ទីនោះ>?

**ឆ៖** ឈ្មោះហ្នឹងដែលចុះចាប់ហ្នឹង មិនមែនធ្វើការនៅជាមួយខ្ញុំទេ ខ្ញុំធ្លាប់ឃើញនៅផ្សារលើនៅបាត់ដំបងនេះ។ គាត់ចេញចូលៗនៅកន្លែងសេនាធិការ កន្លែងភស្តុភារ។

**ស៖** គាត់នៅសេនាធិការហ្នឹង កម្រិតណាដែរ ថ្នាក់ណាដែរសេនាធិការហ្នឹង? សំណួរចុងក្រោយរបស់ខ្ញុំហើយ។

**ឆ៖** អត់ដឹងដែរ ឈ្មោះបុគ្គលដែលចុះចាប់ហ្នឹង គឺមិនដឹងតួនាទីគេធ្វើអ្វីទេ ក៏ប៉ុន្តែឃើញគាត់ចេញចូលៗនៅកន្លែងហ្នឹង ធ្វើការនៅកន្លែងហ្នឹង។

**ស៖** លោកនិយាយអំពីមន្ទីរហ្នឹង លោកនិយាយអំពី<មួយណា? លោកនិយាយពី>មន្ទីរសេនា-ធិការ។ អ៊ីចឹងលោកអាចបញ្ជាក់បានទេថា ជាមន្ទីរណា មន្ទីរកងពលលេខ១ មន្ទីរកងពលលេខ២? អ៊ីចឹងសូមលោកជួយបញ្ជាក់បន្តិចមើល ពីមន្ទីរហ្នឹង មន្ទីរមួយណាដែរ?

**ឆ៖** បាទ មន្ទីរសេនាធិការហ្នឹង គឺជាមន្ទីរសេនាធិការរបស់ទ័ពភាគ ជាៗមន្ទីរសេនាធិការដែលៗគ្រប់គ្រងលើកកងពលលេខ១ និងកងពលលេខ២ហ្នឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំសួរចប់ហើយ ហើយពេលវេលាខ្ញុំក៏អស់ដែរ។ សូមអរគុណលោកប្រធាន។

[១១:៣២:៣៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះអរគុណលោកសាក្សី។ សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីដល់ពេលនេះដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ហើយវត្តមានរបស់លោកនៅអ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានមុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកមេធាវី មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី មេធាវីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬគោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយនៅរសៀលនេះអង្គជំនុំជម្រះនឹងចាប់ផ្តើមធ្វើសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ 2-TCE-98។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះ រសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឱ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឱ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៣ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣១:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយបង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញអ្នកជំនាញចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(អ្នកជំនាញចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកអ្នកជំនាញ។ តើលោកឈ្មោះអី?

**លោក ស៊្មីហ្វិន ម៉ររីស៖**

**ឆ៖** ខ្ញុំឈ្មោះ ស៊្មីហ្វិន ម៉ររីស។

**ស៖** អរគុណលោក ម៉ររីស។ តើលោកកើតនៅថ្ងៃខែឆ្នាំណា?

**ឆ៖** ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៥៩។

01386955


**ប្រធានអង្គជំនុំ៖**

អញ្ជើញ! អញ្ជើញ!

[១៣:៣៥:០៧]

**កញ្ញា អង់តា ហ្គិសសេ៖**

សូមអភ័យទោសលោកប្រធាន។ នៅក្នុងការបកប្រែជាភាសាបារាំងនោះ ពេលដែលអ្នកជំនាញឆ្លើយឃ្លាដំបូង ដើមឃ្លាហ្នឹង គឺខាងអ្នកបកប្រែទៅជាភាសាបារាំងហ្នឹង គាត់បកអត់បានទេ។ អ៊ីចឹងសូមឲ្យលោកអ្នកជំនាញហ្នឹងទុកគម្លាតបន្តិច បង្អង់បន្តិចមុននឹងឆ្លើយ ដើម្បីឲ្យអ្នកបកប្រែបានបកប្រែគ្រប់ជ្រុងជ្រោយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អ៊ីចឹងស្រេចនឹងអ្នកបញ្ជាបិទបើកក្បាលមីក្រូហ្វូនសម្រាប់អ្នកជំនាញទេ សូមឲ្យឃ្លាតបន្តិច ព្រោះអ្នកជំនាញមិនមែនអ្នកចុចទេ គឺមានការបើកបិទ សម្របសម្រួលដោយអ្នកបច្ចេក-ទេស។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកមានសញ្ជាតិអ្វីដែរ លោកអ្នកជំនាញ?

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** ខ្ញុំជនជាតិអូស្ត្រាលី។

**ស៖** បាទ អរគុណ។ ហើយសព្វថ្ងៃនេះ លោកមានទីលំនៅអចិន្ត្រៃយ៍នៅទីកន្លែងណា? ហើយលោកប្រកបមុខរបរអ្វីដែរ?

[១៣:៣៦:១៩]

**ឆ៖** អាសយដ្ឋានបច្ចុប្បន្នរបស់ខ្ញុំ ស៊ីលវ័រ ព្រីង, ម៉ារីលែន។ ខ្ញុំជាអ្នកស្រាវជ្រាវ ហើយអ្នកនិពន្ធ ហើយក៏ជាគ្រូបង្រៀននយោបាយអន្តរជាតិ ហើយនិងប្រវត្តិសាស្ត្រ។

**ស៖** បាទ អរគុណ។ ហើយតើលោកគោរពប្រតិបត្តិសាសនាអ្វីដែរ?

**ឆ៖** ខ្ញុំមិនគោរពសាសនាអ្វីទេ។

**ស៖** បាទ អរគុណ។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញថា តាមសមត្ថភាពដែលលោកដឹង និងលោកអាចដឹង និងលោកមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធ

01386956



ជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍នេះពិតជាត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវលោកតុលាការ។

**ស៖** បាទ អរគុណលោក ម៉ររីស។ ដោយអនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៣១(២) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងឋានៈលោកជាអ្នកជំនាញដែលនឹងត្រូវផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសច្ចាប្រណិធានជាមុនសិនតាមជំនឿរបស់ខ្លួន មុននឹងផ្ដល់សក្ខីកម្មជូនអង្គជំនុំជម្រះ។ តើលោកយល់ព្រមដែរទេ?

**ឆ៖** បាទ ខ្ញុំយល់ព្រម។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការលោក ហាសាន់ សូមឡើងធ្វើការណែនាំពីនីតិវិធីធ្វើសម្បថ -- ធ្វើពាក្យសច្ចាប្រណិធានដល់អ្នកជំនាញចំពោះមុខអង្គជំនុំជម្រះ។

[១៣:៣៨:២១]

**ក្រឡាបញ្ជី៖**

ជម្រាបសួរលោកអ្នកជំនាញ សូមលោកក្រោកឈរ ហើយលោកថាតាមខ្ញុំ អ្វីដែលខ្ញុំអាន។ ខ្ញុំសូមសច្ចាប្រណិធានថា ខ្ញុំនឹងជួយអង្គជំនុំជម្រះដោយអស់ពីលទ្ធភាពរបស់ខ្ញុំ។

**លោក ស៊្មីហ្វិន ម៉ររីស៖**

ខ្ញុំសូមស្បថថា ខ្ញុំនឹងជួយអង្គជំនុំជម្រះដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្ញុំ។

**ក្រឡាបញ្ជី៖**

សូមអរគុណ សូមលោកអង្គុយចុះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយអង្គជំនុំជម្រះ និងភាគីសូមថ្លែងអំណរគុណដល់លោកអ្នកជំនាញ ម៉ររីស ដែលបានចំណាយពេលវេលាមានតម្លៃ ហើយបានធ្វើដំណើរមកពីទីឆ្ងាយឯនាយសមុទ្រមកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ ដែលនឹងអាចជួយរួមវិភាគទានដល់អង្គជំនុំជម្រះក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ ពាក់ព័ន្ធនឹងបញ្ហានានាដែលមានសារៈសំខាន់ ក៏សម្រាប់ប្រជាជនកម្ពុជាផងដែរ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាបន្តទៅនេះ យើងខ្ញុំសូមសួរសំណួរបឋមមួយចំនួនពាក់ព័ន្ធនឹងប្រវត្តិនៃការសិក្សា និងស្នាដៃនិពន្ធរបស់លោក។ ហើយដំបូងនេះ ខ្ញុំសូមសួរពាក់ព័ន្ធនឹងការសិក្សា និងស្នាដៃនិពន្ធ។

[១៣:៣៩:៣៦]

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរទេថា លោកបានទទួលការអប់រំ សិក្សាហ្នឹងដល់កម្រិតណាដែរ?

**លោក ស្ទីហ្វិន ម៉ររីស៖**

**ឆ៖** បាទ ខ្ញុំមានថ្នាក់បណ្ឌិតខាងវិទ្យាសាស្ត្រនយោបាយនៅសកលវិទ្យាល័យកូឡុំប៊ី ហើយខ្ញុំមានជំនាញខាងស្រាវជ្រាវនៅសាកលវិទ្យាល័យហាវើត ហើយនៅសាកលវិទ្យាល័យកូឡុំប៊ី ហើយនៅចន ហបគីន នៃសាកលវិទ្យាល័យសិក្សាថ្នាក់ខ្ពស់។ ហើយខ្ញុំក៏មានគុណភាព តាមអង្គហេតុថា នៅក្នុងឆ្នាំ១៩៨៣ ខ្ញុំបានទៅធ្វើទស្សនកិច្ច<នៅតំបន់គ្រប់គ្រងដោយ>ទ័ពព្រៃ<នៅ>កម្ពុជា ហើយខ្ញុំបានជួបមេដឹកនាំបក្សខាងកម្ពុជាប្រជាធិបតេយ្យ ហើយនិងភាគីខាងហ៊្វុនស៊ិនប៉ិច ហើយនិងខាងរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ ដែលច្បាំងជាមួយនឹងវៀតណាម។ ហើយក្រោយមក ខ្ញុំគិតថា ខ្ញុំគឺជាបណ្ឌិតម្នាក់ដែលមានការ មានបទសម្ភាសន៍មួយម៉ោងកន្លះ ដោយជាឯកជនជាមួយព្រះអង្គម្ចាស់នរោត្តមសីហនុ ឆ្នាំ១៩៨៥។ ហើយខ្ញុំ<បាន>បោះពុម្ពសៀវភៅ<យ៉ាងច្រើន មិនមែនតែសៀវភៅមួយដែលបោះពុម្ពដោយ> សាកលវិទ្យាល័យស្តែនហ្វើដ អំពី "មូលហេតុអ្វីដែលវៀតណាមចូលឈ្លានពានកម្ពុជា" <នោះទេ គឺបានបោះពុម្ពនៅក្នុង>ទស្សនាវដ្ដីផ្សេងទៀត<ជាច្រើនផងដែរ ដូចជា *ឌឹអាត្លង់ទិច ម៉ាន់ស្លី* និងសារព័ត៌មានដូចជា *ញូវយ៉កថែមស៍ វ៉ាស៊ីតោនប៉ុស្ត៍*> ហើយនិង<>*វើលស្ទ្រីត ជឺណល* <>។ ហើយខ្ញុំមានសំណាងល្អ ហើយជាសំណាងដ៏ពិសេសដែលអាចបានធ្វើការជាមួយបណ្ណសាររបស់រុស្ស៊ីអំពីសង្គ្រាមវៀតណាម ហើយនិងសង្គ្រាមនៅកម្ពុជា។

[១៣:៤១:៣៥]

**ស៖** បាទ អរគុណ។ ចុះការសិក្សាផ្សេងទៀត តើលោកបានសិក្សាស្រាវជ្រាវអ្វីខ្លះជាក់លាក់ដែលពាក់ព័ន្ធនឹងកម្ពុជា ជាពិសេសទាក់ទងផ្ទាល់ទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** បាទ ខ្ញុំគិតថា សៀវភៅរបស់ខ្ញុំ "មូលហេតុដែលវៀតណាមឈ្លានពានកម្ពុជា" គឺជាសៀវភៅដែលពាក់ព័ន្ធបំផុត ទាក់ទងនឹងការសិក្សារបស់ខ្ញុំ ដែលមាននិយាយអំពីឯកសារសម្ភារៈជាប្រភព

01386958



ដែលខ្ញុំជម្រាបជូនលោកប្រធាន ប៉ុន្តែខ្ញុំបានសរសេរច្រើនអំពីបទពិសោធន៍នានារបស់ខ្ញុំ ជាមួយកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីឆ្នាំ១៩៧៩ គឺមិនបទពិសោធន៍មុនឆ្នាំ១៩៧៩ទេ។ ប៉ុន្តែសៀវភៅរបស់ខ្ញុំមានការវិភាគអំពី<របប>លក្ខណៈនៃកម្ពុជាប្រជាធិបតេយ្យ<> ហើយឲ្យមានការបកស្រាយរបស់ខ្ញុំថាតើហេតុអ្វីបានគេប្រព្រឹត្តតាមបែបដែលគេបានប្រព្រឹត្តនោះ។

**ស៖** បាទ អរគុណ។ ហើយមុននឹងបន្តទៀត សូមស្នើសុំអ្នកជំនាញថា សូមលោកអ្នកជំនាញឆ្លើយតបឲ្យបានយឺតៗ ជាងនេះបន្តិច ក្នុងគោលបំណងដើម្បីឲ្យចម្លើយតបរបស់លោកហ្នឹង គឺឆ្លងកាត់ការបកប្រែភាសាហ្នឹងបានពេញលេញ ហើយនិងបានល្អ។ ហើយចំពោះនិក្ខេបបទដែលលោកបានលើកឡើងអំមិញនេះ អំពីប្រភពនៃ -- ពាក់ព័ន្ធនឹងបញ្ហានេះសិន បញ្ហាថា និក្ខេបបទថ្នាក់បណ្ឌិតរបស់លោកអ្នកជំនាញដែលមានចំណងជើងថា "ប្រភពដើមនៃសម្ព័ន្ធភាពរវាងសហភាពសូវៀត និងវៀតណាម" ហើយចំពោះនិក្ខេបបទបណ្ឌិតរបស់លោកដែលមានចំណងជើង "ប្រភពដើមនៃសម្ព័ន្ធភាពរវាងសហភាពសូវៀត និងវៀតណាម" នោះ តើលោកបានចាប់ផ្តើមសិក្សាស្រាវជ្រាវនិក្ខេបបទនេះនៅពេលណាដែរ? ហើយហេតុអ្វីបានជាលោកសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ហើយនិងធ្វើជានិក្ខេបបទសម្រាប់បញ្ចប់ថ្នាក់បណ្ឌិតរបស់លោក?

[១៣:៤៤:១២]

**ផ៖** ខ្ញុំបានចាប់ផ្តើមការសិក្សា ការងាររបស់ខ្ញុំនៅក្នុងឆ្នាំ១៩៧៩ ឬឆ្នាំ១៩៨០។ ខ្ញុំមិនចាំជាក់លាក់ទេ ដែលខ្ញុំចាប់ផ្តើមការស្រាវជ្រាវប្រហែលជា១៩៧៩ ឬក៏១៩៨០។ មូលហេតុនៃការចាប់អារម្មណ៍ក្នុងប្រធានបទនេះ គឺថាផ្អែកលើអង្គហេតុដែលខ្ញុំបានទៅវៀតណាមក្នុងសម័យសង្គ្រាម នៅក្នុងឆ្នាំ១៩៧០ ហើយនៅក្នុងឆ្នាំ១៩៧២។ ខ្ញុំបានឃើញស្ថានភាពនៅក្នុងវៀតណាម ហើយខ្ញុំដឹងថា ស្ថានភាព គឺវាខុសគ្នាឆ្ងាយពីអ្វីដែលខ្ញុំជឿជាក់។ ដូច្នេះហើយខ្ញុំតែងតែមានការប៉ុនប៉ង ផ្អែកការសិក្សារបស់ខ្ញុំមួយផ្នែកទៅលើបរិបទផ្ទាល់ដែលប្រជាជន ដែលជាអ្នកកសាងប្រវត្តិសាស្ត្រ ដែលខ្ញុំចង់សរសេរអំពីរឿងហ្នឹង។ ដូច្នេះការចាប់អារម្មណ៍របស់ខ្ញុំទៅលើសម្ព័ន្ធភាពសូវៀត-វៀតណាម ដែលជាប្រភពដើមហ្នឹង គឺកើតចេញមកពីការចាប់អារម្មណ៍របស់ខ្ញុំលើសង្គ្រាមវៀតណាម។ ហើយមួយផ្នែកគឺផ្អែកទៅលើការបណ្តុះបណ្តាលរបស់ខ្ញុំទៅលើការសិក្សាអំពីសូវៀតនៅសាកលវិទ្យាល័យកូឡុំប៊ី ដែលនាំឲ្យខ្ញុំបានសរសេរបរិមាធិប្បាយថ្នាក់ឌុកទ័រ ហើយទទួលបាននូវថ្នាក់បណ្ឌិត។

**ស៖** បាទ អរគុណ។ ហើយនិក្ខេបបទរបស់លោកហ្នឹងផ្តោតទៅលើបញ្ហាអ្វីដែលសំខាន់ អ្វីខ្លះ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅ? ហើយលោកអាចឆ្លើយដោយសង្ខេប ត្រួសៗដល់អង្គជំនុំជម្រះបានហើយ ព្រោះយើងខ្ញុំសួរសំណួររបស់លោកជាបឋមដើម្បីបញ្ជាក់អំពីភាពពាក់ព័ន្ធ និងស្នាដៃនិពន្ធផ្សេងៗរបស់លោកតែប៉ុណ្ណោះ។

[១៣:៤៦:២៥]

**ឆ៖** មួយផ្នែកនោះ គឺការឆ្លើយតបទៅនឹងការជឿជាក់ដែលថា វៀតណាមតែងតែអះអាងថា ឯករាជ្យពីនយោបាយបរទេស ដែលខ្ញុំពិនិត្យមើលថា ការអះអាងបែបនោះមិនត្រឹមត្រូវ។ ហើយវៀត-ណាមបាន<ផ្លាស់គ្នា>គាំទ្រចិន <និង>គាំទ្រសហភាពសូវៀត<> នៅក្នុងសម័យកាលខ្លីនៅក្នុងឆ្នាំ ១៩៦០នោះ គឺថានៅកណ្តាលនៃរបបកុម្មុយនីស្តទាំងពីរនេះ។ ដូច្នេះហើយការសិក្សាអំពីសម្ព័ន្ធភាព សូវៀត-វៀតណាមនេះគឺថាផ្អែកលើគំនិតដែលថា វៀតណាមមិនតែងតែរក្សាអព្យាក្រឹតភាពរវាងអំណាច សហភាពសូវៀត និងចិន<ដែលជាគូសត្រូវប្រជែងអំណាចសង្គមនិយម>នោះទេ<គឺសហភាពសូវៀត និងចិន>។ ហើយពេលខ្លះវៀតណាមនោះក៏ប្រកាន់ម្ខាង ពេលខ្លះម្ខាងទៀត គឺរវាងសហភាពសូវៀតនិង ប្រទេសចិន។ ហើយចំណុចដែលច្បាស់ ហើយនិងប្រាកដដែលជាឧទាហរណ៍ដែលគេចូលខាងម្ខាងនោះ គឺគេធ្វើសេចក្តីសម្រេច គឺចុះហត្ថលេខាសន្ធិសញ្ញាសហប្រតិបត្តិការជាមួយសហភាពសូវៀតនៅក្នុងឆ្នាំ ១៩៧៨ គឺមុនពេលដែលពួកគេឈ្លានពានប្រទេសកម្ពុជា។

**ស៖** អរគុណ។ ហើយជាចុងក្រោយនេះពាក់ព័ន្ធនឹងសៀវភៅដែលមានចំណងជើងថា "ហេតុ អ្វីបានប្រទេសវៀតណាមឈ្លានពានកម្ពុជា វប្បធម៌ នយោបាយ និងបុព្វហេតុនៃសង្គ្រាម" លោកបាន បញ្ជាក់អំពីស្នាដៃនិពន្ធរបស់លោកនេះហើយ។ ហើយចំពោះសៀវភៅរបស់លោកដែលមានចំណងជើង ថា "ហេតុអ្វីបានប្រទេសវៀតណាមឈ្លានពានកម្ពុជា វប្បធម៌ នយោបាយ និងមូលហេតុនៃសង្គ្រាម" នេះ តើលោកចាប់ផ្តើមសិក្សាស្រាវជ្រាវអំពីបញ្ហានេះនៅពេលណា? ហើយលោកចាប់ផ្តើមបោះពុម្ព សៀវភៅនេះជាលើកដំបូងនៅឆ្នាំណាដែរ?

[១៣:៤៨:៤០]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** ចាំ! ចាំ! ចាំបន្តិច!

**ឆ៖** ខ្ញុំចាប់ផ្តើមការសិក្សាស្រាវជ្រាវ ដើម្បីសរសេរសៀវភៅគឺភ្លាមៗបន្ទាប់ពីបញ្ចប់និក្ខេបបទ របស់ខ្ញុំឆ្នាំ១៩៨៧ ប្រហែលជាឆ្នាំ១៩៨៨ ឬក៏១៩៨៩។ សៀវភៅគឺត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ១៩៩៩ ដោយសាកលវិទ្យាល័យស្ទែនហ្វើដ ហៅថា *ស្ទែនហ្វើដ យូនីវើស៊ីធី ប្រេស*។

**ស៖** អរគុណ។ ហើយតើលោកប្រើប្រាស់នូវវិធីសាស្ត្រអ្វីខ្លះនៅក្នុងការសិក្សាស្រាវជ្រាវ ដើម្បីសរសេរសៀវភៅនេះ? ហើយប្រភពណាខ្លះដែលលោកយកមកធ្វើជាមូលដ្ឋានក្នុងការសរសេរ? និងថាតើលោកបានជួបសម្ភាសជាមួយនឹងបុគ្គលសំខាន់ៗប៉ុន្មាននាក់? ហើយបុគ្គលនោះឈ្មោះអ្វីខ្លះដែរ?

**ឆ៖** បាទ ខ្ញុំបានសម្ភាសបុគ្គលសំខាន់ៗមួយចំនួន គឺបុគ្គលដ៏សំខាន់បំផុត ជាពិសេសគឺសម្ដេចព្រះនរោត្តម សីហនុ នៅក្នុងប្រទេសថៃ នៅក្នុងឆ្នាំ១៩៨៥។ ខ្ញុំក៏បានសម្ភាសផងដែរ លោក អៀង សារី ជាអតីតរដ្ឋ<មន្ត្រី>ក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា នៅភូមិភាគខាងលិច នៅខែកញ្ញា ឆ្នាំ១៩៨៣។ ពេលនោះខ្ញុំមានការងារមួយ ទាក់ទងជាមួយនឹងសារព័ត៌មានស៊ី.ប៊ី.អេស ជាសារព័ត៌មានរបស់សហរដ្ឋអាមេរិក ធ្វើការក្នុងប្រទេសកម្ពុជា គឺជាមូលហេតុសំខាន់ ដែលខ្ញុំមានលទ្ធភាពសម្ភាសលោក អៀង សារី ប៉ុន្តែបទសម្ភាសន៍នោះ គឺគ្រាន់ជាផ្នែកមួយនៃវិធីសាស្ត្រមួយរបស់ខ្ញុំប៉ុណ្ណោះទេ។ ខ្ញុំបានសិក្សាប្រភពទី២ជាច្រើន <គឺអក្សរសាស្ត្រទាំងអស់ដែល>ទាក់ទងទៅនឹងនិក្ខេបបទ ឬក៏សំណេរនានាទាក់ទងនឹងគាត់។ ហើយលើសពីហ្នឹងទៀត ខ្ញុំមានលទ្ធភាពមើលឯកសារនៅក្នុងនៅក្នុងបណ្ណសារនៃអតីតសហភាពសូវៀតដែលត្រឡប់ទៅឆ្នាំ១៩៣០ នៅពេលដែល ហូ ជីមិញ បានបង្កើតបក្សកុម្មុយនីស្ត<ឥណ្ឌូចិន>។ ខ្ញុំមានលទ្ធភាពអានឯកសារនៅទីក្រុងមូស្គូ ដែលសរសេរដោយវៀតណាមកុម្មុយនីស្តដែលពាក់ព័ន្ធទៅនឹងប្រទេសកម្ពុជា។ ហើយក៏កំណត់ត្រាបទសម្ភាសន៍របស់មេដឹកនាំកុម្មុយ-នីស្តវៀតណាម ដែលមន្ត្រីសហភាពសូវៀត<>អ្នកធ្វើសម្ភាសន៍ដែលពាក់ព័ន្ធទៅនឹងបញ្ហារបស់ប្រទេសកម្ពុជា។ ដូច្នេះជាប្រភពនានាផ្សេងៗមួយចំនួន ដែលខ្ញុំបានប្រើ។

[១៣:៥១:៥៥]

**ស៖** បាទ អរគុណ។ ហើយអំមិញ លោកបាននិយាយដល់ យោងទៅកិច្ចសម្ភាសន៍រវាងលោកជាមួយនឹងព្រះបរមកោដ្ឋនរោត្តម – រតនកោដ្ឋ នរោត្តម សីហនុ ហើយនិងធ្វើកិច្ចសម្ភាសន៍ជាមួយនឹងលោក អៀង សារី អតីតជារដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជាប្រជាធិបតេយ្យ។ សំណួរសួរថា កាលពីម្សិលមិញ លោកបានទទួលព័ត៌មានពីខាងអង្គភាពគាំពារសាក្សីនៅនេះ ស្នើសុំឲ្យលោកផ្ដល់នូវកំណត់ត្រាកិច្ចសម្ភាសន៍នោះដែរឬទេ? ហើយលោកមានយកមកជាមួយទេ នូវកំណត់ត្រាកិច្ចសម្ភាសន៍ឥស្សរជនទាំងពីររូបនេះ?

**ឆ៖** បាទ ខ្ញុំបានទទួលសំណើសុំច្បាប់ចម្លងនៃកំណត់ត្រានេះ ដែលខ្ញុំបានកត់ត្រាក្នុងពេលសម្ភាស។ ជាអកុសល ខ្ញុំបាននៅប្រទេសកម្ពុជារួចមកហើយ ហើយឯកសារប្រភពរបស់ខ្ញុំនោះ នៅឯ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01386961



សហរដ្ឋអាមេរិកឯនោះទាំងអស់ ខ្ញុំអត់បានយកមកទេ។ ដូច្នេះខ្ញុំមិនអាច<>ទៅរកយកឯកសារនោះមកពីកន្លែងណាបានទេ។

**ស៖** បាទ អរគុណ។ មិនអីទេ ហើយអរគុណដែលបានផ្តល់នូវការឆ្លើយបំភ្លឺយ៉ាងច្បាស់លាស់ពីបញ្ហានេះ។ ហើយដើម្បីគាំទ្រដល់ការចងក្រងសៀវភៅរបស់លោកនេះ តើលោកប្រើប្រាស់សម្ភារៈដែលផ្តល់ឲ្យដោយអ្នកស្រាវជ្រាវផ្សេងៗដទៃទៀតដែរឬទេ? ហើយប្រសិនបើមាន តើសម្ភារៈអ្វីខ្លះ?

[១៣:៥៣:៥១]

**ឆ៖** ឯកសារ ហើយនិងសំណេរ<របស់អ្នកស្រាវជ្រាវផ្សេងៗទៀត ដែលខ្ញុំបានប្រើ។> គឺថាមានឧបករណ៍ គឺមិនមានទេ គឺថាអ្នកស្រាវជ្រាវផ្សេង គេមានឧបករណ៍ គឺឧបករណ៍ដែលខ្ញុំប្រើហ្នឹងគឺគ្រាន់តែមានកាមេរ៉ា ហើយនិងអ្នកថតកាមេរ៉ាដែលសម្អាសលោក អៀង សារី ដែលមកពីក្រុមហ៊ុនស៊ី.ប៊ី.អេស ទូរទស្សន៍ ស៊ី.ប៊ី.អេស សហរដ្ឋអាមេរិក ហើយនិងមានកាសែតអាត់សំឡេងជាមួយនឹងព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ផងដែរ។ ប៉ុន្តែជាទូទៅ ខ្ញុំបានប្រើស្នាដៃរបស់អ្នកសិក្សាស្រាវជ្រាវផ្សេងទៀត ដែលផ្តល់ជាមូលដ្ឋាននៃការងារស្រាវជ្រាវរបស់ខ្ញុំ។

**ស៖** បាទ អរគុណ។ ហើយអ្នកជំនាញ តើហេតុអ្វីបានជាលោកមានចំណាប់អារម្មណ៍ខ្លាំងក្នុងការសិក្សាស្រាវជ្រាវ ហើយនិងនិពន្ធនូវសៀវភៅដែលមានចំណងជើង "ហេតុអ្វីបានជាវៀតណាមឈ្លានពានកម្ពុជា វប្បធម៌ នយោបាយ និងមូលហេតុនៃសង្គ្រាម" នេះឡើង?

**ឆ៖** ខ្ញុំចាប់អារម្មណ៍ក្នុងការងារនេះ ដោយហេតុថា ខ្ញុំបានចាប់អារម្មណ៍ជាយូរណាស់មកហើយ អំពីកិច្ចការនយោបាយវៀតណាមនិងកម្ពុជា។ ហើយខ្ញុំចង់ដឹងពីមូលហេតុ ថាតើ<ហេតុអ្វីបានជា>អតីតសម្ព័ន្ធភាពទាំងពីរនេះបានក្លាយទៅជាគូសត្រូវក្នុងសង្គ្រាមនឹងគ្នា។ ហើយជាពិសេស នៅពេលដែលខ្ញុំយល់ឃើញថា មិនមែនជាអត្ថប្រយោជន៍របស់ភាគីទាំងពីរទេ ក្នុងការច្បាំងនេះ។ ខ្ញុំក៏ស្វែងរកសេចក្តីពន្យល់ អ្វីជាចំណុចនៅពីក្រោយនេះ ដែលថានាំឲ្យមានសង្គ្រាមរវាងវៀតណាម និងកម្ពុជាជាចំណុចចម្ងល់ ខ្ញុំសិក្សាដើម្បីដោះស្រាយនូវចម្ងល់នេះ។

[១៣:៥៦:០៣]

**ស៖** បាទ អរគុណ។ ហើយសំណួរចុងក្រោយរបស់ខ្ញុំ ថាតើលោកអាចសង្ខេបខ្លីៗបានដែរឬទេអំពីព្រឹត្តិការណ៍សំខាន់ៗដែលលោកបានសរសេរនៅក្នុងសៀវភៅនេះ នៅក្នុងសៀវភៅស្នាដៃនិពន្ធរបស់លោក ដែលលើកបានជាប្រធានបទនៃការពិភាក្សាចុងក្រោយអម្បាញ់មិញនេះ? តើលោកអាចសង្ខេប

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដោយខ្លីៗបានទេ នូវព្រឹត្តិការណ៍សំខាន់ៗដែលលោកបានលើកឡើងនៅក្នុងសៀវភៅនិពន្ធរបស់លោក ដែលយើងបានពិភាក្សាគ្នាអម្បាញ់មិញនេះ? លោកចាំដែរទេ?

**ឆ៖** ជាមូលដ្ឋាន ខ្ញុំព្យាយាមពន្យល់អំពីវិធីដែលបក្សកុម្មុយនីស្ត<វៀតណាម>ប៉ុនប៉ងចង់ត្រួតត្រាចលនាកុម្មុយនីស្តរបស់ប្រទេសទាំងបីនៃឥណ្ឌូចិន។ ខ្ញុំក៏មានបំណងចង់ពន្យល់អំពីរបៀបដែលថាវៀត-ណាមបាត់បង់<ការ>ត្រួតត្រាលើចលនាកុម្មុយនីស្តនៅកម្ពុជាទោះបីជាគេមានចេតនាចង់ត្រួតត្រាយ៉ាងណាក៏ដោយ។ ហើយខ្ញុំក៏ចង់ចង្អុលបង្ហាញអំពីជម្លោះរវាងវៀតណាម ហើយនិងកម្ពុជា ដែលបានចាប់ផ្តើមក្នុងអំឡុងពេលសង្គ្រាមរវាងរបបមួយដែលគាំទ្រសហរដ្ឋអាមេរិក ដែលថាកុម្មុយនីស្តវៀតណាម និងកុម្មុយនីស្តខ្មែរច្បាំងគ្នានៅកាលនោះផង។ ហើយនៅក្នុងគំនិតមួយដែលខ្ញុំបញ្ជាក់ច្បាស់នៅពេលដែលសត្រូវសំខាន់របស់កុម្មុយនីស្តវៀតណាមហ្នឹង គឺសហរដ្ឋអាមេរិកនោះ។ ហើយ<និយាយម្យ៉ាងទៀត នៅពេលដែលសត្រូវចម្បងរបស់កុម្មុយនីស្តវៀតណាម និង>កុម្មុយនីស្តខ្មែរ <គឺសហរដ្ឋអាមេរិក និងរបបដែលគាំទ្រដោយអាមេរិកនៅក្នុងប្រទេសវៀតណាម និងកម្ពុជានោះ យ៉ាងណាក៏ដោយ>កុម្មុយ-នីស្តខ្មែរក៏ទទួលស្គាល់ថា <>វៀតណាមកុម្មុយនីស្តជាសត្រូវសំខាន់របស់គេ<>។ ជាពិសេសទៅទៀត ខ្ញុំបញ្ជាក់បង្ហាញអំពីវិធីដែលកុម្មុយនីស្តវៀតណាមមិនដែលយល់អ្វីដែលកើតឡើងនៅកម្ពុជាទាំងអស់នោះទេ ដែលនាំឲ្យគេយល់ច្រឡំថា អ្នកណាជាអ្នកគាំទ្រគេ អ្នកណាជាអ្នកប្រឆាំងនឹងគេនោះ។

[១៣:៥៨:៣០]

ហើយនៅទីបំផុត <គឺ>វិធីអ្វីដែលគេពឹងផ្អែកទៅលើជំនួយរបស់សហភាពសូវៀត ដើម្បីអនុវត្ត <នូវ>អ្វីដែលគេសន្និដ្ឋានថា <ជាភាពចាំបាច់>ត្រូវឈ្លានពាន ឬក៏លុកលុយនៅខែធ្នូ ឆ្នាំ១៩៧៨។ ប៉ុន្តែប្រធានបទសំខាន់នៅក្នុងសៀវភៅរបស់ខ្ញុំ គឺថាភាគីទាំងអស់ យ៉ាងហោចណាស់បក្សកុម្មុយនីស្តកម្ពុជា និងបក្សកុម្មុយនីស្ត<វៀតណាម> ហើយនិងចិនកុម្មុយនីស្តយល់ច្រឡំអំពីស្ថានភាពរបស់ពួកគេ ហើយគេបានចាត់វិធានការដោយមិនមានមូលហេតុសមស្រប ហើយបណ្តាលឲ្យមានផលវិបាកដែលមិនស្ថិតនៅក្នុង ឬក៏មិនបម្រើផលប្រយោជន៍ដល់គេទេ។ ហើយក៏វាជះជាផលវិបាកអវិជ្ជមានចំពោះភាគីទាំងអស់ដែលជាភាគីក្នុងវិវាទដែលខ្ញុំបានបញ្ជាក់ខាងដើម។

មូលហេតុដែលខ្ញុំបញ្ជាក់ទាំងនេះ ពីព្រោះថារបបកម្ពុជាប្រជាធិបតេយ្យត្រូវបានផ្តួលដោយវៀតណាម ហើយវៀតណាមជាអ្នកអុជអាលចិនដើម្បីឲ្យវាយប្រហារគេ។ ប៉ុន្តែចិនយល់ច្រឡំទំនាក់ទំនងជាក់ស្តែងរបស់វៀតណាម ហើយនិងសហភាពសូវៀត ទាក់ទងទៅនឹងប្រភពដើមនៃជម្លោះនោះ។

ហើយមានការយល់ច្រឡំជាច្រើន ការយល់ខុសជាច្រើន ហើយខ្ញុំក៏ព្យាយាមពន្យល់សរសេរនៅក្នុងសៀវភៅនេះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយនៅក្នុងការសួរដេញដោលអ្នកជំនាញរូបនេះ អនុវត្តតាម -- ស្អីគេនុ៎ង?

*(មានបញ្ហាបច្ចេកទេស)*

[១៤:០១:០៨]

បាទ ជាបន្តទៀត មានបញ្ហាកាសខាងឧបករណ៍បកប្រែភាសាមានចូលសំឡេងភាសាអន្តរជាតិមកខាងភាសាខ្មែរ។

ដដែលទេៗ នៅដដែលទេ សូមដោះស្រាយបញ្ហាបច្ចេកទេស។

*(មានបញ្ហាបច្ចេកទេស)*

ហើយនៅក្នុងការសួរដេញដោលទៅអ្នកជំនាញរូបនេះ អនុវត្តតាមបទប្បញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី នួន ជា ក្នុងការសួរដេញដោលអ្នកជំនាញនេះ មុនភាគីដទៃទៀតនៃរឿងក្តី។ សហមេធាវីការពារក្តី នួន ជា រួមទាំងមេធាវីការពារក្តី ខៀវ សំផន មានរយៈពេលបួនវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ -- អ្នកជំនាញរូបនេះ។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងអ្នកជំនាញផងដែរ។ មុននឹងខ្ញុំចាប់ផ្តើម ខ្ញុំមានបញ្ហាតូចមួយពាក់ព័ន្ធទៅនឹងឯកសារ ដែលតុលាការបានទទួលយក ប៉ុន្តែតាមដែលខ្ញុំយល់ហ្នឹង គឺថាមិនទាន់មានលេខជា E3 នៅឡើយទេ ដែលបញ្ជាក់ទៅលើឲ្យឯកសារហ្នឹង ប្រហែលជាអាចនឹងត្រូវបញ្ជាក់ ពីព្រោះខ្ញុំនឹងប្រើឯកសារនេះនៅថ្ងៃនេះ និងថ្ងៃស្អែកផងដែរ លោកប្រធាន។

[១៤:០៣:០១]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដោយបានជម្រាបបែបនេះហើយ លោក ម៉ររីស ខ្ញុំមានសំណួរជាច្រើនដែលខ្ញុំចង់សួរទៅ

01386964



លោក។ ជាអកុសលនោះ យើងមានពេលតែមួយថ្ងៃប៉ុណ្ណោះទេ សម្រាប់មេធាវីការពារក្តី។ អ៊ីចឹងខ្ញុំសូមអនុញ្ញាតជម្រាបលោកដោយ<សង្ខេប>អំពីវិធីដែលខ្ញុំចង់សួរសំណួរទៅលោក អំពីប្រធានបទណាខ្លះផ្នែកណាខ្លះ <ដើម្បីឲ្យលោក>ដឹងជាមុន។ អ៊ីចឹងនិយាយពីរបៀបដែលខ្ញុំនឹងត្រូវអនុវត្តទៅ។ ហើយខ្ញុំនឹងសួរសំណួរលោកមួយចំនួនអំពី ជាពិសេសគឺអំពីប្រភពឯកសារ និងវិធីសាស្ត្រ។ បន្ទាប់មកខ្ញុំនឹងសួរពិភាក្សាជាមួយលោក អំពីថាតើសៀវភៅដែលអំពីចក្រពត្តិនិយម ហើយនិងប្រទេសវៀតណាម ហើយនិងខ្ញុំសួរសំណួរទាំងអស់នេះ គឺពាក់ព័ន្ធទៅនឹងសហព័ន្ធឥណ្ឌូចិន ហើយនិងមហិច្ឆតារបស់<សម្រាប់សហព័ន្ធ>ឥណ្ឌូចិន ហើយនិងអំពីអាកប្បកិរិយារបស់ជនជាតិវៀតណាមចំពោះខ្មែរនៅក្នុងពេលចរចានានាជាទូទៅ។

អ៊ីចឹងប្រធានបទទី៤របស់ខ្ញុំ គឺមនោគមន៍វិជ្ជាកុម្មុយនីស្តវៀតណាមពាក់ព័ន្ធទៅនឹង ចំពោះសហភាពសូវៀត ហើយនិងជំហររបស់មេដឹកនាំបក្សកុម្មុយនីស្តវៀតណាម។ បន្ទាប់មកខ្ញុំនឹងសួរប្រធានបទសំខាន់សម្រាប់មេធាវីការពារក្តី គឺអំពីវិធីដែលមហិច្ឆតារបស់ចក្រពត្តិនិយម <ឬក៏ការប៉ុនប៉ងបង្កើត> សហព័ន្ធឥណ្ឌូចិន<មួយ> ដែលគេយកមកអនុវត្តនៅក្នុងកម្ពុជា ជាពិសេសនៅក្នុងចលនាបដិវត្តន៍នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីនោះទៅទៀត ខ្ញុំនឹងលើកឡើងអំពីប្រធានបទដែលលោកបាននិយាយដោយសង្ខេបមកហើយ អំពីប្រតិកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាទៅនឹងការប៉ុនប៉ងរបស់វៀត-ណាមចំពោះ<>កម្ពុជា<ប្រជាធិបតេយ្យ>។ ហើយខ្ញុំនឹង<ពិភាក្សាអំពី>ពាក្យដែលលោកប្រើក្នុងសៀវភៅរបស់លោក ដែលគេប្រើពាក្យថា <ត្រដេវរិច ឥរិយាបថមិនសមហេតុផលជាដើម ឬក៏ដូចដែលលោកបាននិយាយថា ហេតុ>អ្វីដែលគេប្រព្រឹត្ត មូលហេតុអ្វី<បានជាគេបានធ្វើ។> អ៊ីចឹងគឺថាបន្ទាប់ទៀត<ខ្ញុំចង់ពិភាក្សាជាមួយលោកអំពី>នយោបាយបរទេសរបស់វៀតណាមចំពោះចិន ហើយនិងពីចិនមកវៀតណាមមកវិញ។

[១៤:០៦:០២]

<ហើយបន្ទាប់មកទៀត>ខ្ញុំ<ចង់ពិភាក្សាបញ្ហាមួយចំនួនតូចអំពីកូនក្តីរបស់ខ្ញុំ គឺ>លោក នួន ជា <អំពីបញ្ហាដែល>លោកបាន<រកឃើញ>នៅក្នុងបណ្ណសារសហភាពសូវៀត ទាក់ទងទៅនឹង<គាត់។ ហើយបន្តមកទៀត ដោយសង្ខេបបំផុត ខ្ញុំចង់ដឹងអំពីប្រតិកម្មចំពោះវៀតណាមក្រោយពីការឈ្លានពានរបស់ពួកគេ ដូច្នេះគឺប្រធានបទសង្ខេបមួយអំពីទស្សនៈ>ក្រោយពីឆ្នាំ១៩៧៩ <ហើយនិងជំហររបស់ពិភពលោក>ចំពោះវៀតណាម<>។ ហើយក្រោយមក<ខ្ញុំនឹងបញ្ចប់ ហើយបើខ្ញុំនៅមានពេល> យើង

នឹងនិយាយអំពីការទំនាក់ទំនងការទូតរវាងកម្ពុជាប្រជាធិបតេយ្យចំពោះប្រទេសមួយចំនួន ជាឧទាហរណ៍ យើងនិយាយអំពីការប៉ុនប៉ងរបស់វៀតណាមដើម្បីចាប់ជំរិតយកសម្ដេច នរោត្តម សីហនុ នៅ<ដើមឆ្នាំ ១៩៧៩> ហើយនិងប្រធានបទមួយចំនួនទៀត។ អ៊ីចឹងនេះជាសេចក្ដីសង្ខេបដ៏វែងមួយ គឺសូមអភ័យទោស ដើម្បីធ្វើយ៉ាងម៉េចឲ្យលោកបានយល់ ថាតើខ្ញុំនឹងត្រូវដើរទៅផ្លូវណា។

អ៊ីចឹងលោក ម៉ររីស ខ្ញុំនឹងចាប់ផ្ដើមដោយសំណួរមួយចំនួនអំពីប្រភព។ នៅក្នុងសៀវភៅរបស់លោក លោកបានធ្វើបញ្ជីនូវប្រភពទី២ទាំងឡាយរបស់លោក។ សៀវភៅទាំងនោះ ភាគីបានដឹងបានស្គាល់ហើយ យើង<អាចធ្វើ*ម៉ៃក្រូហ្វីស*ផ្នែកខ្លះនៃ>និក្ខេបបទរបស់លោក<>។ អ៊ីចឹងគឺថាយើងមិនទាន់មានប្រភពពិតប្រាកដដែលលោកប្រើសម្រាប់សៀវភៅរបស់លោក<ទេ>។ អ៊ីចឹងគឺថា តើ<វាជាការសមហេតុផលទេក្នុងការនិយាយថា សៀវភៅរបស់លោក ក្នុងន័យនៃពាក្យថា>ប្រភពទី២ <គឺ>វាផ្អែក <បន្ថែមទៀត>លើប្រភព<ដែលបានប្រើប្រាស់>ដើម្បីសរសេរសៀវភៅរបស់លោក ឬយ៉ាងដូចម្ដេច?

[១៤:០៨:២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សូមទោសលោក។>

**ប្រធានអង្គជំនុំ៖**

ទាន់! កុំអាលទាន់!

**លោក ស៊្ទីហ្វិន ម៉ររីស៖**

**ឆ៖** បាទគឺត្រឹមត្រូវហើយ គឺផ្អែកលើប្រភពទាំងឡាយដែលបានប្រើរួចហើយនៅក្នុងនិក្ខេបបទ ហើយនិងការផ្ដោតអារម្មណ៍នៅក្នុងសៀវភៅខុសពីអ្វីដែលសង្កត់ធ្ងន់នៅក្នុងនិក្ខេបបទ។

**ស៖** ខ្ញុំនឹងនិយាយពីប្រធានបទនេះនៅពេលបន្តិចខាងមុខនេះ។ ខ្ញុំសូមសួរលោកនូវសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងប្រភពទី២ដែលលោកបានយកមកប្រើ។ ជាពិសេសគឺយើងមិនអាចយកមកពិភាក្សាទាំងអស់បានទេ។ គឺថាមានអ្នកបណ្ឌិតជនជាតិអាមេរិកាំងមួយចំនួនដែល<ខ្ញុំគិតថាលោក>ប្រើ<ជាពិសេសនៅក្នុង>សៀវភៅរបស់លោក គឺក្នុងចំណោមនោះមានបញ្ញវន្តអាមេរិកាំងម្នាក់គឺ<> ដូក្លាស <ផាយ> ដែលជាអតីតរដ្ឋមន្ត្រីការបរទេសនោះ។ តើ ដូក្លាស <ផាយ> ហ្នឹងគាត់ជាអ្នកណា? ហើយតើលោកបានប្រើបណ្ណសាររបស់គាត់ដូចម្ដេចដែលលោកយកមកប្រើក្នុងការសរសេរនៅក្នុងសាកលវិទ្យាល័យប៊ឺកឃ្លី នៅសហរដ្ឋអាមេរិកនោះ?

[១៤:០៩:៤០]

**ឆ៖** ដូក្លាស <ផាយ> ហ្នឹងគឺជាមន្ត្រីក្រសួងការបរទេស ជាអតីតមន្ត្រីហ្នឹងគឺថាគាត់មានជំនាញខាងប្រទេសវៀតណាម។ គាត់បានមកដល់ប្រទេសវៀតណាមនៅក្នុងសម័យសង្គ្រាមរវាងសហរដ្ឋអាមេរិក និងវៀតណាមខាងជើង។ ហើយគាត់បានប្រមូលឯកសារភស្តុតាងជាច្រើនក្នុងពេលដែលគាត់ធ្វើការឲ្យរដ្ឋាភិបាលសហរដ្ឋអាមេរិក។ ហើយគាត់បានដាក់ចូលទៅក្នុងបណ្ណសារនៃសកលវិទ្យាល័យប៊ឺកឃ្លីនៃរដ្ឋកាលីហ្វ័រញ៉ា ដែលខ្ញុំមានឱកាសបាននៅទីនោះពីរឆ្នាំ ក្នុងការស្រាវជ្រាវដើម្បីធ្វើនិក្ខេបបទរបស់ខ្ញុំ។ ខ្ញុំគិតថា លោក ផាយ<> នេះគឺជាមនុស្ស អ្នកដែលពូកែប្រមូលព័ត៌មានអង្គហេតុដែលចេញពីប្រភពទាំងឡាយទាំងអស់ ហើយគាត់បានធ្វើការរៀបចំដែលនិយាយអំពីទិនានុប្បវត្តិ ឬកាលានុប្បវត្តិអំពី<ឥណ្ឌូ>ចិន <ដែលបានសង្ខេបរាល់ការសរសេរចុងក្រោយបំផុតអំពីឥណ្ឌូចិន> ហើយគាត់ក៏បានប្រមូលនូវព័ត៌មានអំពីហេតុការណ៍ ព្រឹត្តិការណ៍<នៅក្នុងប្រទេស>វៀតណាម <ឡាវ> និងកម្ពុជាដើម្បីឲ្យអ្នកអានហ្នឹងអាចតាមដានអានបានស្រួល។

**ស៖** សំណួរបន្ថែមទៀត ហើយខ្ញុំដឹងថា លោកក៏បានដឹងដែរថា គាត់បានធ្វើសក្ខីកម្មចំពោះព្រឹទ្ធសភាអាមេរិក គឺថានៅក្នុងតុលា ឬវិច្ឆិកា ឆ្នាំ១៩៧៨ គេសួរមតិគាត់អំពីបញ្ហាស្មុគស្មាញរវាងទំនាក់ទំនងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាម។ តើលោកដឹងដែរឬទេ ថាតើមូលហេតុអ្វីបានជាព្រឹទ្ធសភាសហរដ្ឋអាមេរិក ហៅគាត់ទៅសួរដេញដោលអំពីរឿងហ្នឹង?

**ឆ៖** ខ្ញុំមិនដឹងពីមូលហេតុច្បាស់លាស់ទេ ប៉ុន្តែខ្ញុំជឿថា ប្រហែលមកពីគេបានស្វែងរកប្រភពព័ត៌មានដែលមានគ្រប់ចំណុចទាំងអស់ អំពីវិបត្តិដែលបានកើនឡើងនៅក្នុងឥណ្ឌូចិន រវាងកម្ពុជានិងវៀតណាម ហើយលោក ផាយក៏ គឺជាបុគ្គលដែលត្រូវតែកោះអញ្ជើញឲ្យធ្វើសក្ខីកម្ម រឿងនេះ។

[១៤:១២:០៥]

**ស៖** សូមអរគុណចំពោះចម្លើយ។ ប៉ុន្តែនៅក្នុងសៀវភៅរបស់លោក ERN 01001662 លោកបាននិយាយទៅរកអ្នកប្រាជ្ញបណ្ឌិតអាមេរិកាំងម្នាក់ទៀត ដែល<ខ្ញុំនឹង>សួរ<អំពីកិច្ចការងាររបស់គាត់នេះផង>ដែរ លោកហៅគាត់ថា ជាទស្សនវិទូដ៏ល្បីគឺ វីល្លៀម ដាយគ័រ។ សូមលោកពន្យល់តុលាការបន្ថែម អំពីវិធីដែលលោកប្រើនូវស្នាដៃរបស់គាត់នៅក្នុងសៀវភៅគាត់នោះ ជាប្រភពរបស់លោកដែរនោះ។

**ឆ៖** ខ្ញុំនឹកឃើញថា ខ្ញុំប្រើស្នាដៃរបស់លោក ដាយ<គ័រ> នេះនៅក្នុងកន្លែងខ្លះ ក៏ប៉ុន្តែខ្ញុំមិន

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រាកដថា គាត់មានសារៈសំខាន់ប៉ុន្មាននៅក្នុងការអះអាង<ទូទៅ>របស់ខ្ញុំទេ។

**ស៖** ខ្ញុំនឹងត្រឡប់មកបញ្ហានេះម្តងទៀត នៅពេលដែលខ្ញុំចង់ប្រើសេចក្តីសង្កេតនៅក្នុងសៀវភៅរបស់គាត់នេះ ដើម្បីសួរ។ ប៉ុន្តែតាមពិត នៅក្នុងសាលាក្តីនេះ យើងបានដឹងយ៉ាងច្រើនអំពីស្នាដៃរបស់ណាយ៉ាន់ ចាន់ដា, ប៉ែន យៀរនិន, ឆេនដ័ល័រ ហើយស៊ីវ ហេដឌ័រ ហើយនិងអ្នកផ្សេងទៀតដែរ។ អ៊ីចឹងខ្ញុំសួរលោកដោយសង្ខេបនូវសំណួរមួយចំនួន ពីដំបូងគឺចាប់ផ្តើមពី ប៉ែន យៀរនិន។ តើត្រឹមត្រូវដែរឬទេគឺថា លោកមិនមែនជា គឺថាមិត្តដ៏ល្អរបស់ ប៉ែន យៀរនិន ទេ តើអ៊ីចឹងដែរឬទេ?

**ឆ៖** នេះគឺជាការយល់ត្រឹមត្រូវ។

**ស៖** ខ្ញុំនឹងសួរបន្តទៅទៀត។ ខ្ញុំដឹងមូលហេតុថា ហេតុម៉េចបានជាយ៉ាងដូច្នេះ ប្រហែលជាសាធារណជនខ្មែរមិនដឹងទេ។ ខ្ញុំនឹងសួរលោក ប៉ុន្តែតើលោកអាចពន្យល់បន្តិចបានទេថា នេះជាការកត់សម្គាល់មួយដែលត្រឹមត្រូវ?

[១៤:១៤:២៨]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់!

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** ខ្ញុំជឿជាក់ថា ប៉ែន យៀរនិន គឺជាមនុស្សម្នាក់ដែលចូលចិត្តរឿងនយោបាយ ហើយតែងតែមានរបៀបវារៈនយោបាយហ្នឹងយ៉ាងខ្លាំងៗ ជាពិសេសក្នុងអំឡុងពេលដែល ប៉ុល ពត គ្រប់គ្រងអំណាច គាត់ជាអ្នកគាំទ្រដ៏ខ្លាំងទៅដល់របបកម្ពុជាប្រជាធិបតេយ្យ។ ហើយទើបតែវៀតណាមប្រឆាំងជាមួយនឹងកម្ពុជាប្រជាធិបតេយ្យនោះទេ ទើប ប៉ែន យៀរនិន ក្លាយទៅជាអ្នកទិតៀន រិះគន់ទៅដល់ ប៉ុល ពត ហើយនិងខ្មែរក្រហម។ ហើយក្រោយមកទៀត ប៉ែន យៀរនិន បានប្រកាន់ជំហរមួយដែលថាអាចមានសម្ព័ន្ធមួយខ្លាំងជាប់ពាក់ព័ន្ធជាមួយវៀតណាម ពាក់ព័ន្ធទៅនឹងបកស្រាយព្រឹត្តិការណ៍ចំពោះប្រទេសកម្ពុជា។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ហើយតើត្រឹមត្រូវដែរឬទេ ថាលោកបានប្រឆាំងជាមួយនឹងការតែងតាំងគាត់ឲ្យធ្វើជានាយករបស់អង្គការមួយ ហៅថា "មជ្ឈមណ្ឌលឯកសារកម្ពុជា"?

**ប្រធានអង្គជំនុំ៖**

រង់ចាំសិន! រង់ចាំ!

[១៤:១៥:៤៩]

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** ខ្ញុំអត់បានដឹងថា គាត់ធ្លាប់ធ្វើជានាយករបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។ លោកយោងទៅអង្គការណាផ្សេង មជ្ឈមណ្ឌលណាមួយផ្សេង?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមទោសៗ ខ្ញុំមានន័យថា យើងត្រូវមានការជាប់ទាក់ទងជាមួយនឹងយ៉ែល គឺថាមានការតែងតាំង<គាត់ដោយក្រសួងការបរទេស ក្នុងកម្មវិធី>ប្រល័យពូជសាសន៍ <ដែលខ្ញុំជឿថា តាំងពីដំបូងនោះបានធ្វើការ>ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ <ប៉ុន្តែសូមកុំនិយាយអំពីមជ្ឈមណ្ឌលឯកសារកម្ពុជាអី សូមនិយាយពីអ្វីដែលលោកថា ជាការតែងតាំងដោយក្រសួងការបរទេសនោះ។>

**ឆ៖** ខ្ញុំយល់ថា ក្រសួងការបរទេសគឺបានផ្តល់ថវិការមកដល់ ប៉ែន ឃៀរនិន គឺកន្លះលានដុល្លារ ហើយក្រោយមកទៀត ផ្តល់ចំនួន១លានដុល្លារ គឺជារឿងមួយគួរឲ្យសោកស្តាយ ដោយថាគាត់មិនមែនជាមនុស្សដែលល្អបំផុត សម្រាប់ធ្វើការសិក្សាស្រាវជ្រាវនូវអ្វីដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជា ចន្លោះពី៧៥ ទៅ៧៨នោះទេ។ តាមពិតមានបេក្ខជនល្អដទៃទៀត ដូចជា ដេវីដ ហក ជាដើម ដែលបានធ្វើការជាមួយ<អង្គការលើកលែងទោសអន្តរជាតិ> ហើយដែលខ្ញុំជឿថា ជាមនុស្សដែលមានអ្នក -- ជាអ្នកដែលវិភាគចំៗចំណុចតែម្តង។ ហើយមិនមែនជាមនុស្សម្នាក់ដែលមានតែរឿងបញ្ហានយោបាយរាល់ពេលនោះទេ។

**ស៖** សូមអរគុណ។ សំណួរមួយទៀត ជាប់ពាក់ព័ន្ធទៅនឹងមនុស្សម្នាក់ដែលមកផ្តល់សក្ខីកម្មជាសាក្សី ហើយក៏ជាអ្នកជំនាញអំពីបក្សកុម្មុយនីស្តកម្ពុជា គឺលោក ដេវីដ ឆេនដ៍ល័រ។ ខ្ញុំឆ្ងល់ថា ខ្ញុំចង់ដឹងថាតើលោកធ្លាប់បានអាន<ទស្សនៈរបស់គាត់ អំពី>សៀវភៅរបស់លោក "ថាហេតុអ្វីបានជាវៀតណាមឈ្លានពានប្រទេសកម្ពុជា" ដែលបានបោះពុម្ពផ្សាយភ្លាមៗ ក្រោយសៀវភៅនោះបោះពុម្ពនោះ តើលោកមានដឹងអំពីបញ្ហានេះទេ? ហើយបើលោកដឹង តើលោកមានប្រតិកម្មយ៉ាងដូចម្តេចចំពោះអ្វីដែលគាត់បាននិយាយពាក់ព័ន្ធទៅនឹងសៀវភៅរបស់លោក?

[១៤:១៨:១១]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមលោកផ្ដល់លេខឯកសារយោងផង។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ គឺឯកសារនេះ មិនទាន់មានលេខ E3 នៅឡើយទេ គឺ01335287 គឺវាភ្ជាប់មកជាមួយនឹងសំណើសុំរបស់យើងខ្ញុំ គឺឯកសារ E445។

**លោក ស្ទីហ្វិន ម៉័ររីស៖**

**ឆ៖** ខ្ញុំដឹងអំពីការពិនិត្យមើលសៀវភៅរបស់ខ្ញុំពីសំណាក់ ដេវីដ ឆេនដ៍ល័រ។ <ខ្ញុំគិតថាគឺទស្សនាវដ្ដី "*ឌីជីណាល អូហ្វ អាស៊ាន ស្ដាឌី*>។ ខ្ញុំមានអ្នកសិក្សាស្រាវជ្រាវមួយទៀតថាជា ថាសៀវភៅនោះ វាមានចំណុចល្អច្រើន ក៏មានចំណុចមិនល្អនោះច្រើនផងដែរ។ ប៉ុន្ដែមតិយោបល់ខ្ញុំទៅលើ នេះគឺថា ដោយសារ ដេវីដ ឆេនដ៍ល័រ មិនដែលលើកឡើងអំពីចំណុចដែលមិនល្អនៅក្នុងសៀវភៅនេះទេ។ គាត់បានលើកឡើងថា វាមានព័ត៌មានច្រើនមកពីបណ្ណសាររបស់សហភាពសូវៀតដែលយកមកសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំ <ដែលមិនអាចរកបាននៅកន្លែងផ្សេង>។ ដូចជាអ្នកប្រវត្តិសាស្ត្រដទៃទៀតផងដែរ ឬក៏ថាអ្នកប្រវត្តិសាស្ត្រខ្លះដែលបានពិនិត្យមើលសៀវភៅរបស់ខ្ញុំ គឺការរិះគន់ គឺគេរិះគន់ទៅលើវិទ្យាសាស្ត្រនយោបាយរបស់ខ្ញុំ មិនមែនរឿងប្រវត្តិសាស្ត្រនោះទេ <ដែលខ្ញុំយល់ថាជាការចំអកទៅលើអំណះអំណាងរបស់ខ្ញុំ ថាមិនបានពិចារណាពី>ចំណុចកណ្ដាល ចំណុចស្នូលនៃជម្លោះនៅក្នុងឥណ្ឌូចិននេះ <ជាជាង>ភាពរឹងមាំ<និងសច្ចភាព>នៃការ<អះអាង>របស់ខ្ញុំ <ដែលគ្មាននរណាជំទាស់ ហើយខ្ញុំជឿថា មិនមាននរណាអាចជំទាស់បាន>។

[១៤:២០:១១]

**ស៖** ឥឡូវខ្ញុំសូមចូលទៅប្រភពសំខាន់មួយទៀត សម្រាប់ការសិក្សាស្រាវជ្រាវរបស់លោកនេះ ហើយលោកប្រធានក៏ទើបតែសួរមួយចំណុចហើយទៅលើបញ្ហានេះ។ ហើយ<វាជាការសម្ភាសជាមួយបុគ្គល>សំខាន់<ៗ គឺសំខាន់នៅពេលនោះ>។ លោកបានលើកឈ្មោះរបស់គាត់ហើយ លោកបានសម្ភាសជាមួយសម្ដេចនរោត្ដម សីហនុ។ ខ្ញុំចាប់អារម្មណ៍ពិសេស<ទៅលើបទសម្ភាសន៍មួយដែលលោកបានធ្វើ ខ្ញុំជឿថា តាមនិក្ខេបបទរបស់លោក> គឺទាំងនៅប៉ារីស ទាំងនៅទីក្រុងវ៉ាស៊ីតោន គឺលោកបានជួបជាមួយនឹង<> ទ្រុង ង៉ុក តាំង ជាថ្នាក់ដឹកនាំជាន់ខ្ពស់របស់វៀតណាម<ខាងត្បូង>។ ខ្ញុំនឹងសួរលោកឲ្យច្រើនអំពី ទ្រុង ង៉ុក តាំង នេះ បើខ្ញុំអានមិនច្រឡំទេ។ ប៉ុន្ដែតើលោកអាចជម្រាបជូនតុលាការ

ឲ្យបានលម្អិតបន្តិចបានទេជុំវិញកិច្ចសម្ភាសន៍របស់លោកជាមួយគាត់? ជាពិសេសពាក់ព័ន្ធទៅនឹងសំណួររបស់អង្គជំនុំជម្រះ លោកប្រធានដែលទើបសួរហើយ តើលោកមានកំណត់ត្រានៃកិច្ចសម្ភាសន៍ទាំងអស់នេះទេ? ហើយយ៉ាងហោចណាស់ក៏លោកសូមរៀបរាប់បានលម្អិតបន្តិចឲ្យបានដឹង ថាតើ ទ្រុង ង៉ុក តាំង នេះជាអ្នកណាផងដែរ?

**ឆ៖** ទ្រុង ង៉ុក តាំង ជាអតីតមន្ត្រីជាន់ខ្ពស់របស់រណសិរ្សរំដោះជាតិ។ គាត់ តាមដែលខ្ញុំដឹងនេះគឺថាគាត់មិនមែនសមាជិករបស់កុម្មុយនីស្តវៀតណាមនោះទេ គាត់ជាសមាជិកនៃរណសិរ្សជួរមុខរបស់បក្សកុម្មុយនីស្តវៀតណាម។ គាត់ជាបញ្ញវន្តមួយរូប ហើយគាត់ហ្នឹងនៅក្នុងឆ្នាំ១៩៧០ហ្នឹង គឺគាត់មិនពេញចិត្តវៀតណាមក្រោយការដណ្តើមអំណាចហ្នឹង គាត់មិនពេញចិត្តទេ គាត់ក៏រត់ទៅប្រទេសបារាំងទៅ ដោយសារតែគាត់គឺជាបុគ្គលម្នាក់ដែលលេចធ្លោ។ ហើយម្នាក់ទៀតឈ្មោះ ប៊ុយ ធៀន ជាអ្នកធ្វើនៅខាងសារព័ត៌មាន<កងទ័ព> ហើយខ្ញុំសម្ភាសដែរ ក៏គាត់ក៏ជាសមាជិកបក្សកុម្មុយនីស្តវៀតណាមដែរ។

[១៤:២២:៥១]

**ស៖** ខ្ញុំនឹងត្រឡប់មកសួរលោកអំពី ទ្រុង ង៉ុក តាំង ហើយនិងដកសម្រង់<ចេញពីសារណា>របស់គាត់ <ហើយខ្ញុំជឿលើបទសម្ភាសន៍របស់លោក>។ ក៏ប៉ុន្តែចំពោះលោកវិញ លោកនៅមានកំណត់ត្រាដែលលោកបានសម្ភាសជាមួយគាត់ទេ ឬក៏កំណត់ត្រានោះទៅណាបាត់អស់ហើយ?

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនមានកំណត់ត្រាដែលខ្ញុំបានសម្ភាសនោះ ខ្ញុំបានជួបគាត់បីបួនដងដែរ ហើយជំនួបខ្លះគឺថាក្រៅផ្លូវការ។ គាត់ជាមិត្តភក្តិរបស់ជនជាតិវៀតណាមម្នាក់ដែលជាមិត្តភក្តិរបស់ខ្ញុំ អ៊ីចឹងខ្ញុំអាចទាក់ទងជួបគាត់បានជាញឹកញាប់ នៅពេលដែលគាត់ទៅលេងនៅសហរដ្ឋអាមេរិក។ ដូច្នេះខ្ញុំជួនកាលខ្ញុំអត់បានគិតថា ខ្ញុំចាំបាច់កត់ត្រាអីទេ។

**ស៖** តើគាត់នៅរស់រានមានជីវិតទេសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។

**ស៖** ឥឡូវខ្ញុំសូមចូលទៅប្រភពដែលសំខាន់បំផុត គឺបណ្ណសាររបស់សូវៀតនេះ។ ខ្ញុំនឹងសួរលោកសង្ខេបទេ លោកបានលើកពីចំណុចនេះមកសរសេរក្នុងសៀវភៅរបស់លោក។ យើងបានរកឃើញថាមានការបោះពុម្ពផ្សាយមួយទៀត គឺលោកជាអ្នកធ្វើការបោះពុម្ពផ្សាយហៅថា "ត្រីកោណមានសូវៀត ចិន និង វៀតណាម <នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧០>"។ <ឯកសារនេះមិនទាន់មានលេខ

E3 នៅឡើយទេ ប៉ុន្តែវាត្រូវបានទទួលស្គាល់ជាភស្តុតាងរួចហើយ។> ជាពិសេសខ្ញុំយោងទៅលើ ERN ជាភាសាអង់គ្លេស 01335245 ក្នុងនោះគឺមានលេខយោងជើងទំព័រ<លេខ២> ដែលលោករៀបរាប់យ៉ាងច្រើនថា កិច្ចការនេះត្រូវបានធ្វើសម្រេចដោយរបៀបណានៅបណ្ណសាររបស់សូវៀតនោះ <ហើយនិងការបែងចែករវាងឯកសារដែល>គេអនុញ្ញាតឲ្យមើល <និង>ឯកសារ<ដែលគេមិនអនុញ្ញាតឲ្យលោកមើល>។ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះ ថាលោកបានធ្វើអ្វីខ្លះនៅឯបណ្ណសារនោះ? ហើយថាតើគេបានរៀបចំឲ្យលោកមានលទ្ធភាពចូលទៅបណ្ណសារហ្នឹងបានដោយរបៀបណា?

[១៤:២៥:២៤]

**ឆ៖** លទ្ធភាពដែលខ្ញុំអាចចូលទៅបណ្ណសារនេះបាននេះ គឺវាកើតមានឡើងក្រោយពេលសហភាពសូវៀតនោះដួលរលំ នៅពេល បូរីស យែលស៊ីន ដែលជាប្រធានាធិបតីសហភាពសូវៀត បានសម្រេចធ្វើការស៊ើបអង្កេតទៅលើឧក្រិដ្ឋកម្មរបស់អតីតបក្សកុម្មុយនីស្តសូវៀត។ ក្រោយមកទៀត ក្រោយពេលលោក បូរីស យែលស៊ីន ប្រមូលបានអ្នកជំនាញមួយក្រុម<ដែលភាគច្រើនជាជនជាតិរុស្ស៊ី> ដើម្បីឲ្យស៊ើបអង្កេតអំពីបក្សកុម្មុយនីស្តសូវៀតនេះ គឺមានអ្នកសិក្សាស្រាវជ្រាវជាច្រើន បានស្នើសុំទៅពិនិត្យមើល<បណ្ណសារនោះផងដែរ។> ក្នុងនោះរួមទាំង<កម្មវិធីប្រវត្តិ>សង្គ្រាមត្រជាក់<អន្តរ-ជាតិ របស់មជ្ឈមណ្ឌល *វីលសុន សិនធ័រ* នៅ>ទីក្រុងវ៉ាស៊ីនតោនផងដែរ ក៏សុំទៅពិនិត្យផងដែរ។ ហើយពួកគាត់គឺថារៀបចំចាត់ចែងឲ្យអ្នកទទួលបានលទ្ធភាពចូលទៅមើល ពាក់ព័ន្ធទៅនឹងប្រវត្តិសាស្ត្រនៃសង្គ្រាមត្រជាក់។ ពីដើមដំបូង ខ្ញុំអត់បានដឹងរឿងនេះទេ ខ្ញុំទៅទីក្រុងមូស្គូ តាមរយៈខ្លួនខ្ញុំផ្ទាល់ទេ ជាដំណើរឯកជនរបស់ខ្ញុំទេ។ <ខ្ញុំបានដឹងពីកម្មវិធីរបស់*វីលសុន សិនធ័រ*> ហើយក្រោយការខិតខំប្រឹងប្រែងជាច្រើនមក ខ្ញុំក៏បាន<រួមចំណែកក្នុង>កម្មវិធីមួយនេះ។ អ៊ីចឹងយើងក៏បានស្នើសុំឯកសារមួយចំនួនពីបក្សកុម្មុយនីស្តនៃសហភាពសូវៀត ពីគណៈមជ្ឈិម ក៏ដូចជាស្នើសុំទៅកាន់ក្រសួងការបរទេស គឺវាអាស្រ័យទៅលើមន្ត្រីដែលធ្វើការនៅបណ្ណសារនោះទេ ដែលជាអ្នកសម្រេច ថាតើអ្នកស្រាវជ្រាវ ក្នុងនោះមានខ្ញុំម្នាក់ដែរ អនុញ្ញាតឲ្យពិនិត្យមើលឯកសារនេះបានដោយរបៀបណានោះ។

[១៤:២៧:២៣]

គម្រោងនិយាយអំពីប្រវត្តិសាស្ត្រនៃសង្គ្រាមត្រជាក់នេះ មិនមែនផ្តោតតែលើវៀតណាម និងកម្ពុជាទេ។ ខ្ញុំគឺជាបុគ្គលតែម្នាក់គត់ ដែលបានពាក់ព័ន្ធនៅក្នុងការស្រាវជ្រាវ តែអំពីរឿងវៀតណាម និងកម្ពុជា។ ដូច្នេះខ្ញុំមើលឧបសម្ព័ន្ធផ្សេងៗ ខ្ញុំមើលសំណុំឯកសារ ខ្ញុំមើលឯកសារណាដែលពាក់ព័ន្ធទៅនឹង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រវត្តិសាស្ត្រកម្ពុជា និងវៀតណាម ហើយក៏ស្នើសុំពិនិត្យមើលឯកសារនៅតាមលំដាប់លំដោយ។ មានព័ត៌មានយ៉ាងច្រើនសន្ធឹកសន្ធាប់នៅទីនោះ។ ហើយភាគច្រើននោះ គេ<អនុញ្ញាត>ឱ្យខ្ញុំ<អាចចូលមើលអ្វីៗបានទាំងអស់ ដែលខ្ញុំបានស្នើ>សុំ<>។ មានការបដិសេធសំណើខ្ញុំ តែពីរបីសំណើទេ ប៉ុន្តែអនុញ្ញាតឱ្យខ្ញុំលើកឡើងថា អ្នកដែលធ្វើសេចក្តីសម្រេច ថាតើអ្នកណាត្រូវពិនិត្យមើលឯកសារអី វាមិនមែនពាក់ព័ន្ធទៅនឹងអ្នកជំនាញ ទៅលើអ្នកស្រាវជ្រាវគឺអ្នកដែលស៊ើបអង្កេតទេ។ ដូច្នេះគេអាចដឹងអ្វីដែលសំខាន់អ្វីដែលមិនសំខាន់នៅក្នុងឯកសារហ្នឹង គេដឹង។

លើសពីនេះទៅទៀត ការស្នើសុំពិនិត្យមើលឯកសារទាំងអស់ហ្នឹង គឺវាមានភាពទូលំទូលាយដែលខ្ញុំមិនអាចជឿជាក់ថា គេអាចអានឯកសារនេះពេញលេញបានទេ <មុនគេផ្តល់ឯកសារទាំងនេះដល់អ្នកស្រាវជ្រាវនោះ>។ ដូច្នេះលទ្ធភាពរបស់ខ្ញុំទទួលបាននូវការពិនិត្យមើលឯកសារទាំងអស់នេះ គឺថាគេមានការពិនិត្យពិច័យខ្ញុំតិចតួចទេ។ ខ្ញុំគិតថា ហេតុផលដែលថាគេបដិសេធហ្នឹង គឺវាអាចមានការពាក់ព័ន្ធ ឯកសារពាក់ព័ន្ធទៅនឹងកា.ហ្សេ.បេ ភ្នាក់ងារផ្សេងៗ អាហ្នឹងវាអាចតឹងតែង។ ដូចដែលខ្ញុំ ខ្ញុំមានឯកសារតិចតួចណាស់ ដែលគេបានបដិសេធសំណើរបស់ខ្ញុំ ប៉ុន្តែឯកសារទាំងអស់ដែលខ្ញុំបានស្រាវជ្រាវហ្នឹង គឺមកពីគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តសូវៀតនោះ។

[១៤:២៩:៣៦]

**ស៖** តាមដែលខ្ញុំយល់នោះ គឺថាគេមិនអនុញ្ញាតឱ្យលោកពិនិត្យមើល ឬក៏ទទួលបាននូវឯកសារពាក់ព័ន្ធទៅនឹងការិយាល័យ<នយោបាយរបស់គណៈមជ្ឈិមទេ>។ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ។

**ស៖** ហើយហ្នឹងក៏ដូចគ្នាដែរ លោក គេមិនឱ្យលោកមើលបណ្ណសារផ្សេងៗរបស់ប្រធានាធិបតីទេ មែនទេ?

**ឆ៖** បណ្ណសាររបស់ប្រធានាធិបតី គឺជារឿងមួយផ្សេង គឺគេមិនឱ្យមើលទេ។

**ស៖** តើលោកអាចរៀបរាប់ជាសង្ខេបបន្តិចបានទេ? ខ្ញុំគិតថា--

**ប្រធានអង្គជំនុំ៖**

ទំនងជាមានបញ្ហាឧបករណ៍សំឡេង។

*(មានបញ្ហាបច្ចេកទេស)*

អញ្ជើញ! អញ្ជើញតទៀតលោកមេធាវី!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ អរគុណលោកប្រធាន។ សំណួររបស់ខ្ញុំអំពីរបៀបដែលលោក<>ធ្វើការ <នៅពេល>លោកទៅស្រាវជ្រាវនៅបណ្ណសារនោះ។ តើត្រឹមត្រូវដែរឬទេថា គេមិនអនុញ្ញាតឲ្យលោកធ្វើការថតចម្លងទេ គឺឲ្យតែកត់ត្រានូវឯកសារដែលគេបង្ហាញមកឲ្យលោកទេ ត្រឹមត្រូវទេ?

[១៤:៣១:២៩]

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** មិនត្រឹមត្រូវទេ មិនមែនគេមិនឲ្យខ្ញុំថតចម្លងទេ។ <ប៉ុន្តែដូច>អ្នកណាដែលចូលមកធ្វើការក្នុងគម្រោងហ្នឹងយឺតពេល ហើយមិនមានឈ្មោះនៅក្នុងផែនការដើមនោះ ខ្ញុំមិន<ត្រូវបានគេផ្តល់> នូវ<កូតានៃ>ឯកសារខ្លះៗ<ដែល>អ្នកស្រាវជ្រាវ<ផ្សេងទៀតត្រូវបាន>គេថតចម្លង<ឲ្យ>។ <ខ្ញុំគិតថាគេបានអនុញ្ញាតឲ្យខ្ញុំថតចម្លងប្រហែលជា>១០០ទំព័រ <ខណៈដែល>អ្នកស្រាវជ្រាវខ្លះគឺថាអាចមានលទ្ធភាពថតបានដល់រាប់ពាន់ទំព័រ។ អ៊ីចឹងខ្ញុំត្រូវកត់ត្រាឲ្យបានច្រើនបំផុត សរសេរដោយដៃតែម្តង។ វិធីសាស្ត្ររបស់ខ្ញុំ ឯកសារទាំងអស់នេះសំខាន់ណាស់។ ខ្ញុំសរសេរ<>ឯកសារជាភាសារុស្ស៊ីតែម្តង ហើយសឹមបកប្រែតាមក្រោយ។

**ស៖** ខ្ញុំសុំសួរឧទាហរណ៍មួយជាក់លាក់ដែលវាទើបតែ ខ្ញុំនឹកឃើញអម្បាញ់មិញនេះ។ នៅក្នុងសៀវភៅរបស់លោក លោកបានយោងទៅប្រតិចារឹកមួយ<នៃ>ការសន្ទនាមួយ ឬក៏ថាឯកសារមួយដែលពាក់ព័ន្ធទៅនឹងសន្ទនា<រវាង>អគ្គលេខាធិការបក្សកុម្មុយនីស្តវៀតណាមឈ្មោះ ឡេ យន់ ឬក៏ ឡេ យ័ន ដែលតាមគេហៅនោះ ហើយនិងឯកអគ្គរដ្ឋទូតសូវៀតមួយ គឺថាមានការសន្ទនាគ្នាមួយចំនួន<>។ តើលោកនៅមានឯកសារ<>ថតចម្លង<នោះទេ> ឬក៏<>គ្រាន់តែ<កំណត់>ត្រា<ដែលលោកបានកត់ចម្លងពីឯកសារទាក់ទងនឹងការសន្ទនានេះ>ទេ<>?

**ឆ៖** <នេះអាចជាកំណត់>ត្រា<ដែលខ្ញុំបានកត់ ប្រហែលជា>សរសេរដោយដៃ<ជាភាសារុស្ស៊ី គឺជាការ>ចម្លង<ផ្នែក>ខ្លះ<នៃឯកសារនោះ>។

[១៤:៣៣:៣៣]

**ស៖** ខ្ញុំសុំសួរឲ្យច្បាស់លាស់បន្តិច។ នៅពេលមួយ <-- ខ្ញុំជឿថាគឺ>នៅក្នុងឆ្នាំ១៩៧៦ <ហើយគាត់និយាយម្តងទៀតនៅឆ្នាំ>៧៨ <--> ឡេ យន់ បានប្រាប់ទៅឯកអគ្គរដ្ឋទូតសូវៀតថា "នួន ជា គឺជាមនុស្សរបស់យើង។ គាត់ជាមិត្តភក្តិផ្ទាល់របស់ខ្ញុំ"។ យើងនឹងត្រឡប់មកនិយាយអំពីចំណុចនេះ។ តើ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកមានឯកសារជាក់លាក់នេះ<ទេ ដូច្នេះបើលោកមានឆន្ទៈធ្វើដូច្នោះ -- យើងនឹងអាចពិនិត្យមើល> ឯកសារនេះ<> ឬក៏ថាលោក<មានកំណត់>ត្រា<នេះ>ទេ<>?

**ឆ៖** ខ្ញុំនឹកមិនឃើញ១០០ភាគរយដែរ ក៏ប៉ុន្តែ<ខ្ញុំជឿថា វាជា>ប្រតិចារឹកមួយដែលសរសេរជាភាសារុស្ស៊ី<នៅក្នុងការសរសេរដោយផ្ទាល់ដៃរបស់ខ្ញុំ ដូច្នេះ>បើសិនណាជាខ្ញុំ<>រក<ឃើញ>ឯកសារនោះ ខ្ញុំអាច<កត់ត្រា>ដោយដៃរបស់ខ្ញុំជាភាសារុស្ស៊ីនោះ។

**ស៖** ក៏ប៉ុន្តែលោកមិនមានឯកសារដើមជាភាសារុស្ស៊ីដែល ឡេ យន់ និយាយទៅកាន់ឯកអគ្គរដ្ឋទូតសូវៀតថា "នួន ជា គឺជាមនុស្សរបស់យើង" អីអ៊ីចឹងទេ? លោកមានឯកសារហ្នឹងទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកចេះនិយាយ និងចេះសរសេរភាសារុស្ស៊ី<ច្បាស់លាស់>ទេ?

**ឆ៖** ខ្ញុំអាចសរសេរ និងនិយាយបាន ខ្ញុំមិន<>និយាយដល់ថ្នាក់ល្អមែនទែននោះទេ។

**ស៖** <ដូច្នេះបើយើង>មានសំណួរជាក់លាក់មួយចំនួនពាក់ព័ន្ធទៅនឹងពាក្យជាភាសារុស្ស៊ីដែលប្រើនៅក្នុងពេលសន្ទនានេះ <ឧទាហរណ៍> ដូចជា ឡេ យន់ គាត់លើកឡើងមកនិយាយ<អំពី នួន ជា> នោះ តើលោក<ប្រាប់យើងពី>ពាក្យរុស្ស៊ីចំៗតែម្តងបានទេ ជាភាសារុស្ស៊ី ហើយក្រោយមកបានបកប្រែជាភាសាអង់គ្លេសតាមក្រោយបានទេ?

[១៤:៣៥:៥៥]

**ឆ៖** ខ្ញុំអាច ៗធ្វើអ៊ីចឹងជូនលោកបាន។

**ស៖** សំណួរមួយចំនួនពាក់ព័ន្ធទៅនឹងការងាររបស់លោកនៅក្នុងបណ្ណសាររុស្ស៊ី ខ្ញុំអានសៀវភៅរបស់លោក<ឃើញថា>លោកមាន ឌីមីទ្រី ម៉ូស្យាកូស ហ្នឹងជួយធ្វើការឲ្យលោកផងដែរ ត្រឹមត្រូវទេ? ហើយបើសិនជាអ៊ីចឹងមែន តើគាត់ជួយធ្វើអ្វីលោក?

**ឆ៖** ត្រឹមត្រូវហើយ។ គាត់អានឯកសារដែលខ្ញុំមានចំណាប់អារម្មណ៍ហ្នឹង ហើយប្រាប់ខ្ញុំថាមួយណាដែលខ្ញុំគួរតែអាន។ អាចចាត់ទុកថាជាអ្នក*ស្ក្រីន* គឺអ្នកជាពិនិត្យឯកសារហ្នឹងមុនខ្ញុំក៏ថាបាន ព្រោះ<មានឯកសារច្រើន។> ខ្ញុំត្រូវការមនុស្សដូចគាត់អ៊ីចឹងឲ្យជួយខ្ញុំ។

**ស៖** ចុងក្រោយមុនពេលឈប់សម្រាក ហើយខ្ញុំនឹងចូលទៅសួរលោកបន្ថែមពីចំណុចសំខាន់ៗដទៃទៀត។ តើត្រឹមត្រូវដែរឬទេ ដែលថាការបើកបណ្ណសារនៅក្នុងឆ្នាំ១៩៩២, ៩៣ហ្នឹង ឥឡូវហ្នឹងបណ្ណសារហ្នឹងបិទហើយ ហើយឬក៏ថាបណ្ណសារនេះ គេបើកឡើងវិញម្តងទៀត ឬក៏យ៉ាងណាដែរ?

01386975



**ឆ៖** លោកលើកឡើងត្រូវខ្លះ ខុសខ្លះ។ ពីឆ្នាំមួយពាន់ប្រាំមួយរយ -- ចុងឆ្នាំ១៩៩១ រហូតដល់ខែមេសា ១៩៩៣ ក៏ប៉ុន្តែថ្មីៗនេះ ខ្ញុំរកឃើញថាបណ្ណសារហ្នឹងនៅទីក្រុងមូស្គូ ដែលខ្ញុំធ្លាប់បានទៅស្រាវជ្រាវនោះ ត្រូវបានបើកជាបណ្ដោះអាសន្ន<ឡើងវិញ> ហើយ<បន្ទាប់មកបិទដើម្បីផ្លាស់ប្ដូរ>កន្លែង<> ហើយឆ្នាំក្រោយនេះ គេនឹងបើកវិញ<>។ ហើយខ្ញុំសង្ឃឹមថាខ្ញុំនឹងទៅទីនោះ ហើយអាចថតចម្លងយកឯកសារទាំងអស់<ដែលលោកនិយាយ>នោះ ហើយដើម្បីយកឯកសារទាំងអស់នោះទុកនៅក្នុងដៃតែម្ដង។

[១៤:៣៨:១១]

**ស៖** ខ្ញុំត្រេកអរណាស់លោក។ លោកប្រធាន មុនពេលឈប់សម្រាកខ្ញុំសូមសួរមួយសំណួរទៀតសិន។ គឺ<ប្រៀបធៀបនិក្ខេបបទរបស់លោកជាមួយនឹង>សៀវភៅរបស់លោកដែលលោកសរសេរក្នុងឆ្នាំ១៩៩៩។ <ដូចខ្ញុំបាននិយាយហើយ គឺ>យើងមាន<តែផ្នែកខ្លះនៃ>និក្ខេបបទរបស់លោក <ឧទាហរណ៍ជំពូកដែលគួរឲ្យចាប់អារម្មណ៍បំផុត>គឺ<>ពាក់ព័ន្ធទៅនឹងការឈ្លានពានរបស់សូវៀត ទៅលើឆេកូស្លូវ៉ាគី<នៅឆ្នាំ៦៨ គឺជាផ្នែកដែលយើងអត់មាន>។ <ប៉ុន្តែអ្វីដែលយើងមានពី>និក្ខេបបទរបស់លោកនេះ វាមានការត្រូវគ្នា <ហើយ>វាមានភាពខុសគ្នាខ្លះៗ។ ចំណុចគួរឲ្យចាប់អារម្មណ៍មួយដែលខ្ញុំនឹងសួរនៅពេលក្រោយផងដែរ គឺនៅទំព័រ៤៦១នៃនិក្ខេបបទរបស់លោក ERN ជាភាសាអង់គ្លេស 01335197 ចំណុចនេះមិនមែននៅក្នុងសៀវភៅរបស់លោកទេ តែនៅក្នុងនិក្ខេបបទរបស់លោក។ ខ្ញុំសូមអានឲ្យលោកស្ដាប់ គឺសម្រង់ចេញអំពីនិក្ខេបបទរបស់លោក។ លោកបាននិយាយអំពីព្រឹត្តិការណ៍មួយនៅក្នុងឆ្នាំ១៩៧៨ លោកបាននិយាយពីឈ្មោះ ហេង សំរិន ហើយលោកនិយាយថា វៀតណាមហ្នឹងគឺបានបង្កើតក្រុមចលនាតស៊ូប្រដាប់អាវុធ។ ខ្ញុំនឹងសូមដកស្រង់ចេញពីនិក្ខេបបទរបស់លោកនេះ៖

“យោងទៅតាម<វរសេនីយ៍ត្រីម្នាក់មក>ពីកងទ័ពជាតិកម្ពុជា<ប្រជាធិបតេយ្យ>ដែលបានរត់ទៅប្រទេសថៃ<នៅខែកញ្ញា> ថា ហេង សំរិន មានបំណងធ្វើរដ្ឋប្រហារប្រឆាំងទៅនឹងរដ្ឋាភិបាលទីក្រុងភ្នំពេញ<មុនខែមេសា> ក៏ប៉ុន្តែអនុមេបញ្ជាការ<របស់ ហេង សំរិន នៅក្នុង>កងពលលេខ៤<ដែលមានមូលដ្ឋាននៅកំពង់ចាម>នោះ <បានប្រាប់យើងនេះដល់រដ្ឋាភិបាល ហើយផែនការនោះត្រូវបានកម្ទេច>។ ហេង សំរិន ដែល<ត្រូវបានគេ>និយាយថា ជាផ្នែកមួយដែលត្រូវបានគាំទ្រដោយ<ក្រុម>វៀតណាម<នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា> ក៏បានរត់ទៅវៀតណាមជាមួយនឹងកងទ័ពគាត់ ហើយនិងអាវុធមួយចំនួនផងដែរ។”

ខ្ញុំមិនចង់សួរឲ្យលោកលើកឡើងអំពីខ្លឹមសារនោះទេ ពីព្រោះយើងនឹងចូលនិយាយអំពីប្រធានបទនេះតទៅទៀត។ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះបានទេថា ហេតុអ្វីបានជាចំណុចនេះ យើងមិនអាចរកឃើញនៅក្នុងសៀវភៅរបស់លោកទេ តែរកឃើញនៅក្នុងនិក្ខេបបទរបស់លោកទៅវិញ?

[១៤:៤១:១៣]

**ឆ៖** ខ្ញុំត្រូវពិនិត្យមើលសម្រង់ដែលលោកដកស្រង់ចេញពីនិក្ខេបបទរបស់<ខ្ញុំ>សិន ពីព្រោះខ្ញុំជម្រាបឲ្យត្រង់ ខ្ញុំភ្លេចហើយ។

**ស៖** គឺថាយើងនឹងលើកឡើងអំពីប្រធានបទនេះឡើងវិញ ដើម្បីរំឭកដល់ការចងចាំរបស់លោក។ លោកប្រធាន <នេះអាចជាពេលវេលាដ៏ល្អមួយ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<តើលោកអាចធ្វើនៅពេលឈប់សម្រាកបានទេ ឬក៏ថា>តើលោកមានឯកសារនេះនៅជាមួយទេ? អត់មានទេ នៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណអ្នកជំនាញ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់អ្នកជំនាញនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០១ នាទី)*

[១៥:០១:៥៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ផ្តល់វេទិកាជូនទៅមេធាវី វ៉ិចទ័រ កូប៉េ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរជាថ្មីម្តងទៀត លោក ម័ររីស។ សំណួរខ្លីៗបន្ត ពាក់ព័ន្ធទៅនឹងសេចក្តីដកស្រង់ពីនិក្ខេបបទរបស់លោក ពាក់ព័ន្ធទៅនឹងលោក ហេង សំរិន។ តើលោកបានយកមកជាមួយលោកទេនូវនិក្ខេបបទ<របស់លោកទេ ឬមួយក៏លោកចង់ឱ្យខ្ញុំផ្តល់នូវទំព័រជាក់លាក់ជូនលោក តាមរយៈអន្តរាគមន៍របស់>លោកប្រធាន<> ពីព្រោះខ្ញុំនឹងត្រឡប់មករកប្រធានបទនេះ នៅពេលក្រោយ?

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** ទេ ខ្ញុំមិនបាននាំនិក្ខេបបទមកជាមួយទេ <ហើយ>ខ្ញុំ<ចង់បានឯកសារមួយច្បាប់>នូវទំព័រជាក់លាក់<នោះ>។ អរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន សូមការអនុញ្ញាត នឹងផ្តល់ជូនឯកសារទៅអ្នកជំនាញ។

[១៥:០៣:១៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

ខ្ញុំមានការកត់សម្គាល់មួយ លោកប្រធាន។ ដើម្បីឱ្យយល់<នូវ>អ្វីដែលត្រូវបានផ្តល់ជូនទៅអ្នកជំនាញ ខ្ញុំមានអារម្មណ៍ថា ផ្នែកដែលដកស្រង់ដោយមេធាវីការពារក្តី គឺមានពីរទំព័រ ជាពិសេសមានសេចក្តីសន្និដ្ឋាននៅផ្នែកចុងក្រោយ ដែលមានលក្ខណៈសំខាន់ដើម្បីអាន។ អ៊ីចឹងខ្ញុំចង់ដឹង ថាតើអ្នកជំនាញគាត់មានឯកសារទាំងពីរទំព័រ ដែលមេធាវីការពារក្តី គាត់ចង់សួរហ្នឹងទេ? គឺ ERN នៅខាងចុងហ្នឹងគឺ 197 និង198។ <ខ្ញុំធ្វើការកត់សម្គាល់នេះ> ព្រោះថានៅក្នុងហ្នឹង មានកថាខណ្ឌមួយដែលជាសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញ ដែលមេធាវីការពារក្តី គាត់ដកស្រង់។ អ៊ីចឹងចំណុចហ្នឹង ក៏គួរតែអានដែរ ដើម្បីឱ្យអ្នកជំនាញហ្នឹង គាត់មានប្រតិកម្មតបទៅនឹងកថាខណ្ឌមួយនេះ។ ចំពោះខ្ញុំផ្ទាល់ ខ្ញុំមានហ្វូតូកូពី<នៃឯកសារនេះ>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ<មិន>អាច<ជំទាស់នឹងសំណើ>នេះ<ទេ>។ នេះជានិក្ខេបបទរបស់គាត់ ប្រហែលថាគាត់អាច<ទទួល>អត្ថបទទាំងស្រុង អំពីអ្វីដែលអង្គជំនុំជម្រះមាន <ហើយអ្នកជំនាញអាចពិនិត្យមើលអ្វីៗ

ទាំងអស់>។ ហើយខ្ញុំមិនមានការជំទាស់អ្វីនោះទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចំពោះពេលនេះ គឺថាទំព័រ ពីរទំព័រត្រូវបានស្នើសុំរួចហើយ<គឺមាននៅទីនេះ>។ ប្រហែលគប្បីផ្តល់ទំព័រទាំងពីរនេះទៅអ្នកជំនាញ។ ខ្ញុំមិន<ដឹង>ថា <តើគាត់>អាចពិនិត្យមើលនៅ<ក្នុងរយៈ>ពេល<ខ្លី>នេះ<បានឬ>ទេ ប៉ុន្តែទុកជូនទៅអ្នកជំនាញចុះ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

បើអ៊ីចឹងលោកប្រធាន សុំការអនុញ្ញាតឲ្យមន្ត្រីតុលាការផ្តល់ឯកសារដែលខ្ញុំបានហ្វូតូកូពីហ្នឹង គឺមានពីរទំព័រពាក់ព័ន្ធដើម្បីផ្តល់ជូនអ្នកជំនាញ។ សូមលោកប្រធានមេត្តាអនុញ្ញាត។

[១៥:០៥:២០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងបន្តទៅទៀតលោកប្រធាន។ ខ្ញុំសុំជម្រាបថា បើសិនជាអ្នកជំនាញចង់បានទទួលបានឯកសារទាំងអស់ដែលយើងមាន គឺថាសុំលោកបញ្ជាក់ជូនអង្គជំនុំជម្រះ។ មុននឹងខ្ញុំចូលទៅដល់ប្រធានបទទី២ គឺមានសំណួរខ្លីៗពាក់ព័ន្ធទៅនឹងប្រភពនានាដែលលោកប្រើ។ តើត្រឹមត្រូវដែរឬទេ លោកមិនបាន មិនចេះសរសេរ ឬក៏ចេះអានភាសាខ្មែរទេ?

**លោក ស្ទីហ្វិន ម៉័ររីស៖**

**ឆ៖** ត្រឹមត្រូវ។

**ស៖** តើត្រឹមត្រូវដែរឬទេ នៅក្នុងលេខយោង ហើយនិងសេចក្តីយោងទៅរកប្រភពព័ត៌មាននោះនៅក្នុងសៀវភៅរបស់លោកនៅក្នុងឆ្នាំ១៩៨៩ គឺមិនមានអ្វីដកស្រង់ចេញពីអ្វីដែលខ្ញុំចង់ហៅថាជាឯក-សារនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដូចជាកំណត់ហេតុកិច្ចប្រជុំអចិន្ត្រៃយ៍របស់បក្សកុម្មុយនីស្តកម្ពុជា សារទូរលេខមកពីកងពលយោធា ពីថ្នាក់ក្រោមរហូតទៅដល់នាយអគ្គសេនាធិការយោធាជាដើម ដូចជាឯកសារទស្សនាវដ្តីទង់បដិវត្ត ហើយ<ខ្ញុំជឿថាមាន>មួយ<ដែល> លោកបានយោងទៅរកទស្ស-នាវដ្តីទង់បដិវត្ត។ <ប៉ុន្តែខ្ញុំគិតថានោះជាចំណុចតែមួយគត់។> អ៊ីចឹងខ្ញុំសួរថា តើត្រឹមត្រូវដែរឬទេ នៅក្នុងសៀវភៅឆ្នាំ<១៩៨៩> <របស់លោក> លោកមិនបានយោងទៅរកឯកសារដែលចេញនៅក្នុងសម័យ

កម្ពុជាប្រជាធិបតេយ្យ<>នោះទេ?

[១៥:០៧:២៩]

**ឆ៖** នេះប្រហែលជាត្រឹមត្រូវ។ ខ្ញុំមិនបានយោងទៅរកច្រើននោះទេ។

**ស៖** សំណួរមួយទៀត តើលោកប្រើដែរឬទេ នៅក្នុងសៀវភៅរបស់លោកនូវប្រភពសំខាន់បឋមៗរបស់អាមេរិកាំង ឬក៏ចិន <>នៅក្នុងសម័យ<កាលនោះ>?

**ឆ៖** ប្រហែលខ្ញុំអាចនឹងបានប្រើអត្ថបទសារព័ត៌មានទាក់ទងទៅនឹងជាប្រភពរបស់អាមេរិកាំងនៅក្នុងសម័យកាលនៃរបបនោះ មិនមែនជាប្រភពរបស់ចិនទេ។

**ស៖** បាទ ខ្ញុំយល់។ ពាក់ព័ន្ធទៅនឹងប្រភពសំខាន់របស់ជនជាតិអាមេរិកនោះ <ដូចដែលលោកដឹងហើយ>នៅពេល<>មួយ<>មានបណ្តាញព័ត៌មានតាមខ្សែកាប<ទាក់ទងគ្នា>រវាង<ហេនរី ឃីសស៊ីងហ្គ័រ ជាមួយ>នឹងលោក ស៊ូហាតូ <ត្រូវបានគេ>បោះពុម្ពផ្សាយ <គឺបានចេញពីប្រភពសម្ងាត់ ទៅជា>ប្រភពជាចំហ<។ តើ>លោក<>បានប្រើ<>ប្រភពចម្បងរបស់ជនជាតិអាមេរិកាំងនៅក្នុងសៀវ-ភៅរបស់លោកនោះ<ទេ>?

**ឆ៖** ទេ ខ្ញុំមិនចាំថា ខ្ញុំបានធ្វើបែបនេះទេ។

**ស៖** ឥឡូវនេះ សំណួរចុងក្រោយរបស់ខ្ញុំត្រង់ប្រធានបទនេះ ទាក់ទងទៅនឹង<វិធីសាស្ត្រ និង>ប្រភពព័ត៌មាន។ តើលោកបានធ្វើការសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមបន្ទាប់ពីការបោះពុម្ពផ្សាយសៀវភៅរបស់លោកឬទេ? ក្នុងករណីថា “បាន” ថាតើលោកបានរកឃើញអ្វីដែលថាប្រភព និងឯកសារនានាដែលឃើញថា ដែលថា អ្វីៗទាំងអស់ដែលលោកនិយាយហ្នឹងគឺថាបានឃើញចេញពី ដែលបញ្ជាក់ពីមូលដ្ឋាន ឬប្រភពនៅក្នុងសៀវភៅរបស់លោកដែរឬទេ?

[១៥:១០:១២]

**ឆ៖** បាទ ខ្ញុំថាអ្វីៗដែលខ្ញុំបាននិយាយ គឺស្ទើរតែអ្វីៗទាំងអស់ គឺមានមូលដ្ឋាននៅក្នុងសៀវភៅរបស់ខ្ញុំ ហើយនិងការបោះពុម្ពផ្សាយរបស់ខ្ញុំ ហើយនិងការបោះពុម្ពផ្សាយផ្សេងៗទៀតរបស់ស្នាដៃខ្ញុំ។

**ស៖** អ៊ីចឹងសំណួរបន្តទៅទៀត តើលោកបានតាមដានកិច្ចដំណើរការនីតិវិធីជំនុំជម្រះនៃសាលាក្តីនេះដែរឬទេ?

**ឆ៖** បាន ៗតាមដានបន្តិចបន្តួចកាលពីចំណុចចាប់ផ្តើមនៃសាលាក្តីនេះ ប៉ុន្តែមិនបានតាមដានល្អិតល្អន់ច្រើនទេ អត់ទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សូមអរគុណ។--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោក កូប៉េ ខ្ញុំសូមទោសដែលរំខាន។ ដើម្បីកុំឲ្យយើងភ័ន្តច្រឡំ លោក<បានស្នើសុំ>ផ្តល់ទៅអ្នកជំនាញនូវឯកសារពាក់ព័ន្ធដែលលោកចង់ប្រើ។ ឥឡូវនេះគឺមានឯកសារ<២១៦>ទំព័រ <ថាតើយើងត្រូវថតចម្លងសម្រង់ទាំងមូលដែលយើងមាននៅក្នុងសំណុំរឿងឬយ៉ាង>ណា? មូលហេតុដែលខ្ញុំបញ្ជាក់ដូច្នេះ <>គឺថាដើម្បីឲ្យបុគ្គលិក<របស់លោក>អាច<ធ្វើការលើរឿងនេះ។ ប្រហែលពួកគេអាច>កំណត់<ទំព័រទាំងនោះ ដែលលោកចង់>ឲ្យអ្នកជំនាញអាចមើលបានយប់នេះ។ យើង<>អាចធ្វើកូពីចម្លង<ឯកសារទាំងនោះ>បាន<>។

**លោក វ៉ិចទ័រ កូប៉េ៖**

សេចក្តីសម្រង់ដែល<ខ្ញុំនឹងប្រើពី>ក្នុងនិក្ខេបបទ<របស់គាត់នោះ> ខ្ញុំ<នឹងប្រើនៅពេលនេះ។ ដូច្នេះខ្ញុំគិតថា>មុន<>ម៉ោងបួននោះ <វាច្បាស់ហើយ ហើយបើមានសំណួរណាត្រូវសួរបន្ត ពេលនោះ> យើងនឹង<អាចពិភាក្សានៅទីនេះ>ក្នុងសាលសវនាការនេះ។

[១៥:១១:៤៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូចដែលខ្ញុំបញ្ជាក់ខាងដើម លោកអ្នកជំនាញ ម៉័ររីស ប្រធានបទរបស់ខ្ញុំទី២ គឺជាប្រធានបទដ៏សំខាន់ ខ្ញុំប្រើឃ្លារបស់លោកដែលលោកប្រើ ដែលលោកនិយាយថា សូមដកស្រង់៖ "ហៅថាមហិច្ឆតាចក្រពត្តិនិយមរបស់វៀតណាម ឬក៏ថាមហិច្ឆតាចក្រពត្តិនិយមវៀតណាម"។ អ៊ីចឹងសូមលោកពន្យល់តុលាការ ថាតើលោកប្រើពាក្យថា "មហិច្ឆតាចក្រពត្តិនិយមវៀតណាម" នេះ លោកសំដៅយកអត្ថន័យអ្វីខ្លះ?

**លោក ស្ទីហ្វិន ម៉័ររីស៖**

**ឆ៖** បាទ ប្រវត្តិសាស្រ្តរបស់វៀតណាម ហើយគឺជាប្រវត្តិសាស្រ្ត<យូរអង្វែងមួយភ្ជាប់ទៅខាងត្បូង ចេញពីអ្វីដែលពេលនេះយើងហៅថា>វៀតណាម<ខាងជើង> ដើម្បីកាន់កាប់ដែនដីដែលក្រុមជាតិពន្ធុផ្សេងកាន់កាប់<រួម>ទាំងពួកចាម ហើយនិងកម្ពុជា។ ផ្នែក<ធំ>មួយ<នៃអ្វីដែលជា>របស់វៀតណាម<ខាងត្បូង>នៅពេលនេះ ធ្លាប់ជាដែនដីរបស់កម្ពុជា ហើយ<>បារាំង<បានជួយ> កាត់ផ្តាច់<ជាផ្លូវការ>ពីកម្ពុជា<>បញ្ចូលទៅផ្នែកខាងត្បូងនៃប្រទេសវៀតណាម គឺនៅក្នុងសម័យអាណា

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

និគមរបស់បារាំងនោះឯង។ ហើយខ្ញុំក៏គិតផងដែរថា ទស្សនទានទាំងមូលរបស់សហព័ន្ធឥណ្ឌូចិននោះ គឺដើម្បីផ្តួចផ្តើមគំនិតនៅក្នុងកុម្មុយនីស្តអន្តរជាតិនៅក្នុងឆ្នាំ១៩៣០ គឺជាមហិច្ឆតាដឹកនាំ ហើយជាកត្តាជំរុញនៅក្នុងអាកប្បកិរិយារបស់កុម្មុយនីស្តវៀតណាមចំពោះកម្ពុជាក្នុងប៉ុន្មានទសវត្សរ៍<ក្រោយមក>។

[១៥:១៤:០០]

<ខ្ញុំគិត>ថាគំនិតនៃឥណ្ឌូចិន កាលនោះគឺយកគំរូពីសហភាពសូវៀត។ អ៊ីចឹងគឺថាមានអង្គភាពនយោបាយជនជាតិភាគតិច ដែល<បានផ្តល់ឲ្យនូវភាពជា>អ្នកដឹកនាំ<ទៅឲ្យ>ក្រុមជនជាតិភាគតិច<ផ្សេងទៀត>ដែលជាសហព័ន្ធ។ <ដូច្នេះ ដូចក្នុងករណីរបស់របស់សហភាពសូវៀត ក្រុមជនជាតិភាគតិច>រុស្ស៊ី<បានគ្រប់គ្រងលើប្រជាជនផ្សេងទៀតដែលមិនមែនជាជនជាតិ>រុស្ស៊ី<នៅក្នុងសហ-ភាពសូវៀត>។ អ៊ីចឹងហើយ គឺគេអាចមើលឥណ្ឌូចិនថា វៀតណាមជាប្រទេសដែលដឹកនាំក្នុងលក្ខណៈជាអ្នកដឹកនាំលើឡាវ និងកម្ពុជា។ គេមានឥទ្ធិពលច្រើនជាងប្រជាជនឡាវ និងកម្ពុជានៅក្នុងសហព័ន្ធឥណ្ឌូចិននោះ។

**ស៖** ខ្ញុំនឹងសួរបន្តបន្តិចទៅទៀត ដែលលោកបានបញ្ជាក់ពីបញ្ហានិយាយអំពីសហព័ន្ធឥណ្ឌូចិននេះ គឺលោកបានសរសេររួចហើយនៅក្នុងសៀវភៅរបស់លោកដែរ។ គឺមិនមានភាសាខ្មែរ ឬជាភាសាបារាំងទេ ខ្ញុំនឹងប្រើជាភាសាអង់គ្លេសតែប៉ុណ្ណោះ នៅក្នុងសៀវភៅរបស់លោក អង់គ្លេស 01001732។ លោកបាននិយាយដូចខាងក្រោមនេះ៖ “តាមប្រពៃណី គឺមហិច្ឆតាចក្រពត្តិនិយមរបស់វៀតណាមនៅក្នុងឥណ្ឌូចិន គឺជាផ្លូវទៅតាមធម្មានុរូបម៉ាក្សស៊ីស-ឡេនីន<តាមរយៈទស្សនៈ>របស់សហព័ន្ធឥណ្ឌូចិនដែលបង្កើតឡើងដោយក្រុមនោះនៅក្នុងឆ្នាំ១៩៣០ ដើម្បីបង្កើតនូវកុម្មុយនីស្ត<ឥណ្ឌូចិន>។” តើលោក<ចង់>និយាយថា<ម៉េច នៅពេលដែលលោកសរសេរថា> “ជាមាគ៌ា<ធម្មានុរូប>របស់ ម៉ាក្សស៊ីស-ឡេនីន” <> កាលនោះលោកចង់សំដៅយកអ្វី?

**ឆ៖** អ្វីដែលខ្ញុំចង់និយាយនោះគឺថា ខ្ញុំគិតថាវៀតណាមពីដំបូងមាន ហូ ជីមិញ ដែលក្រោយមកគេហៅៗថា <ង្វៀន អាយ ក្វុក> ដែលគាត់បង្កើតបក្សកុម្មុយនីស្ត<វៀតណាម>នៅខែមករា ឆ្នាំ១៩៣០។ ប៉ុន្តែ<ការ>សម្រេច<របស់គាត់ក្នុងការហៅថាបក្សកុម្មុយនីស្តវៀតណាម>នោះ គឺថាត្រូវបាន<ជំទាស់>ដោយកុម្មុយនីស្តអន្តរជាតិ។ <>នៅ<ខែតុលា>ឆ្នាំ១៩៣០ បក្សនោះត្រូវបានប្តូរឈ្មោះគេប្តូរឈ្មោះទៅគណបក្សកុម្មុយនីស្តឥណ្ឌូចិន។ <ដោយយោងទៅលើការពិត>ដែល<ថាមិន>មានកម្ពុជា<ឬ>ឡាវ<ជាសមាជិកនៃបក្សនេះទេ>។ អ៊ីចឹងគំនិតដែលថាគេបង្កើតជាសហព័ន្ធនោះ គឺស្រប

ទៅនឹងទស្សនៈរបស់ម៉ាក្សស៊ីស-ឡេនីន។ គឺជាគម្រោងមួយ គំនិតមួយរបស់វៀតណាម ដែលរៀបចំឡើងដើម្បីឲ្យស្របជាមួយនឹងមនោគមន៍វិជ្ជា ម៉ាក្ស ហើយនិង ឡេនីន។

[១៥:១៧:៤០]

**ស៖** អ៊ីចឹងខ្ញុំសូមងាកចេញពីគំនិត ម៉ាក្ស-ឡេនីននេះបន្តិច ហើយយើងនិយាយទៅនឹងមហិច្ឆតារបស់ចក្រពត្តិនិយមវៀតណាម។ នៅទំព័រ 01001714 លោកនិយាយថា "កត្តានៃចក្រពត្តិនិយមវៀត-ណាមហ្នឹង គឺថាចាក់ឫសយ៉ាងជ្រៅនៅក្នុងវីរជនក្នុងវប្បធម៌វៀតណាម"។ សូមលោកពន្យល់ថាតើលោកសំដៅយកអត្ថន័យដូចម្តេច? ហើយលោកដឹងថាបែបនេះហ្នឹង គឺដឹងដោយរបៀបណា?

**ឆ៖** ជនជាតិវៀតណាមភាគច្រើនដែលខ្ញុំស្គាល់ គឺមិន -- ខ្ញុំសូមកែសម្រួលឡើងវិញ។ ជនជាតិវៀតណាមដែលមានការអប់រំខ្ពស់ៗហ្នឹង គឺថាមានទស្សនៈមួយទៅលើប្រទេសកម្ពុជា មិនមែនជាការស្អប់ខ្ពើមទេ។ ប៉ុន្តែវាជាទស្សនៈផ្ទុយនៅក្នុងគំនិតរបស់គេ គឺទាក់ទងថាកម្ពុជា គឺថាជាប្រទេសមួយមានវប្បធម៌ទន់ខ្សោយ ទន់ខ្សោយខាងវប្បធម៌ គឺមានប្រវត្តិសាស្ត្រនៅក្នុងការកាន់កាប់របស់វៀតណាមលើប្រទេសកម្ពុជានៅក្នុងសតវត្សទី១៩នោះ ជាពេលគឺថាមានការមើលស្រាលដែលថាគេថាកម្ពុជាមិនមែនជាមនុស្សពូកែហ្នឹង ជាផ្នែកមួយនៃជីវិតនយោបាយរបស់គេ។ មិន<ត្រឹមត្រូវទាំងស្រុងទេដែលថាយោធាថៃបាន>កាន់កាប់<>ប្រទេសកម្ពុជានៅ<សតវត្សរ៍ទី១៩នោះ>។ ហើយខ្ញុំពិនិត្យឃើញថា គឺវាមានន័យមួយ គឺថាប្រទេសទាំងពីរមានការយល់ជាវប្បធម៌ហ្នឹងខុសគ្នា រវាងខ្មែរហើយនិងវៀតណាម។ ហើយវៀតណាម គាត់គិតខ្លួនគាត់ថា គាត់ជាមានឧត្តមភាពទៅលើជនជាតិខ្មែរ។ អ៊ីចឹងហើយយើងអាចនឹងពិនិត្យឃើញថា ដោយច្បាស់ ហើយពេលខ្លះយើងអាចឃើញជាសាធារណៈនោះផងដែរ។

[១៥:២០:០០]

**ស៖** មើលខ្ញុំចង់ដឹងថា<ខ្ញុំ>យល់<ត្រឹមត្រូវទេ។ នៅក្នុងនិក្ខេបបទរបស់លោក> ERN ភាសាអង់គ្លេស 01335046 លោកនិយាយប្រហាក់ប្រហែលនេះដែរ <ប៉ុន្តែ>មិន<ច្បាស់ថាវាមានន័យបែបនេះ> ប៉ុន្តែខ្ញុំនឹងដកស្រង់ផងដែរ។ លោកនិយាយថា៖ "ដូច្នេះកត្តាពីរដែលលើកទឹកចិត្តកុម្មុយនីស្តវៀត-ណាម<ឲ្យមានមហិច្ឆតា>ចំពោះកម្ពុជានោះ គឺថា <តាមប្រពៃណីអ្នក>ជាតិនិយម<>វៀតណាម គឺជាអ្នក<មាននយោបាយ>ពង្រីកទឹកដី ហើយមិនមានអំណត់ខាងវប្បធម៌ទេ ហើយ<ទស្សនៈរបស់បដិវត្តន៍> ម៉ាក្ស-ឡេនីន <អន្តរជាតិ ដែលអនុគ្រោះដល់នយោបាយ>បញ្ចូលនូវប្រជាជន ឬក្រុមដែលបែកខ្ញែកឲ្យចូលទៅជាផ្នែករបស់<របស់បដិវត្តពិភពលោក>។"កន្លែងនេះគឺថា លោកនិយាយថា "គំនិត

ស្នេហាជាតិតាមវប្បធម៌របស់វៀតណាម" ថាតើ<នេះជាអ្វីដែល>លោកចង់និយាយ<នៅពេលលោកសំដៅទៅលើវប្បធម៌ ឬក៏អ្វីដែលខុសពីនោះ>?

**ឆ៖** ខ្ញុំគិតថា <នេះជា>ផ្នែកនៃវប្បធម៌ ដែលថា ការជាតិនិយមនេះ គឺជាផ្នែកនៃប្រពៃណី ឬក៏វប្បធម៌វៀតណាមដែរ។ ខ្ញុំគិតថា ការជាតិនិយមរបស់វៀតណាមនោះ គឺថាជាការពង្រីកទឹកដី វាតទីនិយម រហូតមកដល់បច្ចុប្បន្ននេះគឺថា ខ្ញុំមិនប្រាកដថា វៀតណាមបច្ចុប្បន្ននេះ ជាអ្នកមានគំនិតពង្រីកទឹកដីទេប៉ុន្តែនៅក្នុងទសវត្សរ៍កន្លងមកនោះគឺថា ជាការពិតនៅក្នុងឆ្នាំដែល ហូ ជីមិញ ហើយនិង ឡេ យន់ ជាអ្នកមេដឹកនាំរបស់បក្សកុម្មុយនីស្តវៀតណាមហ្នឹង គឺមានផ្នត់គំនិតហ្នឹង។

[១៥:២២:០០]

**ស៖** ឥឡូវនេះ យើងសុំចូលទៅដល់ទស្សនវិស័យមួយចំនួនទៅលើបញ្ហាដដែលនេះ និយាយអំពីចក្រពត្តិនិយម ហើយនិងជាមហិច្ឆតារបស់វៀតណាមដើម្បីបង្កើតសហព័ន្ធឥណ្ឌូចិន។ ហើយយើងមានទស្សនវិស័យផ្សេងៗ ដែលយើងយកមកប្រើបាន ជាពិសេសគឺទស្សនវិស័យរបស់វៀតណាម។ ជាឧទាហរណ៍ យើងអាចនឹងមើលបណ្ណសាររបស់សហភាពសូវៀតដែលយើងបានមើលបន្តិចរួចមកហើយនោះ។ យើងនិយាយពីទស្សនវិស័យកម្ពុជា ទាក់ទងទៅនឹងមហិច្ឆតារបស់ជនជាតិវៀតណាម ឬក៏ការជ្រៀតជ្រែកចូលទឹកដីរបស់កម្ពុជា ហើយនិង<ឥណ្ឌូចិនជាទូទៅ>។ អ៊ីចឹងគឺថាលោកនិយាយ ពីមុនថាអ្វីជាកត្តាសំខាន់របស់កម្ពុជាហ្នឹងគឺ ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ អ្វីដែលគាត់បាននិយាយ បានមានព្រះឱង្ការហើយលោកដកស្រង់នៅក្នុងសៀវភៅរបស់លោកសូមលោកបញ្ជាក់ប្រាប់តុលាការ ថាតើសម្តេច នរោត្តម សីហនុ ទ្រង់មានទស្សនៈដូចម្តេចនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០, <៧០ និង៨០> អំពីមហិច្ឆតារបស់វៀតណាមមកលើប្រទេសកម្ពុជា?

**ឆ៖** ខ្ញុំគិតថា សម្តេចឪទ្រង់នរោត្តម សីហនុ នោះគឺថា ទ្រង់បានព្យាយាមដើម្បីការពារធ្វើម៉េចឱ្យកម្ពុជាស្ថិតនៅមានឯករាជ្យ អត្តសញ្ញាណជាតិកម្ពុជា។ ហើយទ្រង់ក៏គោរពទៅតាមការអនុវត្តខាងនយោបាយដែលទ្រង់បានយល់ឃើញថា តាំងពីដើមទសវត្សរ៍ឆ្នាំ៦០ ទ្រង់បានប្តូរនយោបាយប្រឆាំងទៅនឹងសហរដ្ឋអាមេរិកយ៉ាងខ្លាំង គឺថាពាក់កណ្តាលឆ្នាំ១៩៦០ហ្នឹង គឺកាន់តែខ្លាំង។ ហើយជាលទ្ធផលនៃសម្ពាធពីបញ្ញវន្ត ឬវីរជនក្នុងស្រុកផងដែរ ព្រះអង្គក៏ក្លាយជាជនដែលរិះគន់ ឬក៏ដកខ្លួនចេញពីមហិច្ឆតាវៀតណាមកុម្មុយនីស្ត ហើយទ្រង់ព្យាយាមបានសម្របសម្រួលខ្លះនៃប្រយោជន៍កម្ពុជា ជាមួយសហរដ្ឋអាមេរិក។ ខ្ញុំគិតឃើញថា ព្រះអង្គសម្តេចឪនោះ ទ្រង់នរោត្តម សីហនុ នោះគឺជាបុគ្គលដែលចាត់ការ ឬ

ក៏ធ្វើនយោបាយដែលមានលក្ខណៈសមហេតុផល ដោយមានការវិនិច្ឆ័យត្រឹមត្រូវអំពីអ្វីដែលបម្រើផលប្រយោជន៍<ឯករាជ្យភាពនៃ>ប្រជាជនកម្ពុជា។

[១៥:២៥:១០]

**ស៖** ខ្ញុំនឹងសួរបន្ត ហើយនិងយោងទៅរកសេចក្ដីយោងពីរដែលលោកបញ្ជាក់ថាជាបទសម្ភាសន៍លោកជាមួយនឹងសម្ដេចនរោត្តម សីហនុ ហើយលោកបានយកទៅប្រើនៅក្នុងនិក្ខេបបទ ហើយក្នុងសៀវភៅរបស់លោកដែរ ទស្សនៈនោះ។ យើងយោងទៅរកនៅក្នុងនិក្ខេបបទក្នុងចំណុចមួយ អង់គ្លេស ERN01335073។ លោកបានសរសេរដូចតទៅនេះ សូមដកស្រង់៖ "សម្ដេច សីហនុ មានការភ័យខ្លាចដូចដែលប្រជាជនកម្ពុជាភ័យខ្លាចតាមប្រវត្តិសាស្ត្រ តាមប្រពៃណីដែរ អំពីមហិច្ឆតារបស់វៀតណាម។ ដូច<ទ្រង់បានសរសេរ>នៅក្នុងខែមករា ឆ្នាំ<១៩៦៣> <ថា> ទោះបីព្រះអង្គ គេហៅថា ជាឡុង ឬក៏ ហូ ជីមិញ ឬក៏ <ង៉ ឌិញ ឌៀម> គឺថាមិន<មានជនជាតិអណ្ណាម> ឬក៏ជនជាតិវៀតណាមណាអាច<ដេកដោយសុខស្រួលទេរហូតទាល់តែពួកគេបានទទួលជ័យជម្នះក្នុងការដឹកនាំ>កម្ពុជា <ឆ្ពោះទៅរកភាពវិនាសសាបសូន្យ ដោយបានឆ្លងកាត់>ដំណាក់កាលនៃទាសករ<>។"

ហើយលោកក៏បានសរសេរ<ថា "ទ្រង់បានបញ្ជាក់ឡើងវិញនូវអាកប្បកិរិយាដូចគ្នានេះនៅរយៈពេលជិត>២០ឆ្នាំក្រោយមក" <>នៅក្នុងអត្ថបទ<កាលប្បវត្តិ>របស់<ទ្រង់។ លោកបានដកស្រង់ពីព្រះអង្គមកសរសេរដូចទៅ>៖ "ប្រជាជនខ្មែរមានមូលហេតុយ៉ាងរឹងមាំ មិន<ចូលចិត្ត>ជនជាតិវៀត-ណាម។ <អ្នកជិតខាងយើងនៅខាងកើតមានឥទ្ធិពល>នៅក្នុងដំណើរការនៃទសវត្សរ៍ <>បានលេបត្របាក់<ទឹក>ដីរបស់<កម្ពុជា> ហើយ<បាន>ធ្វើអាណានិគម<លើទឹកដីទាំងនោះ> ហើយនិងឲ្យជម្រើសអ្នកនៅទីនោះគឺថា ឲ្យរស់នៅជារណប ឬក៏<ត្រូវច្បាំង>។"

តើហ្នឹងគឺថាជាសេចក្ដីដកស្រង់<ពីរ>ដែលលោកដកស្រង់ពីអត្ថបទ<>របស់ព្រះអង្គថា "អនុស្សាវរីយ៍ផ្អែមល្ហែម និងជូរចត់" <ហើយនិងបទសម្ភាសន៍>របស់<លោកជាមួយ>ទ្រង់ សីហនុ នោះ? អ៊ីចឹងគឺថា ជាគំនិតនេះឯងដែលលោកនិយាយថា ជាមហិច្ឆតាចក្រពត្តិនិយមរបស់វៀតណាមហ្នឹង ឬដូចម្ដេច?

[១៥:២៧:៥៤]

**ឆ៖** និយាយដោយស្មោះត្រង់ ខ្ញុំមិនបាននឹកឃើញពីអ្វីជាបទសម្ភាសន៍របស់ខ្ញុំដែលធ្វើឡើងជាមួយព្រះអង្គក្នុងឆ្នាំ១៩៨៥ ប៉ុន្តែគំនិតនេះវាស្របទៅនឹងទស្សនៈរបស់ព្រះអង្គ។ ប៉ុន្តែព្រះបរមរតនកោដ្ឋ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<> ទ្រង់ សីហនុ បានបញ្ជាក់ថា គឺថាកម្ពុជាត្រូវតែរស់នៅជាអ្នកជិតខាងរបស់វៀតណាម គឺយើងត្រូវតែទទួលស្គាល់<ការពិតពី>អត្ថិភាពរបស់ប្រទេសវៀតណាម<នៅខាងកើត ហើយ>មិន<ព្យាយាម>បង្កើតនយោបាយយ៉ាងម៉េចដែលជំរុញឲ្យវៀតណាមនោះមានលក្ខណៈកាន់តែមានលក្ខណៈស្រួចស្រាល់នោះទេ។ <ខ្ញុំគិតថា ចំណុចនេះស្របនឹងជំហររបស់ទ្រង់>។

**ស៖** តើលោកចាំ <ឬក៏>លោកបានប្រើសុន្ទរកថារបស់សម្ដេច សីហនុ នៅចំពោះមុខរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ<នៅខែមករា ឆ្នាំ១៩៧៩>ទេ ដែលគាត់បានប្រើពាក្យ "ថ្កោលទោស" យ៉ាងធ្ងន់ៗចំពោះការឈ្លានពាន លុកលុយចូលរបស់ទ័ពវៀតណាមមកកម្ពុជាកាលនោះ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេ ខ្ញុំដូចចាំស្រពេចស្រពិលពីសុន្ទរកថានោះ សូមទោស។

**ស៖** បើសិនជាករណីនោះ ខ្ញុំនឹង<មិន>សួរសំណួរពីបញ្ហានេះ<ទេ> ប្រហែលជាស្អែក<នៅពេល>ខ្ញុំសួរពីរឿងហ្នឹងនៅពេលដែលយើងនិយាយអំពីសេចក្ដីសម្រេចជាក់លាក់ពីចេតនា ឬក៏មហិច្ឆតាជាក់លាក់នោះ។ តើលោកដឹងដែរឬទេ ថាតើមានភាពខុសគ្នារវាងគំនិត រវាងទស្សនៈរបស់ទ្រង់ សីហនុ អំពីមហិច្ឆតារបស់វៀតណាម ហើយនិងរដ្ឋាភិបាល លន់ នល់ បន្តក្រោយមកទៀតនោះ? តើ លន់ នល់ មានទស្សនៈខុសគ្នាអ្វី ពីព្រះអង្គ ទាក់ទងចំពោះជនជាតិវៀតណាម ឬក៏ប្រទេសវៀតណាម <ឈ្លានពានទឹកដី>?

[១៥:៣០:២៤]

**ឆ៖** ខ្ញុំគិតថា លន់ នល់ មានការខកចិត្តចំពោះជនជាតិវៀតណាម ចំពោះវៀតណាម ប៉ុន្តែខ្ញុំមិនប៊ានធ្វើការប៉ាន់ស្មាន ឬក៏ប៉ាន់ប្រមាណដោយប្រាកដនិយមថា ប្រទេសខ្មែរនឹងត្រូវធ្វើអ្វីទេ។ <កម្ពុជា>មិនស្ថិតនៅក្នុងស្ថានភាពមួយដែលគេអាចផ្ដួល<>កងទ័ពវៀត<ណាមបានទេ ជាពិសេស>នៅខាងភូមិភាគខាងជើងនៅក្នុងសង្គ្រាមវៀតណាម <តាមដែលយើងហៅវានៅសហរដ្ឋអាមេរិក ឬជាសង្គ្រាម>អាមេរិកាំង<តាមដែល>វៀតណាម<ហៅវានោះ>។ ហើយកាលនោះ លន់ នល់ គឺជា មិនមែនជាមនុស្សដែលថា មានហេតុ មានផលឲ្យប្រាកដច្បាស់នោះទេ។ ហើយក៏មិនមែនជាបុគ្គលដែលប្រកាន់តាមការអនុវត្តត្រឹមត្រូវដូចទ្រង់ នរោត្តម សីហនុ នោះទេ។ ប្រហែលជាគាត់មិនសូវឆ្លាតវៃក្នុងការចូលរួម ក្នុងការដឹកនាំឲ្យមានជារដ្ឋប្រហារនៅកាលនោះៗផង។

**ស៖** បាទ ខ្ញុំយល់ហើយ លោកនិយាយថាអំពីប្រតិកម្ម ប៉ុន្តែឥឡូវនេះ ខ្ញុំចាប់អារម្មណ៍ចង់ដឹងអំពីទស្សនវិស័យរបស់<ពួកគេចំពោះ>មហិច្ឆតាវៀតណាម។ តើ<ពួកគេមានទស្សនៈវិស័យ>ដូចគ្នា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

<>ដែរឬទេ?

**ឆ៖** ខ្ញុំមិន<មាន>ជំនាញ<>គ្រប់គ្រាន់<នឹងដឹងអំពីគំនិតរបស់> លន់ នល់ <ដើម្បី>អាច <ឆ្លើយឲ្យបានត្រឹមត្រូវ>នោះទេ។

**ស៖** មិនបញ្ហាទេ។ ឥឡូវនេះយើងបានពិភាក្សាដោយសង្ខេបអំពីទស្សនវិស័យរួមខ្លះៗ អំពីមហិច្ឆតារបស់វៀតណាមនៅក្នុងឥណ្ឌូចិន។ ហើយយើងក៏<ក៏មានមនុស្សសំខាន់ៗដែលមាន>ទស្សនៈ <ចំពោះអ្វីដែលជា>ចេតនារបស់វៀតណាម<>ចំពោះឥណ្ឌូចិននោះ<ដែរ>។ អ៊ីចឹងថាតើទស្សនវិស័យរបស់ចិននេះយ៉ាងដូចម្ដេចដែរ ក្នុងទសវត្សរ៍ឆ្នាំ៥០ <និង>៦០ <ចំពោះវៀតណាម និង>ជាពិសេសនយោបាយការបរទេស<>? <តើចិនជឿថា>មហិច្ឆតារបស់វៀតណាមនុ៎ង យ៉ាងដូចម្ដេចដែរ?

[១៥:៣៣:០៩]

**ឆ៖** ខ្ញុំគិតថា ប្រទេសចិន ពីដំបូងគឺដើរតួដូចជាអាណាព្យាបាលទៅលើវៀតណាម ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ហើយគេបានបណ្ដុះបណ្ដាលជនកុម្មុយនីស្តវៀតណាមជាច្រើន អំពីមនោគមន៍វិជ្ជា អំពីទ្រឹស្ដីទស្សនៈរស់នៅ ឬក៏ជាជនកុម្មុយនីស្ដតាមម៉ៅនិយម។ <ខ្ញុំគិតថា ជនជាតិចិនតែងតែចង់ឲ្យ>ជនជាតិវៀតណាម <>គឺជាអ្នកដើរតាមទស្សនៈរបស់ចិននៅកាលនោះ ដែលថាវៀតណាមហ្នឹង មិន<មានឆន្ទៈក្នុងការទទួលយកនោះទេ នៅពេលពួកគេ>មានទំនាស់ខាងមនោគមន៍វិជ្ជាជាមួយរុស្ស៊ី ជាមួយសូវៀត <នៅក្រោមការដឹកនាំរបស់ គ្រូសឆេវ>។ ហើយខ្ញុំគិតថា ចិនហ្នឹងក៏បានមានការព្រួយបារម្ភច្រើន អំពីមហិច្ឆតារបស់វៀតណាម បន្ទាប់ពីមានការផ្ទុះឡើងនូវជម្លោះចិន-សូវៀត <ជាពិសេស> នៅក្នុងឆ្នាំ១៩៧០ វៀតណាមបានទៅជាអ្នកកាន់ជើងសហភាពសូវៀត។ ដូច្នេះហើយ គឺវាមានអំពើដែលថា អំពើដែលបំពារបំពាន ឬក៏មហិច្ឆតា<ដែល>ធ្វើឡើង<ដោយវៀតណាម គឺ>ដើម្បីជាប្រយោជន៍ ឬក៏ក្រោមឥទ្ធិពលរបស់សហភាពសូវៀត។ អ៊ីចឹងហើយគឺថា<យ៉ាងហោចណាស់>នៅក្នុងឆ្នាំ១៩៧០ ដែលចិនហ្នឹងមានការសង្ស័យអំពីចេតនារបស់វៀតណាម។

**ស៖** អ៊ីចឹងខ្ញុំនឹងសួរបន្តពីបញ្ហានេះ។ យើងនឹងពិភាក្សាគ្នាអំពីវិធីដែលថាតើវៀតណាម -- <>ចិន<មើលឃើញមហិច្ឆតារបស់>វៀតណាមដូចម្ដេច ក្រោយឆ្នាំ១៩៧៥។ យើងនឹងនិយាយអំពីសុភាសិតល្បីល្បាញរបស់ តេង ស៊ាវពីង ដែលថាហៅថា វៀតណាមជាមេកន្ទ្រាញ ឬក៏ជាបក្សខ្លាំងនៅ<ខាងកើត>។ <ប៉ុន្តែខ្ញុំសូមយោងទៅ>បញ្ញវន្ត<បារាំង>វៀតណាម<ដែល>បាននិយាយទៅឧត្តមស្នងការបារាំងនៅក្នុងឆ្នាំ១៩៦៥។ <បញ្ញវន្ត>ជនជាតិបារាំងនេះឈ្មោះ ប៉ូល មូស (អឹម-យូ-អេស ជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រកបរបស់គាត់)។ <លោកមិនបាននិយាយយោងដល់គាត់ទេ> ប៉ុន្តែ ណាយ៉ាន់ ចាន់ដា ហ្នឹងក៏បាន បញ្ជាក់នៅក្នុងសៀវភៅរបស់គាត់ E3/2376, អង់គ្លេស ERN 00192311, ហើយខ្មែរ 0019448 *(ស៊ីក)* ហើយនិង49, បារាំង 00237013 នៅខាងចុង។ ចាន់ដា និយាយថា៖ "ប៉ូល មូស ជាបញ្ញវន្ត <>វៀតណាម<ដ៏ល្បី និងជាអតីតទីប្រឹក្សាឧត្តមស្នងការ>បារាំង <បាន>និយាយនៅក្នុងឆ្នាំ<១៩៦៥> <ថា>ចិន<បានធ្វើសម្បទានដល់>បារាំង<> ដើម្បីបដិសេធកុំឲ្យវៀតណាមធ្វើជាម្ចាស់ ឬក៏ជាមេនៅឥណ្ឌូចិន។" ហើយអ្នកប្រវត្តិសាស្ត្របារាំង ហ្វ្រង់ស្វ័រ ហ្ស៊ីយ៉ូ ក៏<បានបញ្ជាក់ពី>គំនិតនេះ<នៅទំព័រជាមួយគ្នានោះ>។ <ដូច្នេះវាហាក់ដូចជា>ប្រទេសចិន<បាន>ព្រួយបារម្ភ<រួចហើយ>ថា វៀតណាមចង់ធ្វើជាមេធំនៅក្នុងឥណ្ឌូចិន <>នេះ<បើយោងតាមជនជាតិ>បារាំង។ តើ<លោកយល់ស្របទេ>?

[១៥:៣៧:២៤]

**ឆ៖** ខ្ញុំគិតថា នេះជាការបកស្រាយមួយពីខាងឥរិយាបថរបស់ខាងចិន នៅឯទីក្រុងហ្សឺណែវ។ <ប៉ុន្តែខ្ញុំគិត>ថា ចិនបានដឹងអំពីតួនាទីរបស់វៀតណាមនៅក្នុងប្រទេសកម្ពុជានៅក្នុងទសវត្សរ៍៥០តួនាទីរបស់បក្សកុម្មុយនីស្តវៀតណាមនៅទសវត្សរ៍<៥០>ក្នុងប្រទេសកម្ពុជា ហើយអាចចាត់ទុកថាវៀត-ណាមមានមហិច្ឆតាត្រួតត្រាប្រទេសកម្ពុជា និងប្រទេសឡាវតែម្តង តាមរយៈបក្សដែលវៀតណាមខ្លួនឯងជាអ្នកបង្កើតនៅក្នុងឆ្នាំ១៩៥១។ នៅក្នុងឆ្នាំ១៩៥១ វៀតណាមបានបង្កើតបក្ស<កុម្មុយនីស្តបុរាណ> មួយ<នៅកម្ពុជា និងឡាវ> ដោយ<មានជនជាតិខ្មែរ> និងឡាវ <មួយចំនួនតូច>ចូលរួម ដោយបញ្ចូលរួមមនុស្សដែលមានជាតិសាសន៍ផ្សេងគ្នា ឬក៏អ្នកខ្លះដែលមាន ដែលគេហៅថាឈាមជ័រ ហើយជាមួយនឹងវៀតណាម។ ហើយនេះជាវិធីសាស្ត្រមួយដ៏វែងឆ្ងាយហើយ តាំងពីអំឡុងសម័យឡេ យន់ មកតាំងពីឆ្នាំ១៩៣០ដល់ឆ្នាំ<១៩៧០>។ មហិច្ឆតាវៀតណាមក្នុងការប្រើប្រាស់មនុស្សដែលវៀតណាមគិតថា មានភក្តីភាពចំពោះខ្លួនដើម្បីបង្កើតបក្សកុម្មុយនីស្តនៅក្នុងបណ្តាប្រទេសទាំងនេះ។

**ស៖** ដូចដែលខ្ញុំបានលើកឡើងមកហើយ ខ្ញុំនឹងត្រឡប់ទៅនិយាយអំពីប្រទេសចិននូវអ្វីដែលតេង ស៊ាវពីង<និង ហ្គេង បៀវ>បាននិយាយអំពីសកម្មភាពវៀតណាមនៅក្នុងឆ្នាំ១៩៧៥ ទៅដល់៧៩។ ហើយ<>អ្នកដើរតួយ៉ាងសំខាន់នៅក្នុងតំបន់នេះ ហើយជាលក្ខណៈនយោបាយ គឺ<អាមេរិកាំង និងប្រទេសជិតខាង>ឥណ្ឌូចិន<ដូចជាឥណ្ឌូនេស៊ីជាដើម>។ តើលោកមានបានដឹងអំពីការសន្ទនារវាងហ្វូត ហើយនិង យីសស៊ីងហ្គ័រ <ទេ> ខ្ញុំគិតថាក្នុងខែវិច្ឆិកា ឆ្នាំ៧៥ ជាមួយនឹងឧត្តមសេនីយ៍ ស៊ូហាតូ អំពីអ្វីដែលពួកគាត់<ថា>មហិច្ឆតាវៀតណាមក្នុងការក្តោបក្តាប់ឥណ្ឌូចិននេះតែម្តង។ លោកបានដឹងអំពី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការសន្ទនានេះទេ?

[១៥:៤០:១៥]

**ឆ៖** ខ្ញុំអត់បានដឹងអំពីកិច្ចសន្ទនានេះទេ ខ្ញុំនឹកមិនឃើញទេ លោកមេធាវី។

**ស៖** បើអ៊ីចឹងខ្ញុំបន្តទៅមុខទៀត។ គឺថាខ្ញុំគ្មានសិទ្ធិដកស្រង់អំពីកិច្ចសន្ទនាទាំងអស់ទេ ក៏ប៉ុន្តែតើលោកមានការភ្ញាក់ផ្អើលទេដែល ស៊ូហារតូ មានការភ័យខ្លាចអំពីមហិច្ឆតាវៀតណាមចំពោះឥណ្ឌូចិនទាំងមូលនេះតែម្តង?

**ឆ៖** គឺថាខ្ញុំមិនមានការភ្ញាក់ផ្អើលទេ។

**ស៖** ខ្ញុំសូមបន្តចូលទៅដល់ទស្សនទាន ឬក៏ថាប្រភពព័ត៌មានដ៏សំខាន់បំផុត។ ថាតើវៀតណាមខ្លួនឯងនោះ បានមើលឃើញថាឥណ្ឌូចិន ហើយនិងកម្ពុជាហ្នឹងវាយ៉ាងដូចម្តេចដែរ? ចំណុចនេះយើងអាចរកឃើញនៅក្នុងការសន្ទនារវាងឯកអគ្គរដ្ឋទូតសូវៀតជាមួយនឹងមេដឹកនាំបក្សកុម្មុយនីស្តវៀតណាមនៅក្នុងឆ្នាំ១៩៧១ និងឆ្នាំ១៩៧៣។ ខ្ញុំយោងទៅការសន្ទនារវាងឯកអគ្គរដ្ឋទូត ឆាបឺខូហ្វ ដែលបានធ្វើការសន្ទនាជាមួយមន្ត្រីជាន់ខ្ពស់វៀតណាម គឺលោកបានលើកឡើងមកសរសេរនៅក្នុងសៀវភៅរបស់លោក។ ERN អង់គ្លេស 0100178*(ស៊ីក)* ខ្ញុំអាចដកស្រង់បាន ប៉ុន្តែសូមសួរសំណួរបើកសិន។ តើលោកបានរកឃើញថាម៉េចដែរ នៅក្នុងដើមទសវត្សរ៍ឆ្នាំ៧០ អំពីមហិច្ឆតារបស់វៀតណាម និងចេតនាវៀតណាមក្នុងការបង្កើតសហព័ន្ធឥណ្ឌូចិននេះ?

[១៥:៤២:៣៥]

**ឆ៖** មានឯកសារយោងមួយក្នុងសៀវភៅរបស់ខ្ញុំ អំពីការសន្ទនា អំពីទស្សនទាន អំពីការបង្កើតឥណ្ឌូចិននេះ គឺការសន្ទនារវាង ឡេ យន់ និងមន្ត្រីសូវៀត។ នៅពេលហ្នឹងគឺថាវាមានជម្លោះកើតឡើងដល់កំពូលហើយ រវាងវៀតណាម ហើយនិងកម្ពុជាប្រជាធិបតេយ្យ គឺរវាងប្រទេសកុម្មុយនីស្តទាំងពីរនេះ។ ហើយនៅពេលនេះ គាត់បាននិយាយថា អ្វីៗទាំងអស់ គឺថានឹងមានលក្ខណៈធម្មតាឡើងវិញនៅក្នុងប្រទេសកម្ពុជា គេមិនមានជម្រើសអ្វីផ្សេងនោះទេ។ ដូច្នេះខ្ញុំគិតថា វាជាការបង្ហាញថា គឺថាវៀតណាមហ្នឹង គឺថាអាចមានសិទ្ធិនៅពីលើនូវអ្វីដែលកើតឡើងក្នុងប្រទេសកម្ពុជា។

**ស៖** ខ្ញុំជួយរំឭកដល់ការចងចាំបន្តិច ខ្ញុំយោងទៅលើ ERN អង់គ្លេស 01001733។ ខ្ញុំសូមអានឱ្យលោកស្តាប់៖ "នៅក្នុងខែកម្ភៈ ១៩៧៣ ឯកអគ្គរដ្ឋទូតសូវៀតប្រចាំវៀតណាមបានលើកឡើងថាអ្វីដែលគាត់ជឿ ហើយចាត់ទុកថាជាគោលបំណងរបស់ទីក្រុងហាណូយ។" សូមដកស្រង់៖ "កម្មវិធី

របស់សមមិត្តវៀតណាមចំពោះសហព័ន្ធឥណ្ឌូចិន គឺជំនួសរបបប្រតិកិរិយានៅក្នុងទីក្រុងសៃហ្គន, វៀងចន្ទន៍ និងភ្នំពេញ ថាឲ្យមានការជឿនលឿន។ ហើយក្រោយមកទៀត វៀតណាម ឡាវ និងកម្ពុជា គឺថាធ្វើដំណើរលើមាគ៌ាមួយទៅកាន់សង្គមនិយម ដើម្បីចូលរួមបង្កើតនូវសហព័ន្ធឥណ្ឌូចិន។ <កម្មវិធីរបស់>បក្សពលករវៀតណាមបង្កើត<មកពីកម្មវិធីអតីត>បក្សកុម្មុយនីស្តឥណ្ឌូចិននេះឯង។”

ចំណុចដូចគ្នានេះ គឺថាត្រូវបានលើកឡើងពីរឆ្នាំពីខាងដើមនោះ ដែលឯកអគ្គរដ្ឋទូតរូបនេះមានការប្រុងប្រយ័ត្នចំពោះបញ្ហាវៀតណាមឲ្យប្រុងប្រយ័ត្នទៅលើប្រធានបទមួយ ពីព្រោះថាវាជាបញ្ហាមួយរសើបណាស់។ តើចំណុចត្រង់នេះ វាជួយរំឭកដល់ការចងចាំរបស់លោកទេ?

**ឆ៖** បាទ វាជួយរំឭកដល់ការចងចាំរបស់ខ្ញុំ។

[១៥:៤៥:១៦]

**ស៖** ដោយសារយើងមានតែសម្រង់ដែលចេញពីសៀវភៅរបស់លោក តើលោកមានការចងចាំជាក់លាក់ទេ អំពីការសន្ទនាមួយនេះ? ឧទាហរណ៍ តើលោកមានហេតុផលអ្វីដែលនាំឲ្យជឿថាឯកអគ្គ-រដ្ឋទូតសូវៀតដែលមានវត្តមាន ឬក៏អ្នកដែលនិយាយនៅក្នុងការសន្ទនានេះ តើការសន្ទនានេះ គេសរសេរយ៉ាងម៉េចដែរ នៅក្នុងឯកសាររបស់សូវៀតនោះ? <តើការសន្ទនានេះអានជាភាសារុស្ស៊ីថាម៉េច?> តើ<លោកមានប្រមូល>ទុក<នូវអ្វីដែលលោកបានឃើញ>នៅក្នុងបណ្ណសារនៅឯសូវៀតនោះដែរឬទេ?

**ឆ៖** សម្រង់នេះ <អត់ទេ> ខ្ញុំ<>មិន<បានប្រមូលចងក្រងនូវអ្វីដែលខ្ញុំបាន>ឃើញ<>នៅក្នុងបណ្ណសារសូវៀតនោះទេ។ ខ្ញុំមិនអាចបន្ថែមអ្វីលើសពីនេះបានទេ។ ក៏ប៉ុន្តែខ្ញុំសូមនិយាយថា ខ្ញុំអាចៗថាខ្ញុំបានអានរបាយការណ៍ពីភ្នាក់ងារសម្ងាត់សូវៀត ស្តីអំពីការសន្ទនាដែលបានកើតឡើងនេះ ឬក៏របាយការណ៍ពីឯកអគ្គរដ្ឋទូតសូវៀតដែលបានធ្វើការសន្ទនា។ ដូច្នេះខ្ញុំគ្មានអ្វីគួរឲ្យឆ្ងល់អំពីអ្វីដែលគេបាននិយាយនៅក្នុងការសន្ទនានេះទេ។ វាជាកិច្ចការរបស់ឯកអគ្គរដ្ឋទូតសូវៀតដែលត្រូវផ្តល់ព័ត៌មានទៅក្រុងមូស្គូនោះ។

**ស៖** លោកបានសម្ភាសមន្ត្រីជាន់ខ្ពស់វៀតណាមខាងត្បូង ឬក៏ជាមន្ត្រីកុម្មុយនីស្តវៀតណាមក៏មិនដឹង ទ្រឿង <ញូ តាំង>។ <នៅក្នុងការសម្ភាសនេះ តើលោកបានពិភាក្សាអំពីមហិច្ឆតាឥណ្ឌូចិនជាមួយគាត់ទេ> ឬក៏<>លោក<មិន>នឹកឃើញរឿងនេះទេ?

**ឆ៖** ខ្ញុំមិននឹកឃើញថាមានការពិភាក្សាជាមួយគាត់នោះទេ។ វានៅពេលនោះ ទ្រឿង <ញូ តាំង> គឺគាត់លេចមុខនៅបស្ចិមប្រទេស ហើយគាត់<ព្រួយបារម្ភច្រើន>អំពី<ស្ថានភាព>សិទ្ធិមនុស្ស

01386990



នៅក្នុងប្រទេសវៀតណាម។ ហ្នឹងជាតួនាទីមួយ<ដែល>វៀតណាម <កុម្មុយនីស្តបានសម្តែង ដើម្បី> ធ្វើការអូសទាញប្រជាជនឲ្យចូលរួមជាមួយខ្លួនក្នុងពេលសង្គ្រាម។ <ហើយខ្ញុំគិតថា នោះជាគំនិតសំខាន់នៃអ្វីដែលគាត់ចង់និយាយ> ដោយសារថា <>ថ្នាក់ដឹកនាំបក្សកុម្មុយនីស្តវៀតណាមយកគាត់ទៅប្រើប្រាស់ ដើម្បីថាធ្វើម៉េចឲ្យមានការគាំទ្រពេញចិត្តពីប្រជាជន។ ដូច្នេះខ្ញុំនឹកមិនឃើញថាមានការពិភាក្សាជាមួយគាត់នោះទេ។

[១៥:៤៨:៥៥]

**ស៖** តើលោកដឹងថា គាត់ នៅក្នុងឆ្នាំ១៩៨១ គាត់បានផ្តល់សក្ខីកម្មចំពោះសភាអាមេរិកនៅក្នុងឆ្នាំ១៩៨១ អំពីបញ្ហាមហិច្ឆតាវៀតណាមនេះដែរឬទេ?

**ឆ៖** ខ្ញុំនឹកមិនឃើញទេ សូមទោស។

**ស៖** លោកប្រធាន ខ្ញុំយោងទៅឯកសារដែលទទួលយកជាភស្តុតាងហើយ។ ឯកសារនេះ ខ្ញុំមិនដឹង<មានលេខ E3 អ្វីនោះ>--។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

គឺថាយើងផ្ញើអ៊ីម៉ែលទៅឲ្យលោកមើលហើយ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ប៉ុន្តែខ្ញុំអត់មាន E3 ទេនៅនេះ ERN ជាភាសាអង់គ្លេសនោះគឺ 10041745 គាត់យោងទៅលើសហព័ន្ធឥណ្ឌូចិនដែលនិយាយថា៖ "ខ្ញុំយល់ថាទីក្រុងហាណូយ ក៏គាំទ្រអំពីគម្រោងបង្កើតសហព័ន្ធឥណ្ឌូចិននេះផងដែរ។ ហើយនេះក៏ជាគោលបំណងរបស់ ហូ ជីមិញ ផងដែរ។" តើចំណុចនេះ ឃ្លានេះលោកបានរកឃើញផងដែរទេ ថាជាគោលបំណងយូរអង្វែងណាស់មកហើយរបស់ ហូ ជីមិញ ក្នុងការបង្កើតសហព័ន្ធឥណ្ឌូចិននេះ?

[១៥:៥០:២៣]

**លោក ស្ទីហ្វិន ម័ររីស៖**

**ឆ៖** ខ្ញុំគិតថា អ៊ីចឹងមែន។ ខ្ញុំសូមបន្ថែមថា ហូ ជីមិញ គាត់មានតួនាទីមួយលេចធ្លោជាងគេបំផុត <ក្នុងការបង្កើតគោលនយោបាយ>បក្សកុម្មុយនីស្តវៀតណាម<ចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ នៅពេលដែលគាត់ធ្លាក់ខ្លួនឈឺ> ហើយគាត់ស្លាប់នៅក្នុងឆ្នាំ១៩៦៩។ ហើយ<មហិច្ឆតានោះត្រូវបានបន្តអនុវត្តដោយមនុស្សសំខាន់ពីរនាក់នៅក្នុង>បក្សកុម្មុយនីស្តវៀតណាម <គឺ> ឡេ យន់, ឡេ ឌឹកថូ<>។ <ជា

ការពិត នៅអំឡុងសម័យអាណានិគមបារាំង> ឡេ ឌឹកថូ ហ្នឹងក៏មាន<ការទទួលខុសត្រូវនៅកម្ពុជា> សម្រាប់<បក្សកុម្មុយនីស្ត>វៀតណាម <ហើយ>សម្រាប់<បក្សកុម្មុយនីស្តឥណ្ឌូចិន>ទាំងមូលតែម្តង។ ដូច្នេះខ្ញុំគិតថា បាទ នេះគឺជាមហិច្ឆតាដែលគាត់មានយូរមកហើយ។ ហើយជាពិសេសគឺ តាមរយៈការសិក្សានយោបាយក្នុងលក្ខណៈអន្តរជាតិរបស់គាត់ តាំងពីឆ្នាំ<១៩២៣> យ៉ាងហោចណាស់មកដល់<១៩៣៨>។

**ស៖** ដូចដែលលោកបានលើកឡើងយ៉ាងត្រឹមត្រូវហើយថា ទ្រឿង <ញូ តាំង> មិនមែនជាសមាជិកដ៏សំខាន់បំផុតរបស់បក្សពលករវៀតណាមទេ <ខ្ញុំចង់និយាយថា គាត់មិន>នៅក្នុងសមាជិកគណៈមជ្ឈិម ឬគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តវៀតណាមទេ។ <ប៉ុន្តែ>គឺ<ជា>អ្នកដែលមានការយល់អំពី<>មហិច្ឆតារបស់ ឡេ យន់ និង ឡេ ឌឹកថូ។ ហើយនៅក្នុងសៀវភៅរបស់លោក លោកក៏បានសរសេរពី<ហ័ង> វ៉ាន់<ហ័ន> ជា<មនុស្សម្នាក់ក្នុងចំណោម>អ្នកបង្កើតបក្សកុម្មុយនីស្ត<ឥណ្ឌូចិន> ជាសមាជិកការិយាល័យនយោបាយ ហើយជាអ្នកដែលមានជំនាញខាងនយោបាយការបរទេស។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានឬទេ ថាគាត់គឺជាអ្នកណា? ហើយគាត់បាននិយាយអ្វីខ្លះ អំពីមហិច្ឆតារបស់វៀតណាមនៅពេលដែលគាត់រត់ភៀសខ្លួនទៅប្រទេសចិននៅក្នុងឆ្នាំ១៩៧៩នោះ?

[១៥:៥២:៤០]

**ឆ៖** ហ័ង វ៉ាន់ ហ័ន គឺជាសមាជិកជាន់ខ្ពស់នៃបក្សកុម្មុយនីស្តវៀតណាមដែលគាត់មាននិន្នាការកាន់ជើងទៅខាងប្រទេសចិន។ ហើយខ្ញុំជឿជាក់ថា នៅក្នុងពេលដែលប្រទេសវៀតណាមងាកខ្លួនទៅខាងសូវៀតនោះគឺថា គាត់ក៏បានរត់ភៀសខ្លួនទៅកាន់ប្រទេសចិន។ ខ្ញុំអាចមានសម្រង់របស់គាត់យកសរសេរនៅក្នុងសៀវភៅរបស់ខ្ញុំ តែខ្ញុំ<មិនចាំទេ>។

**ស៖** នៅក្នុងប្រភពទី២ លោកយោង<ទៅរកសៀវភៅរបស់គាត់មួយមានចំណងជើង>ថាជា "តំណក់ទឹកមួយតំណក់នៅក្នុងមហាសមុទ្រ" <ដែល>គាត់<បានសរសេរនៅដើមទសវត្សរ៍៨០ ពេលដែលគាត់>រត់ភៀសខ្លួនទៅប្រទេសចិន។ <សម្រង់មួយមកពី>សៀវភៅនេះ <>ទើបតែទទួលយកជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះយើងនេះផងដែរ។ ហើយគាត់បាននិយាយពី ឡេ យន់ ហើយ <គាត់>បាននិយាយ<ថា ឡេ យន់ នោះ> គឺជា<អធិរាជ>អនុត្តរ<ភាពនៃឥណ្ឌូចិន ដោយរួមបញ្ចូលនូវមហិច្ឆតាដូចគ្នា> លោកនឹកឃើញអំពីរឿងនេះទេ?

**ឆ៖** ហ្នឹងជាជំហររបស់គាត់អ៊ីចឹងហើយ។ <ដោយសារ>គាត់រត់ភៀសខ្លួនទៅប្រទេសចិន

<វាអាចជាជំហររបស់ចិននៅពេល>នោះ។ ខ្ញុំសរសេរសៀវភៅមួយក្បាលដែលមានប្រាំពីរ ប្រាំបីរយទំព័រ មានសម្រង់ច្រើនណាស់។ ហើយនិយាយឲ្យត្រង់ទៅ <ខ្ញុំមិន>នឹកឃើញសម្រង់ណាឲ្យច្បាស់លាស់<ទេ> ពីព្រោះវាជាង១៧ឆ្នាំកន្លងមកហើយ។

**ស៖** ខ្ញុំយល់អំពីបញ្ហានេះ ប៉ុន្តែអ្វីដែលខ្ញុំចង់<ដឹង>គឺថាខ្ញុំនឹងលើកមកសួរអំពីគាត់នេះ ខ្លះបន្ថែមទៀត។ គាត់គឺជាសមាជិកការិយាល័យនយោបាយនៃបក្សពលកររៀតណាមរហូត មកដល់ពេលដែលគាត់ត្រូវបានគេបណ្តេញ ឬក៏លាលែងនៅចុងឆ្នាំ<១៩៧៦>។ <តើលោកយល់ស្របជាមួយខ្ញុំទេថា> គឺថាគាត់មិនមានភាពនឹងនរទេ នៅក្នុង<ការធ្វើការផ្ទៃក្នុង ហើយនិងមហិច្ឆតារបស់>បក្ស<កុម្មុយនីស្ត>វៀតណាម?<>

[១៥:៥៥:២៤]

**ឆ៖** ខ្ញុំយល់ស្របជាមួយនឹងអ្វីដែលលោកលើកឡើង។

**ស៖** ខ្ញុំសូមបញ្ចប់។ ខ្ញុំនៅសល់ពេល៥នាទីទៀត លោកប្រធាន។ និយាយអំពីទស្សនៈយល់ឃើញរបស់អ្នកសិក្សាស្រាវជ្រាវអាមេរិកាំងមួយរូប គឺឈ្មោះ ដូក្លាស <ផាយ>។ ដូចដែលលោកយល់ស្របហើយអំពីការយល់ឃើញនេះរបស់គាត់ចំពោះនយោបាយការបរទេសវៀតណាម។ គាត់ក៏បានរាយការណ៍ទៅជូនសមាជសហរដ្ឋអាមេរិកនៅខែតុលា ៧៨ ផងដែរ។ លោកប្រធាននេះ គឺឯកសារ E3/2370។ ខ្ញុំសូមលើកយកសេចក្តីសន្និដ្ឋានរបស់គាត់អំពីបញ្ហាព្រំដែននេះ អង់គ្លេស 00187396, បារាំង 00344747 ដល់48។ នេះគឺជាអ្វីដែលគាត់បានលើកឡើង។ ហើយសំណួររបស់ខ្ញុំ គ្រាន់តែសួរថាលោកយល់ស្របជាមួយគាត់ ឬក៏អត់តែប៉ុណ្ណោះ?

"<មរតករបស់កម្ពុជាវៀតណាម គឺការមានអារម្មណ៍មិនល្អចំពោះគ្នា និងការមិនទុកចិត្តគ្នាទៅវិញទៅមក> គឺថាតែងតែមានជារហូត <និងចាក់ឫសយ៉ាងជ្រៅ អាចប្រៀបធៀបបានទៅនឹង ក្រិក និង ទួរគី, អារ៉ាប់ និង>ជ្វីស ហើយនិងម៉ូស្លីម<និងហិណ្ឌូ>អ៊ីចឹងដែរ មិនមានការទុកចិត្តគ្នា។ បទពិសោធន៍<>ប្រវត្តិសាស្ត្រកម្ពុជា គឺ<វិធីសាស្ត្រ>ទំនាក់ទំនង<បរទេស ដែល>មានដំណើរការទៅល្អ <គ្រប់ទីកន្លែង> រួមមានទាំងផ្នែកតុល្យភាពនយោបាយ <និងសម្ព័ន្ធមិត្តយោធា មិនដំណើរការល្អសម្រាប់កម្ពុជា។"> ហើយចំណុចដែលសំខាន់បំផុតនោះគឺថា "បក្សកុម្មុយនីស្តវៀតណាម បានចាត់ទុកសហព័ន្ធឥណ្ឌូចិនគឺជាគោលបំណងមួយដែលត្រូវបង្កើតជាយូរណាស់មកហើយសម្រាប់ឧបទ្វីបមួយនេះ ដែលតម្រូវឲ្យកម្ពុជា និងឡាវ <យល់ស្របតាម ឬ>យ៉ាងហោចណាស់គឺថា <រក>អ្នកដែល

គ្រប់គ្រង<នៅក្នុងប្រទេសទាំងពីរនេះ ដែលគោរពតាមគំនិត>ក្នុងការបង្កើត<សហព័ន្ធ>ឥណ្ឌូចិន<ដែល>វៀតណាម <ស្ថិតក្នុងស្ថានភាពមួយមិនប្រញាប់ប្រញាល់>។” បញ្ចប់ការដកស្រង់។

តើលោកយល់ស្របជាមួយនឹងការវិភាគរបស់គាត់នេះដែរឬទេ? ជាពិសេសចំណុចដែលគាត់លើកឡើងអំពីសហព័ន្ធឥណ្ឌូចិនថា ជាគោលបំណងផ្នែកខាងនយោបាយមួយដែលតម្រូវឲ្យមាននោះ?

[១៥:៥៨:២០]

**ឆ៖** បក្សកុម្មុយនីស្តវៀតណាមនៅពេលនោះ គឺបានគិតដូច្នេះមែន ខ្ញុំស្រប ខ្ញុំយល់ស្រប។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រហែលជាដល់ពេលត្រូវសម្រាកសម្រាប់ល្ងាចនេះហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណអ្នកជំនាញ។ បាទ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី១៨ ខែតុលា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ស្ទីហ្វិន ម័ររីស សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកអ្នកជំនាញ ស្ទីហ្វិន ម័ររីស សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាអ្នកជំនាញនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនអ្នកជំនាញវិលត្រឡប់ទៅកាន់ដែលកន្លែងគាត់ស្នាក់នៅវិញ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញនៅថ្ងៃស្អែក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*